សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍរបស់ខេត្តកំពង់ស្ពឺ
# (ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៨)

ស្រាវជ្រាវពីថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ: **អ៊ុង ច័ន្ទរិទ្ធ**
**ដួង ចន្ថា**

សាស្ត្រាចារ្យណែនាំ
លោក **ថោង ចន្ត្រា**

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ
ជំនាន់ទី ១១

ឆ្នាំចូលរៀន ២០១៤
ឆ្នាំសរសេររបាយការណ៍ ២០១៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទទាំងពីរនាក់ឈ្មោះ **អ៊ុង ច័ន្ទរិទ្ធ** និង **ជួន ចន្ថា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី៤ ជំនាន់ទី១១ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំសិក្សា២០១៧-២០១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានសរសេររបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី "**ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍរបស់ខេត្តកំពង់ស្ពឺ**(**ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៨**)" សូមលំឱនកាយវាចាចិត្តសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដ៏សែនស្មោះស្ម័គ្រជូនចំពោះលោកអ្នកមានគុណរួមមានដូចខាងក្រោម៖

**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើតឱ្យកូនបានរស់រានមានជីវិត បើគ្មានលោកអ្នកមានគុណទាំងពីរទេរូបកូនក៏គ្មានថ្ងៃនេះដែរ គុណនេះពុំអាចកាត់ថ្លៃបានឡើយ។ ខ្ញុំសូមអរគុណនូវអ្វីគ្រប់យ៉ាងដែលលោកបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ កម្លាំងចិត្ត បូជាជូនកូនដោយមិនគិតពីការនឿយហត់ក្រលំបាក ដើម្បីចិញ្ចឹមបីបាច់ថែរក្សាការពារ បណ្តុះបណ្តាលអប់រំទូន្មានឱ្យកូនប្រព្រឹត្តតែអំពើល្អ។ ទាំងនេះគឺជាឱសថដ៏សក្តិសិទ្ធសម្រាប់កូនក្នុងការបន្តពុះពារគ្រប់ឧបសគ្គក្នុងជីវិតដើម្បីឆ្ពោះទៅរកភាពឧត្តុងឧត្តមនាពេលអនាគត។

**ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង** គណៈគ្រប់គ្រង មន្ត្រី បុគ្គលិកបម្រើការ និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលសិក្សា និងខិតខំព្យាយាមបង្ហាត់បង្រៀនរាល់ចំណេះដឹង និងជំនាញក៏ដូចជាផ្តល់ដំបូន្មានល្អៗពិតប្រាកដដល់រូបយើងខ្ញុំ។

លោកសាស្ត្រាចារ្យ **ថោង ចន្ត្រា** គឺជាសាស្ត្រាចារ្យម្នាក់ប្រកបដោយគតិបណ្ឌិត ដែលលោកបានដឹកនាំក្នុងការសរសេររបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះ។ លើសពីនេះទៅទៀតលោកបានលះបង់កម្លាំងកាយ កម្លាំងចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃ ខិតខំប្រឹងប្រែងណែនាំកែសម្រួល និងផ្តល់នូវមតិល្អៗដែលធ្វើឱ្យសារណានេះមានភាពល្អប្រសើរ និងសម្រេចបានជោគជ័យ។

**ឯកឧត្តម ឌី សំណាង** អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ព្រមទាំងមន្ត្រីរាជការទូទាំងសាលាខេត្តកំពង់ស្ពឺ ដែលបានបង្កលក្ខណៈងាយស្រួលដល់យើងខ្ញុំក្នុងការស្រាវជ្រាវរកឯកសារទាំងឡាយដែលពាក់ព័ន្ធ និងបានពន្យល់ណែនាំពីស្ថានភាពរបស់ខេត្តកំពង់ស្ពឺ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមប្រសិទ្ធិពរជ័យជូនដល់អស់លោកអ្នកមានគុណទាំងអស់សូមជួបតែពុទ្ធពរទាំង ៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់។ ក្នុងនោះវិស័យរដ្ឋបាលសាធារណៈ គឺជាស្នូលមួយដែលរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងចំណោមវិស័យជាច្រើនទៀត។ ជាមួយគ្នានេះដែររាជរដ្ឋាភិបាល បានជំរុញការបង្កើតឱ្យមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើប្រាស់នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ក្នុងគោលបំណងធ្វើកំណែទម្រង់រចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យតាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ដូច្នេះហើយបានជាយើងខ្ញុំ សម្រេចចិត្តសរសេររបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី"**ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍរបស់ខេត្តកំពង់ស្ពឺ (ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៨)**" ដើម្បីសិក្សាស្វែងយល់ពីដំណើរការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយនេះ។ លើសពីនេះទៅទៀតដោយសារតែយល់ឃើញនូវសារៈសំខាន់ដែលមិនអាចខ្វះបាននៃចំណេះដឹង ដែលជាគ្រឹះក្នុងការអនុវត្តក្រសួង ស្ថាប័ន ជាពិសេសនោះគឺរដ្ឋបាលថ្នាក់ក្រោមជាតិនេះតែម្តងដែលនៅជាប់ជាមួយប្រជាពលរដ្ឋក្នុងការអនុវត្តតួនាទី ភារកិច្ច និងមុខតំណែងរបស់មន្ត្រីរាជការ។

ក្នុងការសរសេររបាយការណ៍កម្មសិក្សាប្រធានបទខាងលើនេះ ក្រុមយើងខ្ញុំបានប្រើប្រាស់អស់លទ្ធភាព អត្ថន័យ ខ្លឹមសារ ដើម្បីឱ្យស៊ីជម្រៅ និងមានប្រសិទ្ធភាពខ្ពស់ នឹងដើម្បីឱ្យសម្រេចចេញជាលទ្ធផលមួយជាទីពេញចិត្ត ប៉ុន្តែទោះបីជាយើងខ្ញុំបាទខិតខំប្រឹងប្រែងយ៉ាងណាក៏ការខ្វះខាតការកើតមានកំហុសនៅតែមាន។

យើងខ្ញុំមានសេចក្តីរីករាយជាខ្លាំងប្រសិនបើសំណាក់អ្នកសិក្សា លោក លោកស្រី សាស្ត្រាចារ្យ និស្សិតក៏ដូចជាមិត្តអ្នកអានទាំងឡាយមេត្តាជួយផ្តល់នូវការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យរបាយ-ការណ៍កម្មសិក្សានេះកាន់តែល្អប្រសើរ និងក្លាយជាកម្រងឯកសារទំនើបប្រកបដោយខ្លឹមសារ និងអត្ថន័យជាសារវន្ត ហើយយើងខ្ញុំសង្ឃឹមថាកម្រងឯកសារនេះវាអាចជួយជាប្រយោជន៍ និងរួមចំណែកក្នុងការលើកស្ទួយកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ក៏ដូចជាមិត្តនិស្សិតដែលមានបំណងស្រាវជ្រាវបន្តទៀត។

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម


**១- លំនាំបញ្ហានៃការស្រាវជ្រាវ** ........ ១

**២- ចំណោទបញ្ហានៃការស្រាវជ្រាវ** ........ ១

**៣- គោលបំណងនៃការស្រាវជ្រាវ** ........ ២

**៤- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ** ........ ២

**៥- សារៈសំខាន់នៃការស្រាវជ្រាវ** ........ ២

**៦- វិធីសាស្រ្តនៃស្រាវជ្រាវ** ........ ២

**៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៣


## ជំពូកទី ១

## ដំណើរការគ្រប់គ្រងរដ្ឋបាលខេត្តកំពង់ស្ពឺ


**១.១- ក្រុមប្រឹក្សាខេត្ត** ........ ៤

**១.១.១- សមាសភាព** ........ ៤

**១.១.២- សិទ្ធិអំណាចក្រុមប្រឹក្សាខេត្ត** ........ ៥

**១.១.៣- របៀបរបបការងារក្រុមប្រឹក្សា** ........ ៥

**១.២- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា** ........ ៧

**១.២.១- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** ........ ៨

១.២.១.១- សមាសភាព ........ ៨

១.២.១.២- តួនាទី និងភារកិច្ច ........ ៨

**១.២.២- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារ** ........ ១០

១.២.២.១- សមាសភាព ........ ១១

១.២.២.២-តួនាទី និងភារកិច្ច ........ ១១

**១.២.៣- គណៈកម្មាធិការលទ្ធកម្ម** ........ ១៣

១.២.៣.១- សមាសភាព ........ ១៣

១.២.៣.២- តួនាទី និងភារកិច ........ ១៣

**១.៣- អភិបាលនៃគណៈអភិបាលខេត្ត** ........ ១៥

**១.៣.១- សមាសភាព** ........................................ ១៥

**១.៣.២- តួនាទី និងភារកិច្ច** ........................................ ១៥

**១.៤- នាយករដ្ឋបាលខេត្ត** ........................................ ១៩

**១.៤.១- សមាសភាព** ........................................ ១៩

**១.៤.២- តួនាទី និងភារកិច្ច** ........................................ ១៩

**១.៥- ទីចាត់ការ អង្គភាព និងការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត** ........................................ ២១

**១.៥.១- ទីចាត់ការរដ្ឋបាល** ........................................ ២២

**១.៥.២- ទីចាត់ការផែនការ និងវិនិយោគ** ........................................ ២៤

**១.៥.៣- ទីចាត់ហិរញ្ញវត្ថុ** ........................................ ២៧

**១.៥.៤- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស** ........................................ ២៨

**១.៥.៥- ទីចាត់ការអន្តរវិស័យ** ........................................ ៣១

**១.៥.៦- អង្គភាពលទ្ធកម្ម** ........................................ ៣៤

**១.៥.៧- អង្គភាពច្រកចេញចូលតែមួយ** ........................................ ៣៥


## ជំពូកទី ២

## ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តការងាររបស់ខេត្តកំពង់ស្ពឺ

**២.១- ស្ថានភាពទូទៅនៃខេត្តកំពង់ស្ពឺ** ........................................ ៣៨

**២.២- ស្ថានភាពភូមិសាស្ត្រ** ........................................ ៣៨

**២.៣- ការរៀបចំផែនការអភិវឌ្ឍរបស់ខេត្តកំពង់ស្ពឺ** ........................................ ៣៩

**២.៣.១- ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍** ........................................ ៣៩

**២.៣.២- គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច** ........................................ ៣៩

**២.៣.៣- គោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច** ........................................ ៤០

**២.៣.៤- គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** ........................................ ៤០

**២.៣.៥- គោលដៅអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** ........................................ ៤១

**២.៤- ចំណុចខ្លាំងក្នុងការអនុវត្តការងារ** ........................................ ៤១

**២.៤.១- ការងារគ្រប់គ្រងរាស្ត្រប្រជា** ........................................ ៤១

**២.៤.២- ការងារគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ច** ........................................ ៤២

២.៤.២.១- ការងារសេដ្ឋកិច្ច ........................................ ៤២

២.៤.២.២- ការងារសង្គមកិច្ច ........................................................................ ៤៨
**២.៤.៣- ការគ្រប់គ្រងដីធ្លី បរិស្ថាន សាធារណការ និងសោភ័ណភាព** ............................. ៥២
**២.៤.៤- រដ្ឋបាល និងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ........................................... ៥៤
២.៤.៤.១- ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ............................ ៥៤
២.៤.៤.២- ការងារសន្តិសុខ ........................................................................ ៥៤
២.៤.៤.៣- ការងារសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ចរាចរណ៍ ......................... ៥៥
**២.៥. ចំណុចខ្សោយក្នុងការអនុវត្តការងារ** ........................................................ ៥៦

## ជំពូកទី ៣

## គោលនយោបាយ និងសកម្មភាពអាទិភាពសម្រាប់ឆ្នាំ ២០១៨-២០១៩

**៣.១- យុទ្ធសាស្ត្រអភិវឌ្ឍន៍** ........................................................................ ៥៨
**៣.១.១- ការងាររដ្ឋបាលដែនដី** ........................................................................ ៥៨
**៣.១.២- ការងារគ្រប់គ្រងសេដ្ឋកិច្ច** ........................................................................ ៥៩
**៣.១.៣- ការងារគ្រប់សង្គមកិច្ច**........................................................................ ៦១
**៣.២- ការងារគ្រប់គ្រងដីធ្លី សាធារណការ និងកែលម្អសោភ័ណភាព** ............................. ៦៣
**៣.៣- ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម** ........................................................ ៦៤
**សេចក្តីសន្និដ្ឋាន** ........................................................................ ៦៥
**អនុសាសន៍** ........................................................................ ៦៧
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីងើបផុតពីសង្គ្រាមដ៏រាំរ៉ៃជាងពីរទសវត្សរ៍ ពិសេសរបបប៉ុលពត ដែលធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្តទាំងឡាយត្រូវបានបំផ្លាញខ្ទេចខ្ទីស្ទើរតែទាំងស្រុង និងផ្ដើមចេញពីនយោបាយឈ្នះឈ្នះ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់ថ្មីៗ ពិសេសលើកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលជំរុញឱ្យដំណើរការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅមូលដ្ឋានមានការរីកដុះដាលជាបន្តបន្ទាប់ ក្នុងគោលបំណងសំដៅរួមចំណែកក្នុងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋតាមរយៈការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាព។

ទន្ទឹមនឹងនេះខេត្តកំពង់ស្ពឺ ក៏មានការរីកចម្រើនលើគ្រប់វិស័យ ដូចជាវិស័យកសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល វិស័យសាធារណៈ និងដឹកជញ្ជូន វិស័យអភិវឌ្ឍជនបទ វិស័យធនធានទឹក។ វិស័យទាំងនេះបានរួមចំណែកឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាន់តែល្អប្រសើរឡើងជាលំដាប់តាមរយៈការកាត់បន្ថយបាននូវភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដើម្បីចូលរួមចំណែកលើមាគ៌ាដ៏ត្រឹមត្រូវក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានប្រកបដោយចីរភាព គណនេយ្យភាព និងតម្លាភាព ការកសាងផែនការអភិវឌ្ឍរយៈពេលវែងមានភាពចាំបាច់បំផុត ដែលតម្រូវឱ្យមានការចូលរួមយ៉ាងពេញលេញពីសំណាក់ប្រជាពលរដ្ឋ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តែទោះបីជាយ៉ាងណាក៏ដោយរដ្ឋបាលខេត្តកំពង់ស្ពឺ ក៏នៅមានបញ្ហាប្រឈម និងតម្រូវការមួយចំនួនដែលទាមទារឱ្យមានការឆ្លើយតបបានត្រឹមត្រូវទាន់ពេល និងមានប្រសិទ្ធភាពពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានទើបគោលនយោបាយជាយុទ្ធសាស្ត្រទាំងឡាយរបស់រដ្ឋបាលខេត្តអាចប្រព្រឹតទៅដោយប្រសិទ្ធភាព។ ដើម្បីឱ្យការសិក្សាស្រាវជ្រាវកាន់តែស៊ីជម្រៅបន្ថែមទៀតនោះក្រុមរបស់យើងខ្ញុំក៏បានដាក់ចេញនូវចំណោទបញ្ហាដូចជា៖

១. តើការគ្រប់គ្រងរដ្ឋបាលខេត្តកំពង់ស្ពឺ មានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

២. តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍខេត្ត?

៣. តើខេត្តត្រូវមានទិសដៅយ៉ាងណាខ្លះដើម្បីកែលម្អ និងដោះស្រាយបញ្ហាទាំងនោះឱ្យបានល្អប្រសើរ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ គឺមានគោលបំណងដើម្បីបង្កើននូវការយល់ដឹងអំពីការអនុវត្តការងារ និងការស្វែងយល់ពីតថភាពជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលនៅក្នុងសាលាខេត្តកំពង់ស្ពឺ ការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋមូលដ្ឋានរបស់ខ្លួន និងបញ្ហាប្រឈមក្នុងការអនុវត្តការងាររបស់ខេត្ត មួយវិញទៀតក៏មានការលើកឡើងនូវសំណូមពរមួយចំនួនដើម្បីឱ្យខេត្តធ្វើការកែលម្អនូវចំណុចដែលមានការខ្វះខាតមួយចំនួន។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាមួយជាធម្មតារមែងមាននូវដែនកំណត់ និងវិសាលភាព ដូចគ្នានេះផងដែរនៅក្នុងការសិក្សាទៅលើប្រធានបទស្តីពី **"ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍរបស់ខេត្តកំពង់ស្ពឺ (ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៨)"** នេះជាដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ គឺធ្វើការសិក្សាទៅលើរចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលទាំងមូលនៃសាលាខេត្តកំពង់ស្ពឺ ដើម្បីឱ្យមានភាពកាន់តែច្បាស់លាស់នូវដំណើរការងារក៏ដូចជាការប្រព្រឹត្តទៅនៃខេត្តកំពង់ស្ពឺផងដែរ។ ការសិក្សានេះផ្តោតទៅលើសកម្មភាពការងាររដ្ឋបាលខេត្តកំពង់ស្ពឺ ដែលបានអនុវត្តក្នុងឆ្នាំ២០១៧ និងត្រីមាសទី១ ឆ្នាំ២០១៨ តែប៉ុណ្ណោះ។ ដោយឡែកនៅផ្នែកចុងក្រោយនៃការសិក្សាស្រាវជ្រាវនេះស្វែងរកបញ្ហាប្រឈមនានា និងដំណោះស្រាយ រួមជាមួយនឹងការលើកទិសដៅសម្រាប់ឆ្នាំបន្ទាប់ ព្រមទាំងការផ្តល់ជាអនុសាសន៍ដើម្បីជាការកែលម្អដល់ចំណុចខ្វះខាតមួយចំនួនដែរ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការលើយកប្រធានបទនៃការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍរបស់ខេត្តកំពង់ស្ពឺ មកធ្វើការសិក្សាស្រាវក្នុងរយៈពេលពីរខែកន្លងមកនេះ ពិតជាបានផ្តល់អត្ថប្រយោជន៍ខ្ពស់សម្រាប់ក្រុមយើងខ្ញុំ ពោលគឺប្រធានបទនេះបានផ្តល់ឱកាសឱ្យយើងខ្ញុំរួមសហការគ្នាបានល្អ ទាំងការពិភាក្សាការចែករំលែកនូវចំណេះដឹង មិនត្រឹមតែប៉ុណ្ណោះយើងខ្ញុំក៏បានទទួលនូវចំណេះដឹងថ្មីៗផ្សារភ្ជាប់ជាមួយនឹងការងាររដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាផ្នែកដ៏សំខាន់មួយក្នុងការសិក្សាលើមុខជំនាញរដ្ឋបាលសាធារណៈ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

សម្រាប់ការសិក្សាស្រាវជ្រាវនូវប្រធានបទនេះត្រូវបានធ្វើឡើងតាមរយៈ ឯកសារយោងមួយចំនួនដូចជា សៀវភៅនៅក្នុងបណ្ណាល័យ និងបណ្ណាគារមួយចំនួនព្រមទាំងធ្វើការប្រមូលទិន្នន័យដែលបានមកពីប្រភពដែលពាក់ព័ន្ធដើម្បីយកមកធ្វើការសិក្សានេះ។ ចំណែកឯការចងក្រងនូវរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះគឺចាំបាច់ត្រូវបែងចែកនូវប្រភេទទិន្នន័យជាពីរគឺ៖

➢ **ទិន្នន័យបន្ទាប់បន្សំ**

ចំពោះទិន្នន័យចម្បងនេះត្រូវបានចងក្រងឡើង តាមរយៈការចុះទៅសិក្សាស្រាវជ្រាវនៅសាលាខេត្តកំពង់ស្ពឺដោយផ្ទាល់។ ហើយបានធ្វើការប្រមូលនូវទិន្នន័យឯកសារសកម្មភាពការងាររបស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ និងសមិទ្ធផលនានា ព្រមទាំងបានចុះទៅសាកសួរព័ត៌មានមួយចំនួនពីនាយករដ្ឋបាលសាលាខេត្ត និងពីអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺដោយផ្ទាល់ផងដែរ។

➢ **ទិន្នន័យបន្ទាប់បន្សំ**

ចំពោះទិន្នន័យបន្ទាប់បន្សំវិញ គឺត្រូវបានរៀបចំឡើងដោយបានប្រមូលនូវឯកសារពាក់ព័ន្ធសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមបណ្ណាល័យសាធារណៈនានា រួមផ្សំទាំងគេហទំព័ររបស់រដ្ឋក៏ដូចជាស្ថាប័នក្រសួងមហាផ្ទៃ ជាពិសេសគេហទំព័រនៃសាលាខេត្តកំពង់ស្ពឺ នៅលើប្រព័ន្ធអ៊ីនធឺណែត និងឯកសារផ្សេងៗមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការធ្វើឱ្យកម្រងស្នាដៃស្រាវជ្រាវមួយនេះប្រកបដោយទៅដោយលទ្ធផលល្អប្រសើរ និងរបៀបរៀបរយនោះ គឺចាំបាច់ណាស់ក្នុងការបង្កើតនូវរចនាសម្ព័ន្ធនៃការស្រាវជ្រាវមួយប្រកបដោយភាពច្បាស់លាស់ និងមានលក្ខណៈងាយស្រួលក្នុងការយល់ និងមិនមានភាពសាំញ៉ាំហើយសមស្របទៅតាមបទដ្ឋាននៃការតាក់តែងរបាយការណ៍កម្មសិក្សា ដែលសាកលវិទ្យាល័យបានកំណត់ ហេតុនេះស្នាដៃស្រាវជ្រាវមួយនេះត្រូវបានរៀបចំចងក្រងដោយធ្វើការបែងចែកជា បីជំពូកសំខាន់ៗ ដែលក្នុងនោះរួមមាន៖

**ជំពូកទី១៖** បង្ហាញពី ដំណើរការគ្រប់គ្រងរដ្ឋបាលខេត្តកំពង់ស្ពឺ ដោយបានលើកឡើងពីរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តកំពង់ស្ពឺ

**ជំពូកទី២៖** បង្ហាញពី វិចារណកម្មរបស់ខេត្តកំពង់ស្ពឺ ដោយបានលើកឡើងពី ស្ថានភាពទូទៅ និងស្ថានភាពភូមិសាស្ត្រនៃខេត្តកំពង់ស្ពឺ និងចំណុចខ្លាំងក្នុងការអនុវត្តការងាររបស់រដ្ឋបាលខេត្ត

**ជំពូកទី៣ ៖** បង្ហាញពី បញ្ហាប្រឈម និងដំណោះស្រាយ ដោយលើកឡើងពី ចំណុចខ្សោយក្នុងការអនុវត្តការងារ និងការលើកទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់

# ជំពូកទី ១
# ដំណើរការគ្រប់គ្រងរដ្ឋបាល
# ខេត្តកំពង់ស្ពឺ

# ជំពូកទី ១
# ដំណើរការគ្រប់គ្រងរដ្ឋបាលខេត្តកំពង់ស្ពឺ

## ១.១- ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ដែលស្ថិតនៅក្នុងសមត្ថកិច្ចខេត្តកំពង់ស្ពឺ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាអសកល[1]។ ក្រុមប្រឹក្សាមានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង[2] ហើយអាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់[3]។ លើសពីនេះទៅទៀតក្នុងពេលរងចាំក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិនេះមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃប៉ុណ្ណោះ[4]។

ក្រុមប្រឹក្សាគឺជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន[5]។

### ១.១.១- សមាសភាព

ជាក់ស្តែងចំនួនក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ មានចំនួន១៧រូប ដែលមាន ១រូបជាប្រធាន និង១៦រូបទៀតជាសមាជិក[6]។ ចំនួនក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយផ្អែកតាមកត្តាភូមិសាស្ត្រ និងកត្តាប្រជាសាស្ត្រដូចខាងក្រោម[7]៖

- ក្រុមប្រឹក្សារាជធានី មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប
- ក្រុមប្រឹក្សាស្រុក ខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងតិចចំនួនមួយរយម្ភៃ(១២០)ថ្ងៃ មុនពេលផុតកំណត់

---

[1] មាត្រា១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[2] មាត្រា១៥ វក្យខណ្ឌ១ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[3] មាត្រា១៥ វក្យខណ្ឌ២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[4] មាត្រា១៦ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជាធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[5] មាត្រា៦ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
[6] ប្រការ១ ប្រកាសលេខ ៧២០៧ ប្រក ស្តីពីការទទួលស្គាល់សមាជិកក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ
[7] មាត្រា១៨ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

អាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងករណីដែលគ្មានអនុក្រឹត្យចែងអំពីចំនួនក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេ នោះចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សានីមួយៗត្រូវយកតាមចំនួនសរុបនៃក្រុមប្រឹក្សាអាណត្តិចាស់។

### ១.១.២- សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តមានសិទ្ធិអំណាចពីរគឺ៖

- សិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និង
- សិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិ

ក្រុមប្រឹក្សាខេត្តត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួនដោយផ្អែកតាមគោលការណ៍បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ប្រធានក្រុមប្រឹក្សាខេត្តក្នុងនាមក្រុមប្រឹក្សខេត្តរបស់ខ្លួន មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលខេត្តលើ[8]៖

- ដីកា ឬសេចក្ដីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច
- សេចក្ដីសម្រេចអំពីការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខេត្ត
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាខេត្ត
- សំណើដកហូតអភិបាលខេត្ត ឬអភិបាលរងខេត្ត ចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥២ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខេត្ត
- ប្រតិទិនប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តសម្រាប់រយៈពេល ១២ខែ
- សំណើសុំផ្លាស់ប្ដូរសមាជិកក្រុមប្រឹក្សាខេត្ត
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលខេត្ត ត្រូវជួយក្រុមប្រឹក្សាខេត្តរបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនឹងសំណើដកហូតអភិបាល ឬអភិបាលរងខេត្តចេញពីមុខតំណែង។

### ១.១.៣- របៀបរបបការងាររបស់ក្រុមប្រឹក្សាខេត្ត

ក្នុងការអនុវត្តសិទ្ធិនូវអំណាចរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវត្រួតពិនិត្យពិចារណាលើការងារសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងរបៀបអនុវត្តការងារដូចខាងក្រោម[9]៖

[8] មាត្រា១៣ នៃអនុក្រឹត្យលេខ ២១៦

- ក្រុមប្រឹក្សាខេត្តត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ តាមរយៈដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិ។ រាល់សេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិត្រូវធ្វើឡើងក្នុងអង្គប្រជុំក្រុមប្រឹក្សាខេត្តរបស់ខ្លួន ហើយត្រូវធានាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ
- ក្រុមប្រឹក្សាខេត្តអាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចំបាច់។ គណៈអភិបាលខេត្ត ត្រូវដឹកនាំនាយករដ្ឋបាលសាលាខេត្ត និងទីចាត់ការពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ ព្រមទាំងធ្វើការសម្របសម្រួលណែនាំដល់ទីចាត់ការនានានៃសាលាខេត្តក្នុងការរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យពិភាក្សា និងអនុម័ត។ លើសពីនេះទៀតអភិបាលខេត្តត្រូវណែនាំនាយករដ្ឋបាលសាលាខេត្តឱ្យរៀបចំដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួចឱ្យស្របតាមទម្រង់ដែលបានកំណត់ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាខេត្តរបស់ខេត្ត និងត្រូវប្រថាប់ត្រារដ្ឋបាលខេត្ត
- ក្រុមប្រឹក្សាខេត្ត ត្រូវចាត់ឱ្យអភិបាលខេត្តចាត់ចែងផ្សព្វផ្សាយជាសាធារណៈនូវដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធិភាព
- ក្នុងករណីកិច្ចការណាមួយដែលតម្រូវការចាំបាច់នៃមូលដ្ឋាន ហើយដែលកិច្ចការនោះច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់អំណាចនីតិបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យអភិបាលធ្វើការស្រាវជ្រាវរៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ឬអាចស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទនីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ

[9] ចំណុច៣.២ នៃសៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលខេត្ត ឆ្នាំ២០១១

- ក្នុងករណីណាដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធី តែប៉ុន្តែ បែបបទនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាខេត្តមិនអាចអនុវត្តបានក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្ត ធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ ដោយផ្អែកតាមយន្តការរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហេតុដូច្នេះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយករណីនេះ។

**កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺមានពីរប្រភេទ[10]គឺ៖**

- **កិច្ចប្រជុំសាមញ្ញ ៖** ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន ១២ដង ក្នុងមួយឆ្នាំ
- **កិច្ចប្រជុំវិសាមញ្ញ ៖** ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ដើម្បីដោះស្រាយបញ្ហាបន្ទាប់ ឬពិសេស។

កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តអាចយកជាបានការ លុះត្រាតែកិច្ចការប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខេត្ត។ ចំពោះសេចក្តីសម្រេចណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខេត្ត ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ដូច្នេះរាល់សេចក្តីសម្រេចនោះពុំអាចមានសុពលភាពឡើយ។ ជាងនេះទៅទៀត ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សា អាចស្នើឱ្យមានកិច្ចប្រជុំវិសាមញ្ញបានលុះត្រាតែមានសម្លេង ១/៣ នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។

## ១.២- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាមានកាតព្វកិច្ចរៀបចំឱ្យមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបីដែលរួមមាន[11]

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

ក្រៅពីក្រុមប្រឹក្សាខេត្ត មានជាកាតព្វកិច្ចទាំងបីខាងលើនេះក្រុមប្រឹក្សាខេត្តអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ គណៈកម្មាធិការដែលបង្កើតបន្ថែមនេះមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើឡើយ។ ជាមួយនេះក្រុមប្រឹក្សាខេត្តអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗ

---

[10] ប្រការ១ នៃដីកាស្តីពី បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ

[11] មាត្រា១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលខេត្ត។ អនុគណៈកម្មាធិការ ឬក្រុមការងារខាងលើនេះត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬគណៈអភិបាលខេត្ត។

### ១.២.១- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

ក្រុមប្រឹក្សាខេត្ត ត្រូវរៀបចំឱ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ខ្លួនដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តរបស់ខ្លួនលើបញ្ហាទាក់ទងនឹងការងារផែនការថវិកា ការសម្របសម្រួលកិច្ចការនានាជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារ ធនធានដែលបានប្រគល់ឱ្យ ឬបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាខេត្ត[12]។

#### ១.២.១.១- សមាសភាព

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានសមាសភាពដូចខាងក្រោម[13]៖

| | |
|---|---|
| – អភិបាលខេត្ត | ប្រធាន |
| – អភិបាលរងខេត្ត (១រូប) | អនុប្រធាន |
| – នាយករដ្ឋបាលសាលាខេត្ត | សមាជិកអចិន្ត្រៃយ |
| – សមាជិកក្រុមប្រឹក្សាខេត្ត (២រូប) | ជាសមាជិក |
| – ប្រធានមន្ទីរ អង្គភាពប្រចាំនៅខេត្ត (២៥រូប) | ជាសមាជិក |
| – នាយកទីចាត់ការទាំងអស់របស់សាលាខេត្ត (៦រូប) | ជាសមាជិក |
| – អភិបាលក្រុង ស្រុក ទាំងអស់របស់សាលាខេត្ត (៨រូប) | ជាសមាជិក |
| – តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត | ជាសមាជិក |
| – តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ | ជាសមាជិក |

#### ១.២.១.២- តួនាទី និងភារកិច្ច

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺជាគណៈកម្មាធិការមួយដែលមានតួនាទី និងភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តលើកិច្ចការសំខាន់ៗដូចខាងក្រោម[14]

**ក . ផែនការអភិវឌ្ឍន៍ និងថវិកា**

– សេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត

[12] ចំណុច ៦.២ សៀវភៅណែនាំ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលខេត្ត ឆ្នាំ២០១១

[13] សេចក្តីសម្រេចលេខ ០២ ស.ស.រ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ

[14] ប្រកាស ២ នៃសេចក្តីសម្រេចលេខ ០២ ស.ស.រ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ

- ការដាក់បញ្ចូលផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ និងអង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាទៅក្នុងផែនការអភិវឌ្ឍន៍រយៈ៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សាខេត្ត និងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុ និងថវិការបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគខេត្ត ដើម្បីគាំទ្រដល់កម្មវិធីនានារបស់ខេត្ត
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានា ដល់គម្រោងវិនិយោគខេត្ត
- របាយការណ៍រីកចម្រើននានាទាក់ទងដល់ការងារផែនការអភិវឌ្ឍកម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សាខេត្ត។

**ខ. ការសម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខេត្ត ជាមួយមន្ទីរអង្គភាពរបស់ក្រសួងស្ថាប័ននានា**

- កិច្ចសហប្រតិបត្តិការការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាខេត្តជាមួយមន្ទីរអង្គភាពរបស់ក្រសួងស្ថាប័ន
- ការសម្របសម្រួលការផ្តល់សេវា និងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សាខេត្ត ជាមួយក្រសួង ស្ថាប័ន មន្ទីរអង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានាដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍនានាឱ្យស្របតាមតម្រូវការរបស់មូលដ្ឋាន។

**គ. កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខេត្ត**

- ការរៀបចំយន្តការពិគ្រោះយោបល់ និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពខេត្ត
- ការរៀបចំប្រព័ន្ធ និងនីតិវិធីបំពេញការងារព្រមទាំងទំនាក់ទំនងរបស់ទីចាត់ការនានានៃសាលាខេត្ត

- ការដោះស្រាយនូវភាពមិនភាពចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់នៃសាលាខេត្ត។

**ឃ. កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្ត ជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ខេត្ត**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារ និងធនធាន
- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខេត្ត ជាមួយនឹងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត
- ការឆ្លើយតបចំពោះអនុសាសន៍សំណើ និងសំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ នៅក្នុងខេត្តក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះមិនអាចដោះស្រាយបាន
- ដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខេត្ត ជាមួយក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់នៅក្នុងខេត្ត
- ការសម្រុះសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខេត្ត ជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នា និងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត។

**ង. ការងារទាក់ទងមុខងារ និងធនធាន**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារ និងធនធាន
- ការរៀបចំនូវលក្ខណៈសម្បត្តិ និងមធ្យោបាយដើម្បីទទួល និងអនុវត្តមុខងារ និងធនធានដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យខេត្ត
- ការផ្តួចផ្តើមអំពីការធ្វើប្រតិភូកម្មមុខងារ និងធនធានដល់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងសង្កាត់
- ការវាយតម្លៃលើការអនុវត្តមុខងារ និងធនធានដែលស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលខេត្ត

ក្រៅពីភារកិច្ចខាងលើ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀតតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

### ១.២.២- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

ក្រុមប្រឹក្សាខេត្ត ត្រូវរៀបចំឱ្យមានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារដែលមានសិទ្ធិ និងភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត អភិបាលខេត្ត និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាខេត្ត លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័ន បញ្ហាស្ត្រី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងអំណាចមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។

### ១.២.២.១- សមាសភាព

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ មាន សមាសភាពដូចខាងក្រោម[15]៖

| | |
|---|---|
| – សមាជិកក្រុមប្រឹក្សាខេត្តជាស្ត្រី | ជាប្រធាន |
| – សមាជិកក្រុមប្រឹក្សាខេត្ត | ជាអនុប្រធាន |
| – អភិបាលរងខេត្ត ជាស្ត្រីមួយ (០១) រូប | ជាអនុប្រធាន |
| – អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត | ជាអនុប្រធាន |
| – អនុប្រធានមន្ទីរកិច្ចការនារីខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| – នាយករងរដ្ឋបាលសាលាខេត្តមួយ (០១) រូប | ជាសមាជិក |
| – អនុប្រធានមន្ទីរសុខាភិបាលខេត្ត | ជាសមាជិក |
| – អនុប្រធានមន្ទីរផែនការខេត្ត | ជាសមាជិក |
| – អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | ជាសមាជិក |
| – អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ជាសមាជិក |
| – អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | ជាសមាជិក |
| – អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | ជាសមាជិក |
| – ស្នងការរងនគរបាលខេត្ត | ជាសមាជិក |
| – នាយករងទីចាត់ការអន្តរវិស័យខេត្ត | ជាសមាជិក |
| – ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ | ជាសមាជិក |
| – តំណាង អង្គការប្រចាំអាដហុកប្រចាំខេត្ត | ជាសមាជិក |
| – តំណាង អង្គការ L.W.D ប្រចាំខេត្ត | ជាសមាជិក |

### ១.២.២.២- តួនាទី និងភារកិច្ច

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានតួនាទី និងភារកិច្ចដូចខាងក្រោម[16]៖

- ប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងយេន៉ឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំរបស់ក្រុមប្រឹក្សាខេត្ត

[15] ប្រការ ១ នៃសេចក្តីសម្រេចលេខ ០២/១៨ សសរ.ក្រប្រខ ស្តីពីការកែសម្រួលសមាសភាពសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

[16] ប្រការ ២ នៃសេចក្តីសម្រេចលេខ ០២/១៨ សសរ.ក្រប្រខ ស្តីពីការកែសម្រួលសមាសភាពសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

- ការចូលរួមក្នុងការរៀបចំតាក់តែងត្រួតពិនិត្យ និងវង្វាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្តដែលទាក់ទងនឹងការលើកកម្ពស់ និងការឆ្លើយតប នឹងបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ការស្វែងរកការគាំទ្រពីក្រុមប្រឹក្សាខេត្ត គណៈអភិបាល និងគណៈកម្មាធិការផ្សេងៗទៀត នៃក្រុមប្រឹក្សា ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសម ភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារនៅក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សាខេត្ត
- សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាស្រុក ក្រុង ក្នុងការដោះស្រាយបញ្ហា និងសំណូមពរ ឬសំណើនានា ដែលគណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុក ក្រុង មិនអាចដោះស្រាយបានក្នុងការអនុវត្ត មុខងាររបស់ខ្លួន
- លើសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សា ឬគណៈអភិបាលអំពីវិធានការសមស្រប នានាដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធ នឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ
- ស្វែងរក និងការទទួលបានរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការងាររបស់គណៈកម្មាធិការ
- ការជំរុញលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាដែលទាក់ទងនឹង សមភាពយេនឌ័រស្ត្រី យុវវ័យ និងកុមារ ដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ ក្រុមប្រឹក្សា
- ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍អំពីបញ្ហា ដែលបានកើតមានជាប្រចាំ ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ និងមានវិធានការដើម្បីឆ្លើយតប
- ស្វែងរកការគាំទ្រ ដើម្បីជំរុញឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការ-ងារអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ពិនិត្យមើលលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ជាពិសេសដើម្បីកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវា នានា និងដើម្បីលើកអនុសាសន៍ក្នុងការដោះស្រាយបញ្ហាទាំងនោះ
- លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនងកិច្ចសហការ និងការ សម្របសម្រួលរវាងក្រុមប្រឹក្សាប្រភេទផ្សេងទៀត មន្ទីរអង្គភាពពាក់ព័ន្ធនានាអ្នកផ្តល់សេវា អង្គការមិនមែនរដ្ឋាភិបាល ក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍ដើម្បីធានាថា សកម្មភាព ទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រី យុវវ័យ និងកុមារ

- រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហា ដែលទាក់ទងនឹងសមភាពយេនឌ័រការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ
- គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែង ដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។

**១.២.៣- គណៈកម្មាធិការលទ្ធកម្ម**

ក្រុមប្រឹក្សាខេត្ត ត្រូវរៀបចំឱ្យមានគណៈកម្មាធិការលទ្ធកម្មរបស់ខ្លួនដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តរបស់ខ្លួនលើបញ្ហាទាក់ទងនឹងការងារពាក់ព័ន្ធការគ្រប់គ្រង ការដឹកនាំ និងការអនុវត្តកិច្ចការលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួលជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សាប្រព្រឹត្តទៅដោយរលូនប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព គុណភាព សមភាពការសន្សំសំចៃ និងទាន់ពេលវេលា[17]។

**១.២.៣.១- សមាសភាព**

គណៈកម្មាធិការលទ្ធកម្មរបស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ មានសមាសភាពដូចខាងក្រោម[18]៖

| | |
|---|---|
| - អភិបាលខេត្ត | ជាប្រធាន |
| - អភិបាលរងខេត្តមួយ (០១) រូប | ជាអនុប្រធាន |
| - ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាអនុប្រធាន |
| - សមាជិកក្រុមប្រឹក្សាខេត្តបី (០៣) រូប | ជាសមាជិក |
| - នាយករដ្ឋបាលសាលាខេត្ត | ជាសមាជិក |
| - នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | ជាសមាជិក |
| - ប្រធានអង្គភាពលទ្ធកម្មខេត្ត | ជាលេខាធិការ |

**១.២.៣.២- តួនាទី និងភារកិច្ច**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ មានតួនាទី និងភារកិច្ច សំខាន់ៗដូចខាងក្រោម[19]៖

---

[17] ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[18] ប្រការ១ នៃសេចក្តីសម្រេចលេខ ០០២ ស.ស.រ ស្តីពីការទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ

[19] ប្រការ ៥ នៃសេចក្តីសម្រេចលេខ ០០២ ស.ស.រ ស្តីពីការទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ

- គោរពឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលរៀបចំដោយអង្គភាពលទ្ធកម្មដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័ត្ត
- ណែនាំឱ្យអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃកំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់ថវិកាលទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការកិច្ចលទ្ធកម្ម
- ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន
- ចំពោះកិច្ចលទ្ធកម្មដែលត្រួតពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័ត
- ប្រជុំបើកសំណើដេញថ្លៃពិគ្រោះថ្លៃស្វង់តម្លៃ ឬចចារថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញលើលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខមុនសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅអ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន អំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមសង្កេតការណ៍ដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម លើកលែងតែតំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សា
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។

## ១.៣- អភិបាលនៃគណៈអភិបាលខេត្ត

អភិបាលនៃគណៈអភិបាលខេត្ត គឺជាប្រធានគណៈបញ្ជាការឯកភាពខេត្តក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីថែរក្សា សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត។

គណៈអភិបាលខេត្តរួមមានអភិបាលខេត្តមួយរូបជាប្រធាន និងអភិបាលរងខេត្តមួយ ចំនួន[20]។ ហើយគណៈអភិបាលខេត្តមានចំនួនពីបី(៣)រូប ទៅប្រាំពីរ(៧)រូប[21]។ អភិបាលខេត្ត ត្រូវ តែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រីព្រមទាំងមានសេចក្តីស្នើសុំពីរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។ អភិបាលរងខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យតាម សំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ១.៣.១- សមាសភាព

ខេត្តត្រូវមានគណៈអភិបាលខេត្តដែលរួមមានអភិបាលខេត្ត និងអភិបាលរងខេត្ត ដែលតែង តាំងឡើងស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អភិបាលខេត្ត អភិបាលរងខេត្តមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ[22]។ ជាក់ស្តែងគណៈអភិបាលខេត្តកំពង់ស្ពឺ មានអភិបាលនៃគណៈអភិបាលខេត្តមួយ(១)រូប និងអភិបាលរងខេត្តចំនួនប្រាំមួយ(៦)រូប ជាជំនួយការ

### ១.៣.២- តួនាទី និងភារកិច្ច

គណៈអភិបាលខេត្តមានតួនាទី និងភារកិច្ចចម្បងៗដូចខាងក្រោម[23] ៖

- គណៈអភិបាលខេត្តត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្ត អំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងសិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិ របស់ក្រុមប្រឹក្សាខេត្ត ដើម្បីក្រុមប្រឹក្សាខេត្តធ្វើការពិភាក្សាអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញទាក់ទងនឹង៖
  - ការពិនិត្យមុខងារភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុម ប្រឹក្សាខេត្ត និងអំពីរបៀបរបបបែបបទនីតិវិធីនៃការអនុវត្តមុខងារភារកិច្ច និងការចាត់ ចែងធនធានទាំងនោះ
  - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ

[20] មាត្រា ១៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[21] មាត្រា ១៤០ វាក្យខណ្ឌ ២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[22] មាត្រា ១៤៨ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[23] សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខេត្ត ឆ្នាំ២០១១ ទំព័រ(១៧-២៦)

- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធានដើម្បីទទួលយកមុខងារភារកិច្ច និងធនធានដែលបានប្រគល់ឬបានផ្ទេរស្របតាមច្បាប់ស្ដីពីការគ្រប់-គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងថ្នាក់ឋានន្តរសក្តិ និងការបញ្ឈប់បុគ្គលិក
- ការកំណត់លក្ខណៈសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្សនិងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុម-ប្រឹក្សាខេត្ត
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាល-ខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យ និងអនុម័តមិនឱ្យលើសពី ៩៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ព័ន្ធនឹង៖
  - ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខេត្ត ព្រមទាំងសកម្មភាព និងលទ្ធផលនៃការអនុវត្តដីកា និងសេចក្តីសម្រេចទាំងនោះ
  - របាយការណ៍ហិរញ្ញវត្ថុ
  - ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
  - វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត
  - វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
  - កិច្ចការផ្សេងៗទៀត ដែលក្រុមប្រឹក្សាខេត្តយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។
- របាយការណ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តការងារក្រុមប្រឹក្សាខេត្ត

- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាខេត្តរបស់ខ្លួន

- នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន គណៈអភិបាលខេត្តត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាខេត្ត និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលខេត្តមានតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងខេត្ត។ ចំពោះក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អភិបាលខេត្តមានភារកិច្ចចាំបាច់ ដូចខាងក្រោមៈ

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខេត្តក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត
- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្តឱ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព

និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាខេត្ត

- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុន ក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខេត្ត ក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំង ជាប្រធានមន្ទីរអង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដើម្បីពិនិត្យពិចារណា និងចាត់វិធានការដូចខាងក្រោមៈ
  - ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប
  - ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថាហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្ត ពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្ត ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាពរវាងអភិបាលខេត្ត ជាមួយរដ្ឋមន្ត្រី ឬប្រធាន ស្ថាប័នសាមីទៅលើបេក្ខភាពដែលស្នើតែងតាំងនោះរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនឹងសម្រេច។ អភិបាលខេត្តត្រូវរាយការណ៍ករណីនេះជូនក្រុមប្រឹក្សាខេត្តរបស់ខ្លួន និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់ នៅពេលពិនិត្យឃើញមានភាពមិនប្រក្រតីក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយឬមានការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរអង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយនោះ
- រាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារសាមីក្នុងករណីដែលប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតី ឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ។ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីដោះស្រាយទៅតាមច្បាប់

- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងប្រធានមន្ទីរ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយដែលប្រព្រឹត្តខុសឆ្គងហើយដែលមិនអាចធ្វើយុត្តកម្ម។

**បញ្ជាក់៖**

- ដើម្បីធានាឱ្យអភិបាលខេត្តអនុវត្តនូវតួនាទី និងភារកិច្ចខាងលើនេះ សេចក្ដីរាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្តទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យផ្ដល់យោបល់ជាមុន។ ប្រសិនបើឯកភាពអភិបាលខេត្តត្រូវចុះហត្ថលេខាលើរបាយការណ៍នេះជាមួយប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។
- ចំពោះសេចក្ដីរាយការណ៍ក្រៅពីនោះរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្តត្រូវចម្លងជូនសាលាខេត្ត។

## ១.៤- នាយករដ្ឋបាលសាលាខេត្ត

ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តត្រូវមាននាយករដ្ឋបាលមួយរូប ហៅថានាយករដ្ឋបាលសាលាខេត្ត។ នាយករដ្ឋបាលសាលាខេត្តត្រូវមាននាយករងរដ្ឋបាលពីររូបជាជំនួយការ។

### ១.៤.១- សមាសភាព

នាយករដ្ឋបាលសាលាខេត្តត្រូវមាននាយករងរដ្ឋបាល (០២) រូបជាជំនួយ[24]។ ជាក់ស្ដែងសាលាខេត្តកំពង់ស្ពឺ មាននាយករដ្ឋបាល (០១)រូប និងនាយករងរដ្ឋបាល (០៣)រូប[25] ទៀតជាជំនួយការដើម្បីជួយសម្រួលការងារផ្សេងៗជូននាយករដ្ឋបាលឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

### ១.៤.២- តួនាទី និងភារកិច្ច

នាយករដ្ឋបាលសាលាខេត្តកំពង់ស្ពឺមានតួនាទី និងភារកិច្ចដូចខាងក្រោម[26]៖

- ជាជំនួយការដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងអភិបាលខេត្តក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត។ ក្នុងការអនុវត្តតួនាទីនេះនាយករដ្ឋបាលសាលាខេត្តត្រូវ៖

[24] មាត្រា ៤២ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក

[25] បញ្ជីបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលក្នុងរចនាសម្ព័ន្ធរដ្ឋបាលខេត្តកំពង់ស្ពឺ ឆ្នាំ២០១៧

[26] សៀវភៅណែនាំស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខេត្ត ឆ្នាំ២០១១ ទំព័រ(៤៨-៥១)

- ធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលខេត្ត អភិបាលខេត្ត និងក្រុមប្រឹក្សាខេត្ត
- រៀបចំ និងដាក់ជូនគណៈអភិបាលខេត្ត ពិនិត្យសម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត ផ្អែកតាមក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
- រៀបចំ និងដាក់ជូនគណៈអភិបាលខេត្តនូវវិធានការ និងគោលការណ៍ក្នុងការអនុវត្តដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត
- ធ្វើជាសេនាធិការជូនអភិបាលខេត្ត និងប្រធានក្រុមប្រឹក្សាខេត្តក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាខេត្តរបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលបានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាត្រូវដាក់ជូនគណៈអភិបាលខេត្តដើម្បីពិនិត្យ និងផ្តល់យោបល់ជាមុនលើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាក្នុងការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំកិច្ចការនានា សម្រាប់បម្រើឱ្យកិច្ចការប្រជុំទាំងអស់របស់គណៈអភិបាលខេត្តតាមការណែនាំរបស់អភិបាលខេត្ត
- ធានាក្នុងការទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត និងអភិបាលរងខេត្ត ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា
- ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត និងរដ្ឋបាលរបស់ខ្លួន
- គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលខេត្តឱ្យបានត្រឹមត្រូវ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាខេត្ត គណៈអភិបាល-ខេត្ត ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

- មានសិទ្ធិចូលរួម និងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាខេត្តកិច្ចប្រជុំគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខេត្ត និងកិច្ចប្រជុំអភិបាលខេត្ត ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាខេត្តជាសមាជិកគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សាខេត្ត[27]។
- ក្នុងការចូលរួមក្នុងកិច្ចប្រជុំ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តរបស់ខ្លួនអំពីបញ្ហាច្បាប់ និងបច្ចេកទេសដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្តមានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទ-ដ្ឋានជាតិសម្រាប់សុវត្ថិភាព និងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាខេត្ត[28]។
- ត្រូវធានាឱ្យនាយកទីចាត់ការ មន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារឱ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគិតយុត្ត នីតិវិធីនានា និងការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត និងគណៈកម្មាធិការខេត្តរបស់ខ្លួន។

គណៈអភិបាលខេត្ត ឬអភិបាលខេត្តអាចធ្វើប្រតិកម្មដល់នាយករដ្ឋបាលឱ្យលើកយោបល់លើកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពនៃតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាល-ខេត្ត ឬអភិបាលខេត្តពិនិត្យសម្រេចតាមការចាំបាច់។

### ១.៥- ទីចាត់ការ អង្គភាព និងការិយាល័យចំណុះនៃសាលាខេត្តកំពង់ស្ពឺ

ទីចាត់ការ អង្គភាព ការិយាល័យនីមួយៗនៃសាលាខេត្ត ត្រូវមាននាយកទីចាត់ការមួយ(១)រូបជាប្រធាន និងនាយករងទីចាត់ការយ៉ាងច្រើនចំនួនពីរ(២)រូប ជាជំនួយការ[29]។ នាយកទីចាត់ការនីមួយៗត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល។ ទីចាត់ការនីមួយៗនៃសាលាខេត្តត្រូវ មានការិយាល័យចំណុះមួយចំនួន។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានការិយាល័យមួយ(១)រូប និងអនុប្រធានការិយាល័យយ៉ាងច្រើនពីរ(២)រូប ជាជំនួយការ ជាក់ស្តែងសាលាខេត្តកំពង់ស្ពឺមានទីចាត់ការចំនួនប្រាំ(៥) និងអង្គភាពចំនួនពីរ(២) ដែលចំណុះឱ្យសាលាខេត្តគឺៈ

[27] មាត្រា៤៦ នៃអនុក្រឹត្យលេខ ២១៦
[28] មាត្រា៤៧ នៃអនុក្រឹត្យលេខ ២១៦
[29] មាត្រា៥៧ នៃអនុក្រឹត្យលេខ ២១៦

### ១.៥.១- ទីចាត់ការរដ្ឋបាល

ទីចាត់ការរដ្ឋបាល គឺជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តក្នុងការសហការជាមួយស្ថាប័ន អង្គការជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចខាងក្រោម[30]៖

- ការងារលិខិតស្នាមតម្កល់ឯកសារ និងការធ្វើនីត្យានុកូលកម្មលើឯកសារផ្សេងៗ
- ការគ្រប់គ្រង និងថែរក្សាត្រារបស់រដ្ឋបាលខេត្ត
- ទំនាក់ទំនងជាមួយសាធារណជន ដែលមកទាក់ទងនៅសាលាខេត្ត ការងារព័តមាន ការរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងបិទផ្សាយព័ត៌មានលើក្តារព័ត៌មានសាធារណៈ
- ការគ្រប់គ្រងស្ថិតិ ទិន្នន័យប្រជាពលរដ្ឋ និងការងារអគ្រានុកូលដ្ឋាន
- ការងារពិធីការ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ការគាំទ្រការងារលេខាធិការដ្ឋានដល់ក្រុមប្រឹក្សាខេត្ត។

**ទីចាត់ការរដ្ឋបាលមានការិយាល័យចំណុះ ដូចខាងក្រោម[31]៖**

- **ការិយាល័យរបៀប និងឯកសារ** មានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ច ដូចខាងក្រោម៖
  - ទទួល និងបែងលិខិតចេញ ចូល ទូរស័ព្ទ ទូរសារ
  - ទទួលពិនិត្យសំណើសុំធ្វើនីត្យានុកូលកម្មលើលិខិត និងឯកសារផ្សេងៗ
  - ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែរក្សាត្រា
  - ការងារបណ្ណាល័យ និងតម្កល់ឯកសារ
  - រៀបចំកម្មវិធីការងារប្រចាំសប្តាហ៍របស់គណៈអភិបាលខេត្ត
  - ការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងសាលាខេត្ត។
- **ការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ** មានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ច ដូចខាងក្រោម៖
  - ការចងសម្ព័ន្ធមេត្រីភាពជាមួយទីក្រុង និងខេត្តជាដៃគូ
  - កិច្ចសហការ និងការគាំទ្រពីខេត្ត ក្រុងសម្ព័ន្ធមេត្រីភាព និងពីអង្គការជាតិ អន្តរជាតិ
  - ទំនាក់ទំនង ទទួល និងផ្តល់ព័ត៌មានជូនសាធារណជននានា ដែលមកទាក់ទងការងារនៅសាលាខេត្ត

---

[30] មាត្រា៥៨ ចំណុច(ក) នៃអនុក្រឹត្យលេខ ២១៦

[31] ចំណុច(ខ) សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខេត្ត ២០១១ ទំព័រ(៥៥-៥៨)

- រៀបចំឯកសារសេចក្ដីព្រាងអនុស្សារណៈ ឬកិច្ចព្រមព្រៀងនានារវាងខេត្ត និងខេត្តក្រុងជាដៃគូ និងអង្គការអន្តរជាតិនានា
- ទទួលបន្ទុកការងារពិធីការ និងរៀបចំពិធីបដិសណ្ឋារកិច្ចចំពោះគណៈប្រតិភូភ្ញៀវជាតិអន្តរជាតិដែលបំពេញភារកិច្ចនៅខេត្ត និងសហការរៀបចំពិធីបុណ្យជាតិ ការសម្ពោធសមិទ្ធផល មិទ្ទិញ ឬពិធីនានារបស់ខេត្ត
- តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីកិច្ចសហប្រតិបត្តិការរវាងខេត្តជាមួយខេត្ត ក្រុងជាដៃគូ និងអង្គការអន្តរជាតិនានា។

❖ **ការិយាល័យសរុប និងព័ត៌មាន** មានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ច ដូចខាងក្រោម៖

- ប្រមូលផ្តុំព័ត៌មានអំពីមតិសាធារណៈ និងហេតុការណ៍ផ្សេងៗសម្រាប់ជាមូលដ្ឋានរៀបចំព័ត៌មានជូនក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ដោះស្រាយឱ្យបានទាន់ពេលវេលា
- ប្រមូលផ្តុំព័ត៌មាន និងសភាពការណ៍ទូទៅគ្រប់វិស័យ សេចក្តីរាយការណ៍ពីទីចាត់ការនានាពីក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ក្នុងខេត្តសម្រាប់ជាមូលដ្ឋាន រៀបចំរបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំ និងបិទផ្សាយព័ត៌មានលើក្តារព័ត៌មានសាធារណៈ
- សហការរៀបចំព័ត៌មាន ឬកម្មវិធីនានាសម្រាប់ផ្សព្វផ្សាយតាមស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត
- រៀបចំព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី និងគេហទំព័ររបស់រដ្ឋបាលខេត្ត
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់រដ្ឋបាលខេត្ត
- រៀបចំការប្រជុំ និងកំណត់ហេតុប្រជុំរបស់គណៈអភិបាលខេត្ត។

❖ **ការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន** មានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ច ដូចខាងក្រោម៖

- ជំរឿន និងគ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋក្នុងខេត្ត
- វិភាគ វាយតម្លៃអំពីស្ថានភាពនៃចំណូល និងចំណាកស្រុករបស់ប្រជាពលរដ្ឋក្នុងខេត្ត
- គាំទ្រ តាមដានត្រួតពិនិត្យ ជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន
- ពិនិត្យ និងផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមនីតិវិធីកំណត់
- ស្រាវជ្រាវ វិភាគ វាយតម្លៃអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព សម្រាប់បម្រើឱ្យការងារអត្រានុកូលដ្ឋាន

- ពិនិត្យតាមដាន និងវាយតម្លៃការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយបរទេស
- ផ្សព្វផ្សាយលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការងារស្ថិតិប្រជាពលរដ្ឋ និងអាត្រានុកូដ្ឋាន
- សិក្សា និងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការខាងនយោបាយ និងសម្ភារៈទាក់ទងនឹងការងារអត្រានុកូលដ្ឋាននៅក្នុងខេត្ត។

❖ **ការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត** មានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការរដ្ឋបាលលើភារកិច្ច ដូចខាងក្រោម៖

- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ លិខិតអញ្ជើញប្រជុំ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្ត និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាខេត្ត
- សហការរៀបចំឯកសារតាមរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- ថែរក្សាកំណត់ហេតុប្រជុំ ដីកា សេចក្តីសម្រេច និងឯកសាររបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការ
- រៀបចំប្រជុំកន្លែងប្រជុំក្រុមប្រឹក្សាខេត្ត និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- សហការជាមួយទីចាត់ការ និងការិយាល័យពាក់ព័ន្ធក្នុងសាលាខេត្ត និងបណ្តាផ្សព្វ-ផ្សាយ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់សាធារណជនអំពីការប្រជុំលទ្ធផលនៃការប្រជុំ សេចក្តីសម្រេចនៃអង្គប្រជុំ ព្រមទាំងព័ត៌មានផ្សេងៗទៀតរបស់ក្រុមប្រឹក្សាខេត្ត និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- សហការរៀបចំវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមក្រុង ស្រុកនានាក្នុងខេត្ត និងរៀបចំសេចក្តីរាយការណ៍អំពីវេទិការនេះតាមការកំណត់។

### ១.៥.២- ទីចាត់ការផែនការ និងវិនិយោគ

ទីចាត់ការផែនការ និងវិនិយោគ គឺជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តក្នុងការសហការជាមួយស្ថាប័ន អង្គការជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចខាងក្រោម[32]

- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
- កិច្ចសហការសិក្សាគម្រោង រៀបចំប្លង់ ប៉ានស្មានតម្លៃ និងរៀបចំសំណើគម្រោងសម្រាប់បញ្ចូលក្នុងផែនការអភិវឌ្ឍខេត្ត និងគាំទ្របច្ចេកទេសដល់ក្រុង ស្រុក ឃុំ និងសង្កាត់លើការងារទាំងនេះ
- ការគ្រប់គ្រងកិច្ចសន្យា និងឬអនុវត្តគម្រោងនានា ដែលចុះកិច្ចសន្យាជាមួយរដ្ឋបាលខេត្ត

[32] មាត្រា ៥៨ ចំណុច (ខ) នៃអនុក្រឹត្យលេខ ២១៦

- គាំទ្រធនធានផ្នែករដ្ឋបាល និងសមត្ថភាពផ្នែករដ្ឋបាលដល់ក្រុង ស្រុក ឃុំ និងសង្កាត់
- ការធ្វើសហប្រតិបត្តិការ និងគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍនឹងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក ឃុំ និងសង្កាត់ ព្រមទាំងការគាំទ្រសមត្ថភាពចាំបាច់ដល់ក្រុង ស្រុក ឃុំ និងសង្កាត់ ក្នុងការអនុវត្តគម្រោងនានា
- ការពិនិត្យ និងផ្តល់យោបល់លើសំណើវិនិយោគ និងគម្រោងអភិវឌ្ឍរបស់ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- ការចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធគម្រោងអភិវឌ្ឍនានារបស់ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់។

**ទីចាត់ការផែនការ និងវិនិយោគនៃសាលាខេត្តមានការិយាល័យចំណុះ ដូចខាងក្រោម[33]៖**

❖ **ការិយាល័យផែនការ** ជាសេនាធិការឱ្យនាយកទីចាត់ការផែនការ និងវិនិយោគមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ
  - សហការសម្របសម្រួល និងរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខេត្ត
  - សហការសម្របសម្រួលរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ខេត្ត
  - សហការរៀបចំអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំរបស់ខេត្ត
  - សហការរៀបចំរបាយការណ៍រីកចម្រើនទាក់ទងដល់ការងារផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ខេត្ត
  - ពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់
  - ចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍនានារបស់ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់
  - ទំនាក់ទំនងសហការជាមួយមន្ទីរ អង្គភាព ទាក់ទងនឹងទិន្នន័យ ផែនទី និងសេចក្តីត្រូវការជាអទិភាពរបស់ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់
  - ពិនិត្យ និងលើកអនុសាសន៍ជូនអភិបាលខេត្ត អំពីការធ្វើអនុលោមភាពផែនការអភិវឌ្ឍរបស់ក្រុង ស្រុក ឃុំ និងសង្កាត់
  - សហការសិក្សាគម្រោង រៀបចំប្លង់ ប៉ានស្មានតម្លៃ និងរៀបចំសំណើគម្រោង

[33] ចំណុច(ខ) សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខេត្ត ឆ្នាំ២០១១ ទំព័រ(៦០-៦២)

- គ្រប់គ្រងកិច្ចសន្យា និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យានានាក្នុងកម្មវិធីវិនិយោគរបស់ខេត្ត។

❖ **ការិយាល័យគាំទ្រមូលដ្ឋាន** ជាសេនាធិការឱ្យនាយកទីចាត់ការផែនការ និងវិនិយោគមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួល និងគាំទ្រដល់ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងការកសាង និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
- សម្របសម្រួល និងគាំទ្រថ្នាក់ក្រុង ស្រុក ឃុំ និងសង្កាត់ ក្នុងការអនុវត្តផែនការអភិវឌ្ឍកម្មវិធីវិនិយោគ និងគម្រោងនានាតាមការស្នើសុំ
- គាំទ្រក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងការសិក្សាគម្រោង និងរៀបចំប្លង់ប៉ានស្មានតម្លៃ និងរៀបចំសំណើគម្រោង
- ការងាររៀបចំ និងគ្រប់គ្រងតាមដានត្រួតពិនិត្យ និងបូកសរុបរបាយការណ៍រាល់ការអនុវត្តកិច្ចសន្យាទាំងអស់ដែលបានចុះហត្ថលេខារវាងរដ្ឋបាលខេត្ត និងភ្នាក់ងារអនុវត្ត
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រសមត្ថភាព និងការបំពេញការងាររបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់
- សិក្សា វាយតម្លៃការឆ្លើយតបរបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ចំពោះតម្រូវការរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងការឆ្លើយតបរបស់ក្រុម-ប្រឹក្សាខេត្តចំពោះតម្រូវការរបស់ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក
- គាំទ្រដល់ក្រុង ស្រុកក្នុងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់ឃុំ និងសង្កាត់
- ពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចរបស់ក្រុង និងស្រុក
- សិក្សាស្រាវជ្រាវអំពីការបង្កើត រំសាយ បំបែក បង្រួម និងប្តូរឈ្មោះភូមិ ឃុំ សង្កាត់ ស្រុក និងក្រុងការផ្លាស់ប្តូរទីតាំងសាលាក្រុង ស្រុក ឃុំ និងសង្កាត់ចំណុះសាលាខេត្ត។

❖ **ការិយាល័យវិនិយោគ** ជាសេនាធិការឱ្យនាយកទីចាត់ការផែនការ និងវិនិយោគមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ និងអង្គភាពផ្សេងៗទៀត ដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណើសុំលើកទឹកចិត្តលើការវិនិយោគគ្រប់ប្រភេទក្នុងខេត្ត
- សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ និងអង្គភាពផ្សេងៗទៀតដើម្បីតាមដាន ត្រួតពិនិត្យការអនុវត្តយន្តការលើកទឹកចិត្តលើការវិនិយោគគ្រប់ប្រភេទក្នុងខេត្ត

- សហការក្នុងការសិក្សាអំពីគោលការណ៍ គោលនយោបាយ ដើម្បីជំរុញការវិនិយោគឯកជនក្នុងខេត្ត
- រៀបចំកម្មវិធី ខ្លឹមសារ និងឯកសារលើការងារវិនិយោគ និងទំនាក់ទំនងសហប្រតិបត្តិការជាតិ និងអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើសំណើវិនិយោគ និងគម្រោងអភិវឌ្ឍរបស់ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខេត្ត។

### ១.៥.៣- ទីចាត់ការហិរញ្ញវត្ថុ

ទីចាត់ការហិរញ្ញវត្ថុ គឺជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តក្នុងការសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចជាខាងក្រោម[34]៖

- ការរៀបចំសេចក្តីព្រាងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ការងារហិរញ្ញវត្ថុ ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខេត្ត
- ការរៀបចំឱ្យមានការធ្វើសវនកម្មត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ
- ការគ្រប់គ្រងចំណូល ចំណាយ និងគណនេយ្យ
- ការគាំទ្រដល់ការងារហិរញ្ញវត្ថុ ក្រុង ស្រុក ឃុំ និងសង្កាត់
- ការងារសារពើភណ្ឌ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាលាខេត្ត

**ទីចាត់ការហិរញ្ញវត្ថុនៃសាលាខេត្តមានការិយាល័យចំណុះ ដូចខាងក្រោម[35]៖**

❖ **ការិយាល័យហិរញ្ញកិច្ច** ជាសេនាធិការឱ្យនាយកទីចាត់ការហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត
- សហការរៀបចំនីតិវិធីហិរញ្ញវត្ថុ និងការប្រើប្រាស់ថវិការបស់ខេត្ត
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តនីតិវិធីហិរញ្ញវត្ថុ និងការប្រើប្រាស់ថវិការដ្ឋបាលខេត្ត
- សហការរៀបចំលិខិតបទដ្ឋានតាមគោលការណ៍សម្រាប់ប្រមូលចំណូល
- ចាត់វិធានការជំរុញការប្រមូលចំណូលគ្រប់ប្រភេទសម្រាប់ថវិការបស់រដ្ឋបាលខេត្ត
- រៀបចំអាណត្តិបើកប្រាក់ និងសំណើសុំចំណាយគ្រប់ប្រភេទ

[34] មាត្រា ៥៨ ចំណុច(គ) នៃអនុក្រឹត្យលេខ ២១៦
[35] ចំណុច(ខ) សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខេត្ត ឆ្នាំ២០១១ ទំព័រ(៦៤-៦៥)

- ស្រាវជ្រាវរាល់ប្រភពចំណូលរបស់សាលាខេត្ត
- គាំទ្រដល់ក្រុង ស្រុក ដើម្បីបន្តជួយគាំទ្រដល់ការងាររៀបចំ និងអនុវត្តថវិកាឃុំ សង្កាត់
- ពិនិត្យ និងលើកអនុសាសន៍ជូនអភិបាលខេត្តអំពីការធ្វើអនុលោមភាពថវិកាក្រុង ស្រុក ឃុំ និងសង្កាត់
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុ។

❖ **ការិយាល័យគណនេយ្យ** ជាសេនាធិការឱ្យនាយកទីចាត់ការហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងបេឡាសាច់ប្រាក់ និងគណនេយ្យរបស់រដ្ឋបាលខេត្ត
- ចុះបញ្ជី និងគ្រប់គ្រងប្រាប់ចំណូលគ្រប់ប្រភេទ
- ធ្វើសេចក្តីរាយការណ៍អំពីចំណូល ចំណាយ និងថវិការបស់រដ្ឋបាលខេត្ត
- រៀបចំ និងបើកប្រាក់បៀវត្សរ៍ជូនមន្ត្រី បុគ្គលិកក្នុងសាលាខេត្ត
- ទទួលអាណត្តិបើកប្រាក់ រៀបចំឯកសារដកសាច់ប្រាក់
- ត្រួតពិនិត្យ និងទូទាត់រាល់ការចំណាយ
- គ្រប់គ្រងឃ្លាំងសម្ភារៈ
- សហការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាខេត្ត។

❖ **ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិ** ជាសេនាធិការឱ្យនាយកទីចាត់ការហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យគ្រប់ប្រភេទរបស់រដ្ឋបាលខេត្ត
- ធ្វើសារពើភ័ណ្ឌ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌចលនទ្រព្យ និងអចលនទ្រព្យ
- រៀបចំគោលការណ៍សម្រាប់គ្រប់គ្រង ចាត់ចែងប្រើប្រាក់ចលនទ្រព្យ និងអចលនទ្រព្យ
- រៀបចំឯកសារសម្រាប់ជម្រះបញ្ជីលក់ ជួលវិនិយោគទៅលើទ្រព្យសម្បត្តិនានារបស់ខេត្ត

### ១.៥.៤- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស

ទីចាត់ការគ្រប់គ្រងធនធានមនុស្ស គឺជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ក្នុងការសហការជាមួយស្ថាប័នអង្គភាពជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចខាងក្រោម[36]៖

- ការងារក្របខ័ណ្ឌ និងការគ្រប់គ្រងមន្ត្រីបុគ្គលិកដែលស្ថិតក្នុងសម្ភតកិច្ចរបស់ក្រុមប្រឹក្សាខេត្ត

[36] មាត្រា ៥៨ ចំណុច(យ) នៃអនុក្រឹត្យលេខ ២១៦

- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាព និងបណ្ដុះបណ្ដាលដល់មន្ត្រី បុគ្គលិក
- ផែនការប្រើប្រាស់ ជ្រើសរើសទីប្រឹក្សាបច្ចេកទេស បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលអណ្ដែត
- ការផ្ដល់គ្រឿងឥស្សរិយយស មេដាយ ប័ណ្ណសរសើរដល់មន្ត្រី បុគ្គលិក និងសប្បុរសជន
- ការរៀបចំតួនាទី និងភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យចំណុះសាលាខេត្ត
- ការកំណត់នីតិវិធីរដ្ឋបាលសម្រាប់ទីចាត់ការ និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក
- ការផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីរដ្ឋបាល ដែលពាក់ព័ន្ធនឹងការងារបុគ្គលិក តួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក។

**ទីចាត់ការគ្រប់គ្រងធនធានមនុស្ស មានការិយាល័យចំណុះ ដូចខាងក្រោម[37]៖**

❖ **ការិយាល័យគ្រប់គ្រងបុគ្គលិក** ជាសេនាធិការឱ្យនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖
  - រៀបចំផែនការប្រើប្រាស់ក្របខ័ណ្ឌ និងមន្ត្រី បុគ្គលិករដ្ឋបាលខេត្ត
  - ការងារជ្រើសរើសមន្ត្រី បុគ្គលិក ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខ័ណ្ឌ
  - រៀបចំ និងថែរក្សាសំណុំលិខិតមន្ត្រី បុគ្គលិករដ្ឋបាលខេត្ត
  - រៀបចំតួនាទី ភារកិច្ច និងនីតិវិធិរដ្ឋបាលរបស់ទីចាត់ការ ការិយាល័យនៃសាលាខេត្ត និងតាមដានវាយតម្លៃការអនុវត្ត
  - សិក្សា និងរៀបចំផែនការប្រើប្រាស់ និងជ្រើសរើសទីប្រឹក្សាបច្ចេកទេស មន្ត្រីជាប់កិច្ច-សន្យា និងបុគ្គលិកអណ្ដែត
  - រៀបចំល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក និងតាមដាន វាយតម្លៃការអនុវត្ត
  - ពិនិត្យលើយោបល់លើកសំណើសុំតែងតាំងមុខតំណែង ការផ្លាស់ប្ដូរភារកិច្ច ការផ្លាស់ប្ដូរទីកន្លែងធ្វើការ និងការស្នើសុំច្បាប់ឈប់សម្រាករបស់មន្ត្រី បុគ្គលិក
  - ពិនិត្យ ស្រាវជ្រាវលើកយោបល់លើការដាក់ពិន្ទុ និងមូលវិចារសម្រាប់ដំឡើងឋានន្តរសក្តិ ដំឡើងថ្នាក់ដល់មន្ត្រី បុគ្គលិករដ្ឋបាលខេត្ត

[37] ចំណុច (ខ) សៀវភៅណែនាំស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខេត្ត ឆ្នាំ២០១១ ទំព័រ(៦៧-៧០)

- ពិនិត្យស្រាវជ្រាវ និងលើកយោបល់ក្នុងការដាក់វិន័យ ការដកហូតមុខតំណែង និងការបណ្តេញចេញពីក្របខ័ណ្ឌ
- រៀបចំ និងរក្សាទុកសំណុំលិខិតមន្ត្រី បុគ្គលិក ដែលគ្រប់អាយុចូលនិវត្តន៍ ឈប់សម្រាកលំហែមាតុភាពដាក់ឱ្យនៅក្រៅក្របខ័ណ្ឌដើម ដាក់នៅក្រៅតំណែង ដាក់ឱ្យនៅក្រោមឱវាទដាក់ឱ្យនៅទំនេរគ្មានបៀវត្ស និងផ្ទេរក្របខ័ណ្ឌ
- គាំទ្រដល់ក្រុង ស្រុក លើការងារគ្រប់គ្រងមន្ត្រី បុគ្គលិករបស់ក្រុង ស្រុក ឃុំ និងសង្កាត់
- រៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយស មេដាយ និងប័ណ្ណសរសើរដល់មន្ត្រី បុគ្គលិករដ្ឋបាលខេត្ត និងសប្បុរសជន
- លើកសំណើក្នុងការអនុវត្តគោលនយោបាយដល់មន្ត្រី បុគ្គលិកដែលលាឈប់ពីការងារបាត់បង់សម្បទាវិជ្ជាៈជីវៈ និងទទួលមរណភាព
- រៀបចំសំណើបង្កើត ឬកែសម្រួល ឬរំសាយទីចាត់ការ ឬការិយាល័យនៃសាលាខេត្ត
- ពិនិត្យ និងលើកយោបល់លើកសំណើបង្កើត ឬកែសម្រួល ឬរំសាយការិយាល័យនៃសាលាក្រុង សាលាស្រុក
- ពិនិត្យ និងលើកយោបល់ក្នុងរៀបចំសមាសភាពគណៈកម្មាធិការ អនុគណៈកម្មការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត។

❖ **ការិយាល័យកសាងសមត្ថភាព** ជាសេនាធិការឱ្យនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សមានតួនាទី និងភារកិច្ច ដូចខាងក្រោមៈ

- សិក្សាកំណត់យុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់អភិវឌ្ឍសមត្ថភាពដល់មន្ត្រី បុគ្គលិករបស់រដ្ឋបាលខេត្ត
- វាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល និងរៀបចំកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិករបស់រដ្ឋបាលខេត្ត
- ផ្តល់យោបល់ក្នុងការជ្រើសរើស ចាត់បញ្ជូនមន្ត្រី បុគ្គលិកទៅធ្វើទស្សនកិច្ចដកបទពិសោធន៍ការងារ និងសិក្សារយៈពេលខ្លី និងរយៈពេលវែងក្នុង និងក្រៅប្រទេស
- សហការរៀបចំឯកសារ សម្ភារៈ និងបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិករដ្ឋបាលខេត្ត
- ផ្តល់យោបល់ក្នុងការជ្រើសរើស ចាត់បញ្ជូនមន្ត្រី បុគ្គលិកទៅធ្វើទស្សនកិច្ចដកបទពិសោធន៍ការងារ និងសិក្សារយៈពេលខ្លី និងរយៈពេលវែងក្នុង និងក្រៅប្រទេស
- សហការគាំទ្រការកសាងសមត្ថភាពមន្ត្រី បុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ឃុំ និងសង្កាត់

- ផ្សព្វផ្សាយច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ លិខិតបទដ្ឋាន និតីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ តួនាទី និងភារកិច្ចរបស់ទីចាត់ការ និងការិយាល័យនានា ព្រមទាំងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក។

### ១.៥.៥- ទីចាត់ការអន្តរវិស័យ

ទីចាត់ការអន្តរវិស័យ គឺជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ក្នុងការសហការជាមួយស្ថាប័នអង្គភាពជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចជាខាងក្រោម[38]៖

- កិច្ចសហការសម្របសម្រួល ក្នុងការពិនិត្យមើលឡើងវិញនូវមុខងារធនធាន និងការទទួលខុសត្រូវដើម្បីផ្ទេរមកឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក និងសង្កាត់
- កិច្ចសហការសម្របសម្រួលក្នុងការប្រគល់ និងការធ្វើប្រតិភូកម្មមុខងារ និងធនធានដល់ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់នៅក្នុងខេត្ត
- កិច្ចសហការសម្របសម្រួលអនុវត្តមុខងារ និងភារកិច្ចនានាដែលទាក់ទងនឹងការងារសេដ្ឋកិច្ច ការលើកកម្ពស់សុខុមាភាពសង្គម ការងារពាក់ព័ន្ធដីធ្លី ផែនការរៀបចំដែនដីខេត្ត ការងារបរិស្ថាន ធនធានធម្មជាតិ ឧទ្យាន ការគ្រប់គ្រងកាកសំណល់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ដឹកជញ្ជូន ព្រមទាំងផ្តល់សេវាសាធារណៈនានាលើកលែងតែមុខងារ និងភារកិច្ចទាំងឡាយណាដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃសាលាខេត្ត
- ការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់ និងការអនុវត្តច្បាប់
- ការលើកកម្ពស់យល់ដឹងអំពីសិទ្ធមនុស្សការគោរពសិទ្ធមនុស្ស និងយេនឌ័រ
- ការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខេត្ត និងដោះស្រាយវិវាទនៅមូលដ្ឋាន
- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការលើកកម្ពស់សុវត្ថិភាពសង្គម។

**ទីចាត់ការអន្តរវិស័យនៃសាលាខេត្តមានការិយាល័យចំណុះដូចខាងក្រោម[39]៖**

❖ **ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច** ធ្វើជាសេនាធិការឱ្យនាយកទីចាត់ការអន្តរវិស័យមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

  - គ្រប់គ្រងស្ថិតិអំពីមូលដ្ឋានអាជីវកម្ម និងផលិតកម្មគ្រប់ប្រភេទនៅក្នុងខេត្ត
  - សិក្សាលើកយោបល់អំពីការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងការប្រកបមុខរបរក្នុងខេត្ត

[38] មាត្រា ៥៨ ចំណុច(ង) នៃអនុក្រឹត្យលេខ ២១៦

[39] ចំណុច (ខ) សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលខេត្ត ឆ្នាំ២០១១ ទំព័រ(៧១-៧៨)

- សហការអនុវត្តការងារតាមដាន វាយតម្លៃអំពីការធ្វើអាជីវកម្ម ផលិតកម្មគ្រប់ប្រភេទ នៅក្នុងខេត្តជាមួយមន្ទីរជំនាញ និងអង្គភាពនានាតាមការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័ន
- កំណត់គោលការណ៍អំពីការគ្រប់គ្រងទីផ្សារ និងសត្តឃាតដ្ឋាន
- សហការសម្របសម្រួល ក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ ការទទួលខុសត្រូវ និងធនធាន ដើម្បីធ្វើការផ្ទេរមករដ្ឋបាលខេត្ត
- សហការសម្រលសម្រួលក្នុងការពិនិត្យមុខងារ ការទទួលខុសត្រូវ និងធនធាន ដើម្បីផ្ទេរទៅឱ្យក្រុង ស្រុក ឃុំ និងសង្កាត់
- សហការសម្របសម្រួលដើម្បីលើកកម្ពស់ការផ្តល់សេវាអប់រំ សុខាភិបាល និងអនាម័យក្នុងខេត្ត
- សហការអប់រំផ្សព្វផ្សាយអំពីវិធីបង្ការជម្ងឺ សេវាសុខភាពសាធារណៈ
- ចាត់វិធានការការពារទ្រព្យសម្បត្តិសាធារណៈ ថែរក្សាសម្បត្តិវប្បធម៌ និងបេតិកភណ្ឌជាតិ ធនធានធម្មជាតិ និងបរិស្ថាន
- សហការសម្របសម្រួល ដើម្បីដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធដល់ការជួយសង្គ្រោះជនទីទ័លក្រ និវត្តន៍ជន ជនពិការ កុមារកំព្រា ជនអនាថា ជនគ្មានទីពឹង
- វិធានការបង្ការគ្រោះធម្មជាតិ គ្រោះថ្នាក់សង្គម និងការជួយសង្គ្រោះ
- ដោះស្រាយបញ្ហាពលកម្មការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- លើកកម្ពស់សុខុមាលភាពដល់ស្ត្រី និងកុមារ
- បញ្ជ្រាបការយល់ដឹងអំពីសមភាពយេនឌ័រក្នុងការគ្រប់សកម្មភាពសង្គម
- សម្របសម្រួលអន្តរវិស័យ ដើម្បីជំរុញលើកកម្ពស់ការបង្កើតបរិស្ថានល្អសម្រាប់ធ្វើសកម្មភាពសេដ្ឋកិច្ចគ្រប់ប្រភេទសំដៅជំរុញឱ្យមានការវិនិយោគ និងការអភិវឌ្ឍវិស័យឯកជននៅខេត្ត។

❖ **ការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់** ជាសេនាធិការឱ្យនាយកទីចាត់ការអន្តរវិស័យមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សហការរៀបចំផែនការរៀបចំដែនដីខេត្ត
- ពិនិត្យ និងផ្តល់យោបល់លើគម្រោងអភិវឌ្ឍនានា ដើម្បីឱ្យស្របតាមផែនការរៀបចំដែនដីខេត្ត
- ការងារពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី
- ពិនិត្យ និងផ្តល់យោបល់លើបទល្មើស នៃការសាងសង់សំណង់នានា

- តាមដានវាយតម្លៃ និងធ្វើរបាយការណ៍អំពីការអនុវត្តផែនការផែនការរៀបចំដែនដី-ខេត្ត និងប្លង់សំណង់
- កំណត់គោលការណ៍គ្រប់គ្រងសំណង់ចាស់ និងបេតិកភ័ណ្ឌក្នុងខេត្ត
- សហការកំណត់អំពីគោលការណ៍ក្នុងការអភិវឌ្ឍ និងថែទាំជួលជុលហេដ្ឋារចនាសម្ព័ន្ធដឹងជញ្ជូនក្នុងខេត្ត
- ការតាំងលំនៅថ្មី ការរក្សាសណ្តាប់ធ្នាប់ នគរូបនីយកម្ម និងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។

❖ **ការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ** ជាសេនាធិការឱ្យនាយកទីចាត់ការអន្តរវិស័យមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំកម្មវិធីការងារប្រចាំសប្តាហ៍របស់គណៈអភិបាលខេត្ត
- កំណត់គោលការណ៍ និងវិធានការអំពីការប្រើប្រាស់យានយន្ត និងមធ្យោបាយធ្វើដំណើរផ្សេងទៀតក្នុងខេត្ត និងសម្របសម្រួលតម្រង់ទិសការអនុវត្ត
- កំណត់គោលការណ៍ វិធានការអំពីសុវត្ថិភាពចរាចរណ៍ និងសម្របសម្រួលការអនុវត្ត
- គ្រប់គ្រងប្រព័ន្ធចរាចរណ៍ និងមធ្យោបាយដឹងជញ្ជូនគ្រប់ប្រភេទក្នុងខេត្ត
- កំណត់គោលការណ៍ និងវិធានការទប់ស្កាត់ និងប្រឆាំងឧក្រិដ្ឋកម្ម និងបទល្មើសនានាព្រមទាំងរក្សាសុវត្ថិភាពក្នុងខេត្ត
- សហការស្រាវជ្រាវអំពីអ្នកញៀនគ្រឿងញៀន និងការរៀបចំគោលនយោបាយនានាស្តីពីការទប់ស្កាត់ និងប្រឆាំងគ្រឿងញៀន
- គ្រប់គ្រងដំណើរមជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនផ្សេងៗទៀត
- អំពីការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- ទទួលពិនិត្យ និងលើកយោបល់អំពីការដោះស្រាយវិវាទនានានៅក្នុងមូលដ្ឋាន
- ទទួលពិនិត្យ និងលើកយោបល់ចំពោះពាក្យបណ្តឹងនានារបស់ប្រជាពលរដ្ឋលើការងាររដ្ឋបាលនានាក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាននានា និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការយល់ដឹងអំពីច្បាប់ និងការអនុវត្តច្បាប់
- អប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និងការគោរពសិទ្ធិមនុស្ស
- ចូលរួមក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត និងសហការតាមដានការអនុវត្តការសម្រេច នៃកិច្ចប្រជុំនេះ។

### ១.៥.៦- អង្គភាពលទ្ធកម្ម

អង្គភាពលទ្ធកម្ម គឺជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម ក្នុងការសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗដូចជាខាងក្រោម[40]៖

- រៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីកិច្ចលទ្ធកម្មនីមួយៗ
- លក់ ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម
- ទទួលសំណើរដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំទុកដាក់សំណើដេញថ្លៃដែលបានទទួលឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងត្រូវគ្រប់គ្រងឯកសារ ឬលិខិតស្នាមពាក់ព័ន្ធទាំងអស់មុនពេលបើកសំណើដេញថ្លៃ
- រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ ដោយមានការដឹកនាំត្រួតពិនិត្យពីគណៈកម្មាធិការលទ្ធកម្មរបស់ខេត្ត
- ចាត់ចែងរៀបចំទីកន្លែងសម្រាប់បើកសំណើដេញថ្លៃ
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្តីពីការបើកសំណើរដេញថ្លៃ
- ជួយសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ
- ផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ធ្វើសេចក្តីព្រាងកិច្ចសន្យាឱ្យសមស្របតាមបទដ្ឋានឯកសារកិច្ចសន្យាដែលបានកំណត់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងៗទៀត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ

[40] ប្រការ ១៦ ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣

### ១.៥.៧- អង្គភាពច្រកចេញចូលតែមួយ

អង្គភាពច្រកចេញចូលតែមួយ មានតួនាទីផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត តាមនីតិវិធីសាមញ្ញ ប្រកបដោយមនសិការវិជ្ជាជីវៈ តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាន។ អង្គភាពច្រកចេញចូលតែមួយ ក៏ជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ក្នុងការសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យទាក់ទងនឹងកិច្ចការសំខាន់ៗថ្នាក់ខេត្ត ដូចខាងក្រោម[41]៖

- ទទួលពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារស្នើសុំសេវារដ្ឋបាលរបស់ប្រជាពលរដ្ឋ ព្រមទាំងផ្តល់លទ្ធផលសម្រេចជាផ្លូវការ
- លើកយោបល់លើការរៀបចំទម្រង់បែបបទ នីតិវិធីលម្អិត និងក្របខ័ណ្ឌពេលវេលាសម្រាប់ផ្តល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រមូល ចងក្រងទិន្នន័យអាជីវកម្ម សិប្បកម្ម សេវាកម្ម និងទិន្នន័យពាក់ព័ន្ធ ដើម្បីរៀបចំបញ្ជីសេវារដ្ឋបាលតាមវិស័យនីមួយៗ និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំនូវបញ្ជីសេវារដ្ឋបាលទាំងនេះដោយសហការជាមួយមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ
- ផ្សព្វផ្សាយ និងផ្តល់ព័ត៌មាននានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ
- រៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន វេទិការប្រចាំឆមាស និងវេទិការប្រចាំឆ្នាំស្តីពីការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ
- សម្របសម្រួល ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយ
- សហការ សម្របសម្រួល និងធ្វើទំនាក់ទំនងជាមួយមន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានាក្នុងការផ្សព្វផ្សាយ ជំរុញការផ្តល់សេវា ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តការផ្តល់សេវារដ្ឋបាល
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់អង្គភាពច្រកចេញចូលតែមួយ
- រៀបចំរបាយការណ៍ជាទៀតទាត់តាមគោលការណ៍កំណត់។

**អង្គភាពច្រកចេញចូលតែមួយនៃសាលាខេត្តត្រូវបានរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ[42]៖**

---

[41] ប្រការ ៧ ប្រកាសលេខ ៣៨៧១ ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

[42] ប្រការ៦ លេខ៣៨៧១ ប្រក នៃប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

❖ **ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួល ប្រគល់ពាក្យស្នើសុំ បង់ប្រាក់កម្រៃសេវា និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាល។ ផ្នែកជួរមុខរៀបចំឱ្យមានបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន បុគ្គលិកទទួលបន្ទុកទទួលប្រគល់ឯកសារ និងបុគ្គលិកទទួលបន្ទុកការងារបេឡា ផ្នែកជួរមុខ មានតួនាទី និងភារកិច្ចដូចខាងក្រោម[43]៖

- ផ្តល់ព័ត៌មានអំពីប្រភេទ តម្លៃ រយៈពេល និងសុពលភាពនៃសេវារដ្ឋបាល អំពីគោល-ការណ៍ បែបបទ នឹងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល ព្រមទាំងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ផ្តល់ពាក្យស្នើសុំ និងទម្រង់បែបបទភ្ជាប់នានាជូនប្រជាពលរដ្ឋដើម្បីបំពេញ
- ទទួល និងពិនិត្យពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ជូនប្រជាពលរដ្ឋអំពីភាពត្រឹមត្រូវ ឬចំណុចខ្វះខាតនៃពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់តាមលក្ខខណ្ឌកំណត់
- ទទួល និងពិនិត្យលើឯកសារថតចម្លងនានាតាមការកំណត់
- ចេញបង្កាន់ដៃទទួលពាក្យស្នើសុំ ដែលកត់ត្រាអំពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំ និងកំណត់កាលបរិច្ឆេទដែលត្រូវមកទទួលយកលទ្ធផលសម្រេចជាផ្លូវការ
- ទទួលប្រាក់កម្រៃសេវាពីប្រជាពលរដ្ឋ ព្រមទាំងចេញបង្កាន់ដៃបង់ប្រាក់ទៅតាមតម្លៃសេវា និងគោលការណ៍ដែលបានកំណត់
- បញ្ជូនពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ជូនប្រធានអង្គភាពច្រកចេញចូលតែដើម្បីចាត់ចែងបញ្ជូនទៅផ្នែកជួយក្រោយតាមវិស័យជំនាញនីមួយៗ
- ផ្តល់លទ្ធផលសម្រេចជាផ្លូវការជូនប្រជាពលរដ្ឋ
- ទុកដាក់ ថែរក្សា និងធានាសុវត្ថិភាពសាច់ប្រាក់ដែលទទួលបានពីការផ្តល់សេវាតាមគោលការណ៍ និងនីតិវិធីកំណត់
- បង់ចំណូលដែលទទួលបានពីការផ្តល់សេវារដ្ឋបាលទៅតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់
- រៀបចំរបាយការណ៍អំពីចំនួនសេវា និងចំណូលជាទៀងទាត់តាមគោលការណ៍កំណត់។

❖ **ផ្នែកជួរក្រោយ** គឺជាកន្លែងពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំបែបបទនៃការស្នើសុំសេវារដ្ឋបាល។ ផ្នែកជួរក្រោយរួមមានបុគ្គលិកជំនាញបច្ចេកទេសតាមវិស័យ

[43] ប្រការ ៨ ប្រកាសលេខ ៣៨៧១ ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

នីមួយៗ ដែលត្រូវបានចាត់តាំងឱ្យមកបំពេញការងារនៅក្នុងអង្គភាពចេញចូលតែមួយខេត្ត និងបុគ្គលិកជំនាញបច្ចេកទេសដែលត្រូវបានចាត់តាំងនៅតាមមន្ទីរ អង្គភាពសាមីនីមួយៗដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើការផ្តល់សេវារដ្ឋបាល ព្រមទាំងបុគ្គលិកនៃទីចាត់ការ ឬអង្គភាពពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលខេត្ត។ ផ្នែកជួរក្រោយ មានតួនាទី និងភារកិច្ចដូចខាងក្រោម[44]៖

- ពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំឯកសារស្នើសុំសេវារដ្ឋបាលដើម្បីដាក់ជូនអភិបាលពិនិត្យ និងសម្រេច
- ចុះសិក្សា ឬអង្កេតដល់ទីតាំងអាជីវកម្ម សិប្បកម្ម ឬសេវាកម្មរបស់អ្នកស្នើសុំសេវាស្របតាមគោលការណ៍កំណត់
- ផលិតអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត្ត ឬលិខិតឆ្លើយចំពោះការស្នើសុំសេវារដ្ឋបាល
- ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តតាមលិខិតអនុញ្ញាត្ត ឬអាជ្ញាប័ណ្ណ
- ចុះស្រង់ទិន្នន័យអាជីវកម្ម សិប្បកម្ម សេវាកម្ម និងទិន្នន័យពាក់ព័ន្ធដើម្បីចងក្រងបញ្ជីសេវារដ្ឋបាល និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវារដ្ឋបាលនេះជារៀងរាល់ឆ្នាំ
- ទុកដាក់ និងថែរក្សាសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងឯកសារទិន្នន័យពាក់ព័ន្ធនានាតាមការកំណត់
- រៀបចំរបាយការណ៍តាមគោលការណ៍កំណត់ និងតាមការណែនាំពីប្រធានអង្គភាពច្រកចេញចូលតែមួយ ឬប្រធានមន្ទីរ អង្គភាពសាមី។

ក្រៅពីភារកិច្ចដូចមានចែងខាងលើនេះ ទីចាត់ការ និងអង្គភាពនីមួយៗអាចបំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីគណៈអភិបាលខេត្ត។ ទីចាត់ការ អង្គភាព និងការិយាល័យនីមួយៗត្រូវបំពេញកិច្ចការដោយផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាជាធរមាន។

[44] ប្រការ ៩ ប្រកាសលេខ ៣៨៧១ ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

# ជំពូកទី ២

# ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តការងាររបស់ខេត្តកំពង់ស្ពឺ

# ជំពូកទី ២
# ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តការងាររបស់ខេត្តកំពង់ស្ពឺ

## ២.១- ស្ថានភាពទូទៅនៃខេត្តកំពង់ស្ពឺ

កំពង់ស្ពឺ គឺជាខេត្តមួយក្នុងចំណោម ២៥ រាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ហើយមានចម្ងាយ៤៨គីឡូម៉ែត្រ ខាងលិចរាជធានីភ្នំពេញ ដែលមានសណ្ឋានជាខ្ពស់រាបកណ្តាល និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកណ្តាល និងតាកែវ ខាងត្បូងជាប់នឹងខេត្តតាកែវ និងខេត្តកំពត ខាងលិចជាប់នឹងខេត្តព្រះសីហនុ ខាងជើងជាប់នឹងខេត្តកំពង់ឆ្នាំង និងខេត្តពោធិសាត់។

ខេត្តកំពង់ស្ពឺចែកជា៧ស្រុក ក្រុង១ និងមាន៨២ឃុំ និង៥សង្កាត់។ ភូមិមានចំនួន១.៣៨០ ក្នុងនោះភូមិមានក្របខ័ណ្ឌចំនួន ១.៣៤២ភូមិ និងភូមិអត់ក្របខ័ណ្ឌចំនួន ៣៨ភូមិ។ មានប្រជាពលរដ្ឋសរុបចំនួន៨១២.២៩០នាក់ មានស្រីចំនួន ៤១៥.៤៣៨នាក់ ក្នុងនោះមានអាយុ ១៨ឆ្នាំឡើងទៅមានចំនួន ៤៨៨.២៧៧នាក់ ស្រី ២៥៤.៩៩៧៨នាក់ និងមានគ្រួសារចំនួន ១៦១.១៦២គ្រួសារ ទំហំគ្រួសារជាមធ្យម ៦នាក់ និងមានដង់ស៊ីតេប្រជាពលរដ្ឋ ១១៦នាក់/១គម$^{២}$ ។

ខេត្តមានផ្ទៃដីសរុប ៦៩៦.៥៦ហាត ក្នុងនោះដីស្រែមានចំនួន ១១៣.៦០០ហាត ដីចំការចំនួន ៤៨.២៨៨ហាត (ក្នុងនោះដំណាំកសិឧស្សាហកម្ម៨.០៨៦ហាត) ដីលំនៅដ្ឋាន ១១.៩៩៦ហាត ដីព្រៃភ្នំ និងដីសំណង់ធារាសាស្ត្រ ៥២២.៦៧៩ហាត។ ផ្ទៃដីរបស់ខេត្តប៉ែកខាងលិចគ្របដណ្តប់ដោយជួរភ្នំក្រវ៉ាញ ជាហេតុធ្វើខ្យល់ទឹកភ្លៀងប៉ុន្តែខេត្តអាចជៀសផុតបានយ៉ាងងាយពីការប៉ះទង្គិចដោយសារខ្យល់ព្យុះប៉ែកខាងជើងគ្របដណ្តប់ដោយតំបន់ទំនាបសម្បូរទៅដោយដីមានជីជាតិដែលបង្កលក្ខណៈងាយស្រួលក្នុងការបង្កបង្កើនផលកសិកម្ម។

## ២.២- ស្ថានភាពភូមិសាស្ត្រ

❖ ស្រុកសំរោងទង និងក្រុងច្បារមន ស្ថិតនៅតំបន់កណ្តាលនៃខេត្ត ហើយប្រជាជនមួយចំនួនប្រកបរបរលក់ដូ មួយចំនួនទៀតជាមន្ត្រីរាជការ និងប្របករបរផ្សេងៗទៀត។ ស្រុក ក្រុងទាំងពីរនេះជាទីតាំងមួយដ៏សំខាន់ដែលមានសក្តានុពលខាងវិស័យកាត់ដេ សហគ្រាសធុនតូច មធ្យម សប្បិកម្ម និងអាជីវកម្មខ្នាតតូចធំផ្សេងៗទៀតជាច្រើនផងដែរ។

❖ ស្រុកឱរ៉ាល់ ស្រុកថ្ពង និងស្រុកភ្នំស្រួច មានផ្ទៃដីមួយភាពធំគ្របដណ្តប់ដោយព្រៃឈើ និងមានជួរភ្នំរាយប៉ាយ ហើយក៏ជាតំបន់ដែលមានដីសម្បូរជីជាតិល្អសម្រាប់ការប្រកបរបរកសិកម្ម អាជីវកម្មថ្មរ៉ែក្រោមដីការដេកយកអនុផលព្រៃឈើ និងជាតំបន់ដែលមានសក្តានុពលខាងវិស័យកសិឧស្សាហកម្ម (ដូងប្រេង ពោត អំពៅ) និងកសិដ្ឋានចិញ្ចឹមសត្វផងដែរ។

❖ ស្រុកបរសេដ្ឋ ស្រុកគងពិសី និងស្រុកឧដុង្គ មានប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្មដាំដំណាំរួមផ្សំ ព្រោះស្រុកទាំងនេះមានទីតាំងជាតំបន់ទំនាប និងមានជួរភ្នំព័ទ្ធជុំវិញ។ ស្រុកទាំងនេះ សម្បូរទៅដោយដើមត្នោត ពិសេសស្រុកឧដុង្គ ដែលបច្ចុប្បន្ននេះការផលិតស្ករត្នោតត្រូវបានគេកែច្នៃជាម្សៅ ហើយធ្វើការនាំចេញទៅក្រៅប្រទេស និងបម្រើទីផ្សារក្នុងស្រុកដោយតម្លៃខ្ពស់។

## ២.៣- ការរៀបចំផែនការអភិវឌ្ឍរបស់ខេត្តកំពង់ស្ពឺ

### ២.៣.១- ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍

ដើម្បីជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សន៍កម្ពុជាក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ខេត្តកំពង់ស្ពឺត្រូវមានចក្ខុវិស័យអភិវឌ្ឍន៍រួមមួយរបស់ខ្លួនឱ្យបានច្បាស់លាស់គឺ " **លើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋឱ្យបានធូរធារប្រកបដោយសមធម៌ និងសោភ័ភាពស្រស់បំព្រង ដើម្បីជំរុញឱ្យមានសន្តិសុខស្បៀង សុខមាលភាព សមភាពយេនឌ័រ ចំណេះដឹង និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ តាមរយៈកំណែទម្រង់លើគ្រប់វិស័យដោយប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិតេយ្យ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សឆ្ពោះទៅកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងតម្លាភាព**" ។ ដើម្បីសម្រេចឱ្យបានក្នុងចក្ខុវិស័យអភិវឌ្ឍន៍របស់ខ្លួន ខេត្តក៏ត្រូវបង្កើតនូវគោលដៅអភិវឌ្ឍន៍តាមផ្នែកសំខាន់ៗដូចខាងក្រោម៖

### ២.៣.២- គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច

គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច បានកំណត់ឡើងក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ចឆ្ពោះទៅកាន់វឌ្ឍនភាព ដោយផ្អែកលើមូលដ្ឋានបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងខេត្ត តាមវិស័យនីមួយៗតាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម ការធ្វើពិពិធកម្ម កសិកម្ម ការកែឆ្នៃកសិផល ការលើកម្ពស់កំណែទម្រង់ដីធ្លី ការពង្រីក និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងអរូបវ័ន្តជនបទ ការកសាងផ្លូវថ្នល់ ការរៀបចំប្រព័ន្ធធារាសាស្ត្រ ការតបណ្តាញអគ្គីសនី ការតបណ្តាញទឹកស្អាត ការអភិវឌ្ឍជនបទ ព្រមទាំងការផ្តល់សេវាឥណទាន និងការពង្រីកទីផ្សារសេដ្ឋកិច្ច។ល។ គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចត្រូវបានកំណត់ដូចខាងក្រោម៖

- នៅឆ្នាំ២០១៨ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងទទួលបានការសាងសង់ និជួលជុលទំនប់ទឹក ការស្តារប្រឡាយស្រោចស្រព ប្រព័ន្ធរំដោះទឹក និងប្រព័ន្ធស្រោចស្រពខ្នាតតូចដើម្បីប្រើប្រាស់ប្រចាំថ្ងៃ និងពង្រីកផ្ទៃដីស្រោចស្រពដាំដុះ

- នៅឆ្នាំ២០១៨ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងមានជីវភាពល្អប្រសើរ មានចំណូលប្រចាំឆ្នាំកើនឡើងតាមរយៈលើកកម្ពស់ផលិតភាពកសិកម្ម និងការធ្វើពិពិធកម្មកសិកម្ម
- នៅឆ្នាំ២០១៨ ប្រជាពលរដ្ឋនឹងមានផ្លូវល្អប្រើប្រាស់កាន់តែប្រសើរ និងងាយស្រួលធ្វើដំណើរទៅមក ទាំងនៅជនបទ និងទីប្រជុំជន
- នៅឆ្នាំ២០១៨ ប្រជាពលរដ្ឋនឹងមានទឹកស្អាត និងផ្លូវលំជនបទប្រើប្រាស់ និងរស់នៅប្រកបដោយសុខុមាលភាព
- ការវិនិយោគផ្នែកវិស័យឯកជនទៅលើរោងចក្រសហគ្រាសនឹងបង្កើតឱ្យបាន ១៥កន្លែង និងពង្រីកមុខរបរអាជីវកម្ម និងជំរុញសហគ្រាសធន់តូច និងមធ្យមឱ្យកាន់តែប្រសើរ
- ទេសចរណ៍សហគមន៍នឹងត្រូវបានពងង្រឹង ពង្រីក និងអភិរក្សនៅតាមតំបន់សក្តានុពល។

**២.៣.៣- គោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច**

ការចូលរួមលើកស្ទួយអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច ក្នុងការជំរុញកិច្ចអភិវឌ្ឍន៍ជាកិច្ចការមួយសំខាន់របស់ខេត្តទាំងមូលតាមរយៈការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការពង្រឹង និងកែលម្អវិស័យព្រះពុទ្ធសាសនា និងកិច្ចការធម្មការ ការកាត់បន្ថយចលនាចំណាកស្រុក។ គោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ចត្រូវបានកំណត់ដូចខាងក្រោមៈ

- នៅឆ្នាំ២០១៨ សិស្សានុសិស្សទាំងពីរភេទនឹងទទួលបានសេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅគ្រប់កម្រិតសិក្សា រួមទាំងប្រជាពលរដ្ឋដែលមិនចេះអក្សរ នឹងទទួលបានអប់រំក្រៅប្រព័ន្ធដ៏មានប្រសិទ្ធភាពខ្ពស់
- នៅឆ្នាំ២០១៨ សុខុមាលភាពរបស់ប្រជាពលរដ្ឋនឹងត្រូវបានលើកម្ពស់
- នៅឆ្នាំ២០១៨ សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនឹងត្រូវបានការលើកកម្ពស់
- នៅឆ្នាំ២០១៨ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ ការពង្រឹងសមត្ថភាពទាំងជំនាញ និងចំណេះដឹងដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធលើគ្រប់វិស័យ នឹងត្រូវបានលើកតម្កើង។

**២.៣.៤- គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

ការប្រើប្រាស់ដ៏មាននិរន្តភាព នៃធនធានធម្មជាតិទាំងឡាយ គឺជាកត្តាដ៏សំខាន់បំផុតមួយសម្រាប់ការអភិវឌ្ឍនៅក្នុងខេត្ត។ ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍នៃការគ្រប់គ្រងដីធ្លី ដោយជំរុញ និងការបង្កើតឱ្យមានការចុះបញ្ជីដីធ្លី រួមនឹងកាត់បន្ថយវិវាទដីធ្លី និងការអប់រំឱ្យប្រជាពលរដ្ឋ

យល់ដឹងពីការថែទាំធនធានធម្មជាតិ និងបរិស្ថាន ហើយត្រូវចាត់វិធានការរាល់ការសាងសង់សំណង់ដែលគ្មានការអនុញ្ញាត្ត។ គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយត្រូវបានកំណត់ដូចខាងក្រោម៖

- នៅឆ្នាំ២០១៨ ការចុះបញ្ជីដីធ្លីនឹងត្រូវបានបង្កើនរួម និងវិវាទដីធ្លីនឹងត្រូវបានកាត់បន្ថយ
- នៅឆ្នាំ២០១៨ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងយល់ដឹងបន្ថែមពីការថែក្សាគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
- នៅឆ្នាំ២០១៨ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងយល់ដឹងបន្ថែមពីការការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រប់គ្រងគ្រោះមហន្តរាយ និងកាត់បន្ថយបាននូវគ្រោះថ្នាក់នានា ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងគ្រប់គ្រង គ្រោះមហន្តរាយ។

### ២.៣.៥- គោលដៅអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការចាត់តាំងអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាលសំដៅលើកស្ទួយការផ្តល់សេវាសាធារណៈ ឱ្យកាន់តែល្អប្រសើរឡើងឆ្លើយតបទៅនឹងបំណងរបស់ប្រជាពលរដ្ឋ និងការពង្រឹងប្រព័ន្ធច្បាប់ដើម្បីលើកកម្ពស់ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ រដ្ឋបាលខេត្តមានគោលដៅអភិវឌ្ឍន៍ដូចខាងក្រោម៖

- នៅឆ្នាំ២០១៨ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងទទួលបានសេវាសាធារណៈកាន់តែល្អប្រសើរ
- នៅឆ្នាំ២០១៨ ការងារគ្រប់គ្រងស្ថិតិលើការរៀបចំកិច្ចការចុះអត្រានុកូលដ្ឋាន និងការធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ នឹងមានភាពល្អប្រសើរឡើង
- នៅឆ្នាំ២០១៨ បញ្ហាសុវត្ថិភាព ស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់ និងកង្វះខាតលើការគ្រប់គ្រងស្ថិតិ នឹងត្រូវបានកាត់បន្ថយជាអតិប្បរមា។

## ២.៤- ចំណុចខ្លាំងក្នុងការអនុវត្តការងារ

### ២.៤.១- ការងារគ្រប់គ្រងរាស្ត្រប្រជា

ប្រជាពលរដ្ឋបានចុះបញ្ជីស្នាក់នៅចំនួន ១៧៩.៦៤៧គ្រួសារ គ្រួសារអចិន្ត្រៃយ៍ ១៧៧.៤០៣គ្រួសារ គ្រួសារស្នាក់នៅបណ្តោះអាសន្នចំនួន ២.២៤៤គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ៨៥០.៤៧២នាក់ ប្រជាពលរដ្ឋជាស្ត្រី ៤៣៣.៧២០នាក់ ប្រជាពលរដ្ឋចំណាកស្រុក ៨.១៩០នាក់ ប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើងចំនួន ៥៣៥.៩២៧នាក់ ភាគច្រើនមានមុខរបបជាអ្នកលក់ដូរ កម្មកររោងចក្រ កម្មករសំណង់។ ការចុះបញ្ជីអាត្រានុកូលដ្ឋានគ្រប់ប្រភេទរួមមាន៖ សំបុត្រកំណើតចំនួន ១.៦៩៥នាក់ ស្រី ៩៥៧នាក់ សេចក្តីសម្លងសំបុត្របញ្ជាក់កំណើតចំនួន ៦.៩៨៩សន្លឹក ចុះបញ្ជីអាពាហ៍ពិពាហ៍

ចំនួន ២១៥គូ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចំនួន ៧៣សន្លឹក ចុះបញ្ជីមរណភាពចំនួន ៣៧៨នាក់ ស្រី ១៧៤នាក់[45] ។

### ២.៤.២- ការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ច

#### ២.៤.២.១- ការងារសេដ្ឋកិច្ច

❖ **ការងារកសិកម្ម**

**ស្រូវ និងដំណាំរដូវវស្សា៖** រដូវវស្សាផែនការសរុប ១៣៣ ៦០០ហ.ត ក្នុងនោះអនុវត្តបាន ចំនួន ១១៣ ៧១១ហ.ត ស្មើនឹង ១០០,១០% ទាបជាងឆ្នាំ២០១៦ ចំនួន ១៧២៩ហ.ត ក្នុងនោះៈ ស្រូវពង្រោះចំនួន ៥៩២៥៤ហ.ត ស្មើនឹង ៥២,១០% ដាំស្រូវចំការចំនួន ១២០ហ.ត។ ការងារប្រមូលផលស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ សម្រេចបាន ២១៨៦៤ហ.ត ទិន្នផលជាមធ្យម ២,៨៨៣ តោន/ហ.ត។ ដំណាំរួមផ្សំសរុបចំនួន ២១៧២ហ.ត ទាបជាងឆ្នាំ២០១៦ ចំនួន ១០០១ហ.ត និង ដំណាំកសិឧស្សាហកម្មដែលដាំដោយក្រុមហ៊ុនសប្បទានដីសេដ្ឋកិច្ចចំនួន ២៤ ១៩១,៥៥ហ.ត។

**ស្រូវ និងដំណាំរដូវប្រាំង៖** ផែនការចំនួន ៩៥២ហ.ត ក្នុងនោះ ភ្លួសរុបចំនួន ៩៩៤ហ.ត សាបសរុបចំនួន ៦ហ.ត ស្ទូង ព្រោះសរុបចំនួន ៩៧៧ហ.ត ស្មើនឹង ១០៥,៥៣%។ ផ្ទៃដីប្រមូលផលសរុបចំនួន៩៧៧ហ.ត ទិន្នផលមធ្យមចំនួន ៣,៩១៥តោន/ហ.ត បរិមាណផលសរុបមានចំនួន ១៦២៨,៩៥៥តោន ដំណាំរួមផ្សំសរុបចំនួន ៣៩១,៧៥ហ.ត។

– ក្រុមហ៊ុនដែលបានទទួលសិទ្ធិវិនិយោគដីសម្បទានសេដ្ឋកិច្ចក្នុងខេត្តមានចំនួន ២០ក្រុមហ៊ុន ដែលមានផ្ទៃដីសរុបចំនួន ៨៧៣៧៩.៦៩ហ.ត ដែលបាននឹងកំពុងគ្រប់គ្រង និងធ្វើការដាំដុំលើផ្ទៃដី ចំនួន ៤៨៥២៦,០៨ហ.ត ស្មើនឹង ៥៨,៩៦%

– ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងថ្នាំ និងជីកសិកម្មចំនួន ៥វគ្គ មានអាជីវករចូលរួមចំនួន ៤៥នាក់ ស្រី១០នាក់

– ខេត្តមានកសិដ្ឋានចិញ្ចឹមសត្វសរុបចំនួន ៣០១កន្លែង រួមមាន៖ កសិដ្ឋានចិញ្ចឹមជ្រូកពូជ ចំនួន ២៥កន្លែង កសិដ្ឋានចិញ្ចឹមជ្រូកសាច់ចំនួន ១៤៧កន្លែង កសិដ្ឋានចិញ្ចឹមមាន់ពង ចំនួន១៣ កន្លែង និងកសិដ្ឋានចិញ្ចឹមមាន់សាច់ចំនួន ១៦១កន្លែង

– ផ្សព្វផ្សាយពីផលប៉ះពាល់បរិស្ថានរបស់កសិដ្ឋានចិញ្ចឹមសត្វចំនួន ១៦លើក អ្នកចូលរួម ចំនួន ៣០នាក់ ស្រី ១៦នាក់

– ចុះផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មដល់កសិករចំនួន ៣២២លើក មានកសិករចូលរួម ចំនួន ៧៩៣៧នាក់ ស្រី ៣៣២៥នាក់។

---

[45] របាយការណ៍ប្រចាំត្រីមាសទី១ ស្តីពីការអនុវត្តការងាររដ្ឋបាលខេត្តកំពង់ស្ពឺ ឆ្នាំ២០១៨

❖ **ការងាររដ្ឋបាលព្រៃឈើ**

– ខណ្ឌរដ្ឋបាលព្រៃឈើមានសួនបណ្តុះកូនឈើចំនួន ១កន្លែង ថ្នាលបណ្តុះកូនឈើចំនួន ១៦កន្លែង និងស្ថានីយ៍ដាំឈើចំនួន ១កន្លែង សរុបចំនួន ១៨កន្លែង

– ការបណ្តុះកូនឈើចំនួន ៨៣៧៨៧ដើម និងចែកចាយកូនឈើសរុបចំនួន ៨១២៨៥ដើម

– សហគមន៍ព្រៃឈើកំពុងដំណើរការមានចំនួន ៥០កន្លែង ១៥២ភូមិ ២៦ឃុំ លើ៦ស្រុក មានប្រជាពលរដ្ឋចូលរួមចំនួន ៣១.៨៧២នាក់ ស្មើនឹង ១៥.៣៦៧គ្រួសារ មានផ្ទៃដីសរុបចំនួន ១៩.២៤៨ហ.ត ក្នុងនោះ សហគមន៍ចំនួន ៣០កន្លែង មានផ្ទៃដីសរុបចំនួន ១២៧២៤ហ.ត ត្រូវបានទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

– ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើក្នុងឆ្នាំ២០១៧ បានចំនួន ៥៤ករណី ក្នុងនោះកំពុងចាត់ការចំនួន ១៤ករណី បញ្ជូនទៅសាលាដំបូងខេត្តចំនួន ២៣ករណី និងរៀបចំចងក្រស្នើសុំបង់ពិន័យអន្តរការណ៍ចំនួន ១៩ករណី ឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសចំនួន ២នាក់ ចាប់ឃាត់វត្ថុតាង រួមមាន៖ ឈើចម្រុះប្រភេទចំនួន ៨១៣ម៣ ៣៨១ដើម ឈើរស់ចំនួន ២៣ដើម កូនឈើប្រឡៅមូលចំនួន ៦៥០ដើម កូនឈើទំហំ ១៥-៣០ស.ម ចំនួន ៣៨១ដើម ជន្លងម្រេចចំនួន ៨៤៣ដើម ស្នាត់ចំនួន ៣៩៥ ដើម និងបង្គោលក្រាក់ចំនួន ៣៩៩ដើម

– មធ្យោបាយដឹកជញ្ជូនរួមមាន៖ រថយន្តចំនួន ២០គ្រឿង គោយន្តកន្ត្រៃ ១១គ្រឿង គោ-យន្តថ្ងៃ ២គ្រឿង និងម៉ូតូចំនួន ២គ្រឿង។

❖ **ការងាររដ្ឋបាលជលផល**

– ចុះស្រង់ស្ថិតិកសិករផលិតកូនត្រីពូជ នៅក្នុងក្រុង/ស្រុកចំនួន៧ ស្មើនឹង ២៤កន្លែង ក្នុងនោះនៅបន្តដំណើរការចំនួន ៩កន្លែង និងឈប់ដំណើរការទាំងស្រុងចំនួន ១៥កន្លែង

– ទូទាំងខេត្តមានសហគមន៍ស្រះជម្រកត្រីចំនួន ១៧៤កន្លែង ក្នុងនោះសហគមន៍នៅដំណើរការចំនួន ១០០កន្លែង និងសហគមន៍ចំនួន ៧៤កន្លែងទៀត

– ខណ្ឌរដ្ឋបាលជនផលបានដឹកនាំមន្ត្រីផ្នែក និងសង្កាត់ក្រោមឱវាទចុះពិនិត្យស្ថានភាពបទល្មើសជលផលចំនួន ៥៦លើក ក្នុងនោះបានបង្ក្រាប និងដុតបំផ្លាញឧបករណ៍ នេសាទខុសច្បាប់មួយចំនួនរួមមាន៖ លូស្បៃមុងចំនួន ៨៣លមាត់ប្រវែង ៥៩៥ម៉ែត្រ របាំងស្បៃមុងចំនួន ១៣៧ខ្សែប្រវែង ៦១១ម៉ែត្រ និងបង្គោលចំនួន ៩៨៧ដើម និងត្រីកំពឹស ១៧,៧គ.ក្រ

– បានចុះស្រង់ស្ថិតិកូនត្រីពូជដែលកសិករផលិត និងលក់ក្នុងនោះ៖ កសិករផលិតបានចំនួន ៩៩៧.៥០០ក្បាល និងលក់បានចំនួន ៣៩៣.៨៣៥ក្បាល ស្មើនឹង ៩៩១គ្រួសារ។

❖ **ការងារធនធានទឹក និងឧតុនិយម**

– ចុះសិក្សាឋានលេខាប្រព័ន្ធស្រោចស្រពចំនួន ១៨គម្រោង

– បានជួសជុល និងថែទាំជាប្រចាំទំនប់អាងទឹកចំនួន ១០កន្លែង ប្រវែង ១៦.៣៦១ម៉ែត្រ

– បានជួសជុល និងថែទាំប្រឡាយមេចំនួន ៦ខ្សែ ប្រវែងសរុបចំនួន ២៥.៧៥៥ម៉ែត្រ

– បានជួសជុល និងថែទាំប្រឡាយរងចំនួន ៦ខ្សែ ប្រវែងសរុបចំនួន ៩.២០០ម៉ែត្រ

– បានបញ្ចុះម៉ាស៊ីនអន្តរាគមន៍បូមទឹក (ម៉ាកឥណ្ឌា ៦៥សេស) ចំនួន ៩គ្រឿង ក្នុងនោះក្រុងច្បារមន ៣គ្រឿង ស្រុកភ្នំស្រួច ១គ្រឿង ស្រុកសំរោងទង ២គ្រឿង ស្រុកគងពិសី ២គ្រឿង និងស្រុកបរសេដ្ឋ ១គ្រឿង ដើម្បីជួយបូមអន្តរាគមន៍សង្គ្រោះស្រូវជួបនឹងគ្រោះរាំងស្ងួតជូនប្រជាពលរដ្ឋក្នុងខេត្តលើផ្ទៃដី ៣.១៨៧,២០ ហ.ត

– ស្ថានភាពទឹកភ្លៀងពីខែមករា ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ មធ្យមទូទាំងខេត្ត មានចំនួន ១.២៤២,៦មម បើប្រៀបធៀបនឹង ឆ្នាំ២០១៦ ទាបជាងចំនួន ២៨៧,៧មម។

❖ **ការងារអភិវឌ្ឍន៍ជនបទ**

– ជួសជុលផ្លូវក្រាលខ្សាច់ភ្នំបាន ១ខ្សែ ប្រវែង ២៥០០ម៉ែត្រ នៅភូមិបាល័ង្គរាជ ឃុំស្ពំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ អនុវត្តបាន ១០០% នៃផែនការដោយប្រើប្រាស់ថវិកាមន្ទីរអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៧

– ផ្គត់ផ្គង់សម្ភារៈ និងសាងសង់បង្គន់អនាម័យជូនគ្រួសារក្រីក្រសរុបបានចំនួន ៩៦០បង្គន់ ដែលមានអ្នកទទួលផលចំនួន ២២៨៩នាក់ ស្រីចំនួន ១៩៣០នាក់ នៅតាមភូមិ ឃុំ និងស្រុកគោលដៅ

– ការងារថែទាំផ្លូវលក្ខណៈខួបបានចំនួន ៦ខ្សែ ប្រវែង ៣៣៥១០ម៉ែត្រ ដោយប្រើប្រាស់ថវិកាក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០១៧ អនុវត្តសម្រេចបាន ១០០% នៃផែនការប្រចាំឆ្នាំ២០១៧ ខ្សែផ្លូវរួមមាន៖ ខ្សែទី១ ប្រវែង៣៥០០ម៉ែត្រ ភូមិត្រពាំងដុះគ្រួស ឃុំអូរ ស្រុកភ្នំស្រួច ខ្សែទី២ ប្រវែង ៣១០០ម៉ែត្រ ភូមិទឹកថ្លា ដល់ភូមិទឹកល្អក់ ឃុំដំបូករូង ស្រុកភ្នំស្រួច ខ្សែទី៣ ប្រវែង ៣២០០ម៉ែត្រ ភូមិទឹកថ្លា ឃុំដំបូករូង ស្រុកភ្នំស្រួច ខ្សែទី៤ ប្រវែង ៦៥០០ម៉ែត្រ អូរមុខទឹក ឃុំព្រៃរំដួល ដល់ព្រំរលក ឃុំតាំងស្យា ស្រុកភ្នំស្រួច ខ្សែទៅ៥ ប្រវែង ៣១០០ម៉ែត្រ ភូមិក្រាំងសិរី ឃុំគីរីវ័ន្ត ស្រុកភ្នំស្រួច ខ្សែទី៦ ប្រវែង ២៩៧០ម៉ែត្រ ភូមិក្រាំងខ្វារ ឃុំគីរី ស្រុកភ្នំស្រួច

– សរុបនៅក្នុងឆ្នាំ២០១៦ ក្នុងខេត្តកំពង់ស្ពឺមានខ្សែផ្លូវ ១១៦៧ខ្សែ ប្រវែង ២៧៧០គ.ម គិតមកដល់ឆ្នាំ២០១៧នេះសរុបខ្សែផ្លូវមានចំនួន ១១៩១ខ្សែ ដែលមានប្រវែងសរុបចំនួន ២៧៩៩គ.ម មានការកើនឡើងពីឆ្នាំ២០១៦ ចំនួន ២៤ខ្សែ ប្រវែង ២៨,៥៣គ.ម

– សាងសង់អណ្តូងស្នប់ និងតម្លើងស្នប់អាហ្វ្រីដេវបានចំនួន ១៣អណ្តូងនៃផែនការ ១៣ អណ្តូង ស្មើនឹង ១០០% នៅស្រុកថ្ពង សំរោងទង និងក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានអ្នកទទួលផលចំនួន ៣២៥គ្រួសារ ១៦២៥នាក់ ដោយប្រើប្រាស់ថវិកាក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០១៧

– អនុវត្តគម្រោងអភិវឌ្ឍន៍ចម្រុះ នៅភូមិត្រោតកែវ ឃុំសែនដី ស្រុកសំរោងទង ប្រជាពលរដ្ឋចំនួន ៥គ្រួសារ ទទួលបានស្រះសម្រាប់ចិញ្ចឹមត្រីជាលក្ខណៈគ្រួសារដែលមានទំហ (បណ្តោយ ៥ម៉ែត្រ ទទឹងប្រវែង ៥ម៉ែត្រ និងជម្រៅ ២,៥ម៉ែត្រ) ចំនួន ៥ស្រះ និងកូនត្រីចម្រុះចំនួន ១៥០០ក្បាល

– បើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុង និងក្រៅមជ្ឈមណ្ឌលចំនួន ៧មុខជំនាញ ស្មើនឹង ១៩វគ្គ មានសិក្ខាកាមចូលរួមរៀនចំនួន ៥៥៥នាក់ ស្រី ២១៩នាក់។

❖ **ការងារឧស្សាហកម្ម និងសិប្បកម្ម**

– ទូទាំងខេត្តរោងចក្រធុនធំចំនួន ១១៦រោងចក្រ ដោយប្រើប្រាស់ពលកម្មសរុបចំនួន ៩១.៩៤៣នាក់ ស្រី៩០.៧៥០នាក់ ក្នុងនោះ រោងចក្រកំពុងដំណើរការមានចំនួន ៨៦រោងចក្រ រោងចក្រផ្អាកដំណើរ ការចំនួន ១២រោងចក្រ និងរោងចក្រកំពុងសាងសង់ចំនួន ១៨រោងចក្រ

– មានសហគ្រាសធុនតូច មធ្យម និងសិប្បកម្មសរុបចំនួន ៦.១៦៤មូលដ្ឋាន ប្រើប្រាស់កម្លាំងពលកម្មសរុប ១៧.១៥៧នាក់ ស្រី ៦.២៥០នាក់

– ចុះពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងឥន្ធនៈតាមបណ្តាស្ថានីយ៍ និងដេប៉ូសម្រាប់ឆ្នាំ២០១៧ បានចំនួន ១៣៦មូលដ្ឋាន ៣៣៨កុងទ័រ និងដៃបាញ់ប្រេង ១.២៥៤ដៃ

– នៅទូទាំងខេត្តមានសហគ្រាសផលិត និងផ្គត់ផ្គង់ទឹកស្អាតឯកជនសរុបចំនួន ៥៦មូលដ្ឋាន មានប្រកាសក្រសួងចំនួន ២៥មូលដ្ឋាន មានគោលការណ៍អនុញ្ញាតពីក្រសួងចំនួន ១៨មូលដ្ឋាន កំពុងស្នើសុំធ្វើការសិក្សាសម្មិទ្ធិលទ្ធភាពធ្វើអាជីកម្មផ្គត់ផ្គង់ទឹកស្អាតចំនួន ៣មូលដ្ឋាន។

❖ **ការងាររ៉ែ និងថាមពល**

– ជំរុញការប្រមូលចំណូលសួយសាររ៉ែ តាមនីតិវិធីស្វ័យប្រកាសពីក្រុមហ៊ុនធ្វើអាជីវកម្មក្នុងកាលបរិច្ឆេទឆ្នាំ ខ្សាច់ស្ទឹង អាជ្ញាប័ណ្ណសិប្បកម្មខ្សាច់បក និងអាជ្ញាប័ណ្ណសិប្បកម្មជីករណ្តៅដី។

– បច្ចុប្បន្នទូទាំងខេត្តកំពង់ស្ពឺ មានអាជ្ញាប័ណ្ណរ៉ែសរុបចំនួន ១០៦ការដ្ឋាន ក្នុងនោះ៖ ដំណើរការ ៦២ការដ្ឋាន កំពុងរៀបចំការដ្ឋាន ១៥ការដ្ឋាន គ្មានសកម្មភាព ២៩ការដ្ឋាន ចែកចេញ៖ ក្រុមហ៊ុនថ្ម សម្ភារៈសំណង់ ១០២ការដ្ឋាន ក្រុមហ៊ុនចុះអនុស្សរណៈ និងសិក្សាស្រាវជ្រាវរ៉ែលោហៈ ចំនួន ៤ការដ្ឋាន គ្មានសកម្មភាព ៤ការដ្ឋាន

– វិស័យប្រេងកាតៈ ស្ថានីយ៍ស្តុក និងចែកចាយប្រេងឥន្ធនៈចំនួន ២៦៦ទីតាំង ស្ថានីយ៍ស្តុក និងចែកចាយ(ហ្គាស)ចំនួន ៥០ទីតាំង សេវាកម្មប្តូរប្រេងម៉ាស៊ីនចំនួន ១៩៩ទីតាំង

– ក្រុមហ៊ុនផ្គត់ផ្គង់ និងចែកចាយអគ្គិសនី (រដ្ឋ និងឯកជន) ចំនួន ២១ក្រុមហ៊ុន ក្នុងនោះមានអាជ្ញាប័ណ្ណអគ្គិសនី ១,៣១០ភូមិ/ ១,៣៧៩ភូមិ ស្មើនឹង៩៤,៩៩% និងមានអាជ្ញាប័ណ្ណអគ្គិសនីចូលដល់ភូមិ ១,១៩៩ភូមិ ស្មើនឹង ៨៦,៩៥%។ ទូទាំងខេត្តប្រជាជនមានអគ្គីសនីប្រើប្រាស់ ១៣៧,៣០៤/១៧៦,៨១១គ្រួសារ ស្មើនឹង ៧៧,៦៦%។

❖ **ការងារពាណិជ្ជកម្ម**

– ក្នុងឆ្នាំ២០១៧ ការដាក់ស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទអនុវត្តន៍បានចំនួន ៣២លើក សរុបទាំងអស់ ១.៣៨៧ទីតាំង បើធៀបទៅឆ្នាំ២០១៦ ថយចុះ ៥លើក ទីតាំងមានការកើនឡើងចំនួន ៦២ទីតាំង ស្មើនឹង ៤,៦៧% ក្នុងនោះអនុវត្តក្រុងច្បារមនបានចំនួន ១៣លើក ស្រុកភ្នំស្រួចចំនួន ៥លើក ស្រុកបរសេដ្ឋចំនួន ៣លើក ស្រុកឱរ៉ាល់ចំនួន ៣លើក និងស្រុកគងពិសីចំនួន ៤លើក ស្រុកឧដុង្គចំនួន ១លើក និងស្រុកសំរោទងចំនួន ៣លើក

– បានចុះស្រង់ស្ថិតិតាមបណ្តារោងម៉ាស៊ីន និងកន្លែងស្តុកស្រូវអង្ករទូទាំងខេត្ត មកដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ មានស្តុកស្រូវចំនួន ៦៨.៥០០តោន និងស្តុកអង្ករចំនួន ២៧.៣៨០តោន

– បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មជូនអាជីវករ សេវាករមានចំនួន ៩៣០ច្បាប់ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ មានការថយចុះចំនួន ១៤២ច្បាប់ ស្មើនឹង(១៣,២០%) ក្នុងនោះ៖ ច្រកចេញចូលតែមួយក្រុងច្បារមនបានចំនួន ៤២៥ច្បាប់ ធៀបនឹងនឹងឆ្នាំ២០១៦ មានការកើនឡើងចំនួន ៦១ច្បាប់ ស្មើនឹង(១៦,៧៦%) និងមន្ទីរពាណិជ្ជកម្មខេត្តអនុវត្តបានចំនួន ៥០៥ច្បាប់ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ មានការថយចុះចំនួន ២០៦ច្បាប់ ស្មើនឹង២៨,៩៧%។

❖ **ការងារហិរញ្ញវត្ថុ**

– ចំណូលថវិកាថ្នាក់ជាតិសរុបចំនួន ១៩.០០៧.៤២៨.៥០៨លានរៀល ស្មើនឹង ៨២,៩៧% នៃផែនការឆ្នាំសម្រាប់ចំណាយថវិកាថ្នាក់ជាតិ ១៦៨.១៥៣.១៦៧.០១៩លានរៀល ស្មើនឹង ៩៣,៥០% នៃផែនការឆ្នាំប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំមុនស្មើនឹង ១១៦,១៨%។

– ចំណូលថវិកាថ្នាក់ខេត្តសរុបចំនួន ២១.០០៦.៥៨១.២៩៨លានរៀល ស្មើនឹង ១៦០,៤៣% នៃផែនការឆ្នាំ និងចំណូលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់បំពេញតុល្យភាព ៨.២២០.០០០.០០០លានរៀល ស្មើនឹង១៧៨.៦៩% នៃផែនការឆ្នាំ។ ចំណែកការចំណាយថវិកាខេត្តសរុប ១១.៩២៩.៣៦៦.៩៧០លានរៀល ស្មើនឹង ៩១.១១% នៃផែនការឆ្នាំ។

– ចំណូលថវិកាថ្នាក់ក្រុង ស្រុកសរុបចំនួន ៧.៣៧៨.១១៣.៣០០លានរៀល ស្មើនឹង ៨៨.៥៧% និងចំណូលរដ្ឋបាលខេត្តឧបត្ថម្ភគុល្យភាពលើសេវាកម្មអនាម័យបរិស្ថានក្រុង ស្រុក ២២៦.០០០.០០០លានរៀល ស្មើនឹង៧៨.៧៤% នៃផែនការឆ្នាំ។ ចំណាយថវិកាថ្នាក់ក្រុង ស្រុកសរុបចំនួន ៦.៨២៤.៣៤៣.៧៧០លានរៀល ស្មើនឹង ៨១.៩២% នៃផែនការឆ្នាំ។

❖ **ការងាររតនាគារ**

– ផ្នែកចំណូលសរុបមានចំនួន ២៤១.០៧៦លានរៀលក្នុងនោះ៖ ចំណូលពីរតនាគារជាតិមានចំនួន ២១៥.៩៧៨លានរៀល ពន្ធដារមានចំនួន ១៨.៩៥៦លានរៀល ប្រភពចំណូលផ្សេងៗ ៦.១៤២លានរៀល ក្នុងនោះ៖ ហិរញ្ញកិច្ច (មន្ទីរផ្សេង) មានចំនួន ១.៩៥៤លានរៀល ភាសុី ១៦៨ លានរៀល ចំណត ៥៦លានរៀល សត្តឃាត ១៥លានរៀល មូលនិធិឃុំ សង្កាត់ ២០៨លានរៀល ផ្សេងៗ ៣.៧៤១លានរៀល

– ផ្នែកចំណាយសរុបមានចំនួន ២៣៨.៣៦៧លានរៀល ក្នុងនោះ៖ យោធា ២៩.៩១៤-លានរៀល រដ្ឋបាលស៊ីវិល ២០៨.៤៥៣លានរៀល បៀវត្ស ១១៨.០២៤លានរៀល ចំណាយមូលនិធិឃុំ/សង្កាត់ ២១.៨៦៤លានរៀល ផ្សេងៗចំនួន ៣៨.៦១៣លានរៀល

– រជ្ជទ័យមិនមែនកម្មវិធី ១៣៤លានរៀល រជ្ជទ័យតាមកម្មវិធី ៥៨៦៤លានរៀល ផ្ទេរទៅភ្នំពេញ ២៣.៩៥៤លានរៀល។

❖ **ការងារពន្ធដារ**

ការគ្រប់គ្រងការប្រមូលចំណូលរបស់សាខាពន្ធដារប្រចាំឆ្នាំ២០១៧ មានដូចខាងក្រោម៖

– ចំណូលពន្ធសរុប៖ ផែនការមានចំនួន ២៣.៥៥៣.០០០.០០០លានរៀល ប្រមូលបាន ២៥.៨៩៧.៧៩៩.០០០លានរៀល ស្មើនឹង ១១៨,៤៧%

– ថវិការដ្ឋ៖ ផែនការចំនួន ១៥.៩៥៨.០០០.០០០លានរៀល ប្រមូលបាន ១៤.៨២៣.៤៤៧.០០០លានរៀល ស្មើនឹង ៩២.៨៩%

– ថវិកាខេត្ត៖ ផែនការចំនួន ៧.៥៨៥.០០០.០០០លានរៀល ប្រមូលបាន ១២.០៧៤.៣៥២ លានរៀល ស្មើនឹង ១៦១,៣១%

❖ **ការងារធនាគារជាតិសាខាខេត្ត**

– ចំណូលជាប្រាក់រៀលមានចំនួន ៨៣.៥០៩.៩៣៩.៧៦៨លានរៀល បើប្រៀបធៀបទៅនឹងឆ្នាំមុនថយចុះ ៧.៦១%

– ចំណូលជាប្រាក់ដុល្លារមានចំនួន ៥៦.៣៧៤.៦២២,២២ដុល្លារ បើប្រៀបធៀបទៅនឹងឆ្នាំមុនកើនឡើង ២,៥៣%

– ចំណាយជាប្រាក់រៀលមានចំនួន ១៦២.២៣៤.៩៩១.៥៩៥លានរៀល បើប្រៀបធៀបទៅនឹងឆ្នាំមុនកើនឡើង ១២៣,៦៣%

– ចំណាយប្រាក់ដុល្លារមានចំនួន ៧៣.៧១៥.៥៦៨.២២ដុល្លារ ប្រៀបធៀបទៅនឹងឆ្នាំមុនកើនឡើង ៧៧,៣៣%

– ប្រាក់រៀល ចាស់ ទក់ រហែក ប្តូរបានសរុបចំនួន ២.៨១០.២២៨.២០០រៀល ធ្វើការស្រាល់ជ្រើសនៅនឹងកន្លែង និងតាមរយៈអ្នកប្តូរនៅនឹងបញ្ជរ។

❖ **ការងារទេសចរណ៍**

– បានសហការជាមួយរដ្ឋបាលខេត្ត ដើម្បីផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ ២៩២-សជណ.អគឧ ស្តីពីការរក្សាតម្លៃសេវាកម្ម អាជីវកម្មទេសចរណ៍ក្នុងរយៈពេលប្រលងមធ្យមសិក្សា-ទុតិយភូមិ ដល់ម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ក្នុងខេត្តរួមមានៈ សណ្ឋាគារ ផ្ទះសំណាក់ ផ្នែកភោជនីយដ្ឋានអាហារដ្ឋាន ក្នុងខេត្តកំពង់ស្ពឺ

– ចុះត្រួតពិនិត្យទីតាំង និងពង្រឹកការគ្រប់គ្រងមូលដ្ឋានអាជីវកម្ម សេវាកម្មកម្សាន្ត សេវាកម្មស្នាក់នៅ ក្នុងស្រុកគងពិសីចំនួន ៣៥លើក ស្រុកឧដុង្គចំនួន ៣២លើក ស្រុកភ្នំស្រួចចំនួន ៣៦លើក ស្រុកសំរោងទងចំនួន ៣៨លើក ស្រុកបរសេដ្ឋចំនួន ៥លើ ស្រុកឱរ៉ាលចំនួន ២២លើក ស្រុកថ្ពងចំនួន ១៤លើក និងក្រុងច្បារមនចំនួន ៦២លើក

– ភ្ញៀវចូលរួមមកលេងកម្សាន្តក្នុងសួនច្បារ និងផ្សាររាត្រីខេត្ត ក្នុងឱកាសប្រារព្ធពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ និងតាំងពិព័ណ៌មិត្តភាពកម្ពុជា-ថៃ និងមានការប្រគំតន្ត្រីនៅទីលានមណ្ឌលកីឡាខេត្តក្នុងរយៈពេល ៧ថ្ងៃ ចាប់ពីថ្ងៃទី២៤ ដល់ ៣០ ខែតុលា ឆ្នាំ២០១៧ សង្កេតឃើញមានភ្ញៀវមកលេងកម្សាន្តក្នុងរយៈពេលមួយយប់ប្រមាណជាង ៦០.០០០នាក់

– បានចេញអាជ្ញាប័ណ្ណទេសចរណ៍ចំនួន ៣៩មូលដ្ឋាន ដែលបានចំណូលចំនួន ២.៨៨០.០០០លានរៀល

– ទូទាំងខេត្តមានសណ្ឋាគារចំនួន ០៥កន្លែង ស្មើនឹង ១០៨បន្ទប់ ផ្ទះសំណាក់ចំនួន ១៦កន្លែង ភោជនីយដ្ឋានអាហារដ្ឋានចំនួន ១៤កន្លែង សេវាកម្មកម្សាន្តចំនួន ១១កន្លែង។

**២.៤.២.២- ការងារសង្គមកិច្ច**

❖ **ការងារអប់រំ យុវជន និងកីឡា**

– មត្តេយ្យសិក្សារដ្ឋមានចំនួន ១៧៤សាលា ស្មើនឹង ២៥១ថ្នាក់ មានសិស្សសរុបចំនួន ៨.១៣៥នាក់ ស្រីចំនួន ៤.០៧៦នាក់ មានគ្រូសរុប ២៦៣នាក់ ស្រី ២៤៩នាក់

– មត្តេយ្យឯកជនមានចំនួន ១៥សាលា ស្មើនឹង ៣៨ថ្នាក់ សិស្សសរុបមានចំនួន ១.០៦៨នាក់ ស្រី ៥២៨នាក់ គ្រូសរុប ៣៨នាក់ ស្រី ៣៨នាក់

– មត្តេយ្យសិក្សាសហគមន៍ចំនួន ៣០៨កន្លែង ស្មើនឹង ៣១២ថ្នាក់ មានសិស្សសរុបចំនួន ៧.៩០៥នាក់ មានគ្រូសរុបចំនួន ៣១១នាក់ ស្រី ២៧៩នាក់

– សាលាបឋមសិក្សាមានចំនួន ៣១៣សាលា ស្មើនឹង ២.៩០៣ថ្នាក់ មានសិស្សសរុបចំនួន ១១២.៨៣៥នាក់ ស្រី ៥៤.៥៥៣នាក់ គ្រូសរុបចំនួន ២.៧០១នាក់ ស្រី ១០៧០នាក់

– អនុវិទ្យាល័យមានចំនួន ៧០សាលា ស្មើនឹង ៩១៣ថ្នាក់ សិស្សសរុប ៣២.៣០៨នាក់ ស្រី ១៦.៨១៣ នាក់ មានគ្រូសរុប ១.០៨៥នាក់ ស្រីមានចំនួន ៣៦២នាក់

– វិទ្យាល័យមានចំនួន ២៣សាលា ស្មើនឹង ៥០៨ថ្នាក់ សិស្សសរុប ២១២.៧៦៨នាក់ ស្រី ៦.២០៨នាក់ និងមានគ្រូសរុប ១.១៥៥នាក់ ស្រី ៤៥២នាក់

– បានទទួលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំនួន ៨៧សាលា ទូទាំងខេត្ត បេក្ខជនប្រឡងចំនួន ៦៤០២នាក់ បញ្ជី ៣១៣៥នាក់ បេក្ខជនមកប្រឡងចំនួន ៦២១៨នាក់ ស្រី ៣០៥៨នាក់ បេក្ខជនប្រឡងជាប់ចំនួន ៥៩១៦នាក់ ស្មើនឹង ៩៥,១៤% ស្រី ២៩៩៧ គិតជាភាគរយ ៩៥,១៣%

– បានចូលរួមការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ១០មណ្ឌល មាន១៨១បន្ទប់ បេក្ខជនប្រឡងក្នុងបញ្ជីចំនួន ៤.៨៤៦នាក់ ស្រី ២.១១២នាក់ បេក្ខជនប្រឡងជាក់ស្តែងចំនួន ៤.៤០៣នាក់ ស្រី ២.០៩៧នាក់ បេក្ខជនប្រឡងជាប់ចំនួន ៣.៥១៨នាក់ ស្មើនឹង ៧៩,៨១% ស្រី ១១៧០នាក់ ស្មើនឹង ៦៨,៥៨%។

❖ **ការងារសុខាភិបាល**

– ចំនួនអ្នកពិគ្រោះជម្ងឺក្រៅនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យៈ ករណីថ្មីមានចំនួន ៣៣៨.០៨៨ករណី ករណីសរុបចំនួន ៣៧៦.២៧២ករណី

– បញ្ហាសុខភាពករណីថ្មីនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យៈ ជម្ងឺរាកមានចំនួន ១១.៦២០ករណី រលាកផ្លូវដង្ហើមមានចំនួន ១១១.៣៩៧ករណី សង្ស័យគ្រុនឈាមចំនួន ៧៦ករណី គ្រុនចាញ់មានចំនួន ៤.៨៥៤ករណី ក្អកលើស ១៤ថ្ងៃចំនួន ៨.៥៨១ករណី លើសឈាមមានចំនួន ៦.៨០០ករណី គ្រោះថ្នាក់ចរាចរណ៍ចំនួន ៣.៥១០ករណី និងជម្ងឺផ្សេងៗមានចំនួន ១៩១.១៥២ករណី

– ករណីឈឺសម្រាកនៅមណ្ឌលសុខភាពចំនួន ៦២៣នាក់ និងករណីឈឺសម្រាកនៅមន្ទីរពេទ្យចំនួន ១៨.៣៥៩នាក់ និងស្លាប់នៅមន្ទីរពេទ្យចំនួន ១៤៥នាក់។ ការពិនិត្យផ្ទៃពោះសរុបចំនួន ៨៣.៩៦២ ការសំរាលកូននៅមណ្ឌលសុខភាពចំនួន ៨៧.៨៦នាក់ និងមន្ទីរពេទ្យចំនួន ៣៨៧៣នាក់

– ក្រុមការងារគ្រូពេទ្យស្ម័គ្រចិត្ត **ឯកឧត្តម ហ៊ុន ម៉ានី** ចុះពិនិត្យនឹងព្យាបាលជូនកម្មករ កម្មការិនី ពីថ្ងៃទី២ ខែតុលា ដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅតាមរោងចក្រចំនួន ៧១រោងចក្រ មានកម្មករ កម្មការិនីសរុបចំនួន ៧៣.៨៥៧នាក់ ស្រី ៦៧.០១៩នាក់ ដែលទទួលបានការពិនិត្យសុខភាព និងព្យាបាលជម្ងឺ។

❖ **ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

– កុមារកំព្រារស់នៅក្នុងមណ្ឌលរដ្ឋមានចំនួន ៦៥នាក់ ស្រី ៣០នាក់ និងរស់នៅតាមមណ្ឌលអង្គការនានាមានចំនួន ៨០០នាក់ ស្រី ៣៥៤នាក់

– សរុបកុមារកំព្រារដ្ឋ និងកុមារកំព្រាដែលរស់នៅតាមមណ្ឌលអង្គការនានាចំនួន ៨៦៥នាក់ ស្រី ៣៨៤នាក់

– មណ្ឌលស្តារលទ្ធភាពពលកម្មជនពិការគ្រប់ប្រភេទមានចំនួន ៨.៦៧២នាក់ ស្រី៣.៣២៤នាក់ក្នុងនោះ៖ ជនពិការមកទទួលសេវាកម្មក្នុងសរុបចំនួន ៩០៣នាក់ ស្រី ២០០នាក់ បានទទួលការព្យាបាលដោយចលនាចំនួន ៩០៣នាក់ ស្មើនឹង ៣៣៥៤ដង

– ផ្តល់ជើងសិប្បនិម្មិតលើជង្គង់ ៥៤ជើង ជើងសិប្បនិម្មិតក្រោមជង្គង់ចំនួន ១៩១ជើង ផ្តល់ដៃសិប្បនិម្មិតចំនួន ១២ដើម រណបគ្រប់ប្រភេទចំនួន ១៤៣ឈើច្រត់ក្លៀកចំនួន ៥៦រាយ ប្រដាប់ទប់ខ្លួនសម្រាប់ដើរចំនួន ៤២(សម្រាប់ក្មេង) និងរទេះរុញចំនួន ៥៩គ្រឿង។

❖ **ការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ**

– សហគ្រាស គ្រឹះស្ថាន រោងចក្រ សរុបចំនួន ២០៦កន្លែង បានចុះបញ្ជីកាសរុបចំនួន ១៨៨បញ្ជី មានកម្មករសរុបចំនួន ៩១,១៨៥នាក់ ស្រីចំនួន ៧៧,១៨០នាក់

– រោងចក្រ សហគ្រាសបើកថ្មីមានចំនួន ៥៤កន្លែង រោងច្រក សហគ្រាសបិទមានចំនួន ៤កន្លែង រោងចក្រ សហគ្រាសព្យួរការងារមានចំនួន ៧កន្លែង

– ការដោះស្រាយវិវាទការងាររួមសរុបចំនួន ៩រោងចក្រ សហគ្រាសចំនួន ៩ករណី សះជាចំនួន ៧ករណី និងមោឃ: ១ករណី

– បានធ្វើការហ្វឹកហ្វឺនកូនជាងបានចំនួន ៦៤ក្រុមហ៊ុន កូនជាងសរុប ៣,១៥១នាក់ ស្រីចំនួន ២,៨៥៩ នាក់

– បានចុះណែនាំ និងជំរុញដល់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនដើម្បីចុះធ្វើការផ្សព្វផ្សាយបញ្ញត្តិស្តីពីកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងបានចំនួន ២៥៥រោងចក្រ សហគ្រាស។

❖ **ការងារព័ត៌មាន**

– បានផ្តល់សេវាសាធារណៈទៅលើស្លាកសញ្ញាឃីហោប៉ាណ្ហូអាហ្វីសបានចំនួន ១៨៨សេវា

- ចូលរួមកម្មវិធីប្រជុំ និងយកព័ត៌មាននៅសាលាខេត្តនិងតាមបណ្តាក្រុង ស្រុកចំនួន ២៣៥លើក
- រាយការណ៍ទៅទូរទស្សន៍ជាតិ ចំនួន ១៦៩ លើក
- ផ្សាយទូរទស្សន៍ជាតិ និងឯកជន ចំនួន ៨០ លើក
- ផ្សាយតាមទូរទស្សន៍ខ្សែកាប្លិ៍ ចំនួន ៨៦ លើក។

❖ **ការងារកិច្ចការនារី**

- បានបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរចំនួន ២វគ្គ ដែលមានសិស្សចូលរួមសរុបចំនួន ១២០នាក់ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈតម្បាញចំនួន ២វគ្គ ដែលមានសិស្សចូលរួមសរុបចំនួន ៤០នាក់ វគ្គកែឆ្នៃចំណីអាហារចំនួន ១វគ្គ មានសិស្សសរុបចំនួន ១០នាក់

- ក្រុមការងារថ្នាក់ខេត្ត/ស្រុក បានបើកវគ្គបណ្តុះបណ្តាលជូនដល់ភ្នាក់ងារអប់រំសុខភាពភូមិ ស្តីពីយេនឌ័រ និងសុខភាពភ្នែកបានចំនួន ៥វគ្គ ២ស្រុកគឺៈ ស្រុកគងពិសី ឃុំស្រង់ និងស្រុកភ្នំស្រួច ឃុំអូរ ឃុំគីរីវន្ត មានអ្នកចូលចំនួន ១២១នាក់ ស្រី ៧៣នាក់

- ក្រុមការងារថ្នាក់ខេត្ត/ស្រុក បានសហការជាមួយមន្ទីរសុខាភិបាលខេត្ត ចុះធ្វើយុទ្ធការការអប់រំពិនិត្យ និងព្យាបាលភ្នែកដោយឥតគិតថ្លៃចំនួន ៥លើក មានអ្នកចូលរួមសរុបចំនួន ៧៦៥នាក់ ស្រី ៤៩៦នាក់ និងអ្នកមានបញ្ហាភ្នែកទៅរកសេវាព្យាបាលភ្នែកចំនួន ១១៦នាក់ ស្រី ៧២នាក់

- បានរៀបចំវេទិកាសហគមន៍ផ្សព្វផ្សាយស្តីពីច្បាប់អំពើហិង្សាក្នុងគ្រួសារ ទប់ស្កាត់ការរំលោភបំពានផ្លូវភេទ ទប់ស្កាត់ចំណាកស្រុក និងជួញដូរមនុស្ស គោលការណ៍ស្ទួលទាំង៦ បុរសល្អ នៅភូមិ សាឡាំ ឃុំពោធិ៍ម្រាល ស្រុកបរសេដ្ឋ មានអ្នកចូលរួមចំនួន ៧៥នាក់ ស្រី ៥០នាក់

- បានរៀបចំវេទិកាសហគមន៍លើកកម្ពស់សមភាពយេនឌ័រ និងបង្កើតភាពអង់អាចដល់ស្ត្រីក្រោមប្រធានបទ ស្តីពីចំណេះដឹងយេនឌ័រ និងការលើកកម្ពស់ស្ថានភាពស្ត្រី នៅឃុំស្វាយរំពា ស្រុកបរសេដ្ឋ មានសមាសភាពចូលរួមចំនួន ៦១នាក់ ស្រី ២៧នាក់ ។

❖ **ការងារធម្មការ និងសាសនា**

- ទូទាំងខេត្តមានវត្តចំនួន ២៨៧វត្ត ក្នុងនោះៈ វត្តធម្មយុត្តិកនិកាយ ១៧វត្ត និងវត្តមហានិកាយ ២៧០វត្ត ព្រះសង្ឃចំនួន ៣.៦៦៣អង្គ ភិក្ខុចំនួន ១.១១៣អង្គ សាមណេរចំនួន ២.៥៥០អង្គ អាចារ្យចំនួន ៨៧៤នាក់ អាស្រមវិប្បសនាចំនួន ២២កន្លែង គណៈកម្មករចំនួន ១៩៧៥នាក់ តាជីចំនួន ២០៧នាក់ ដូនជីចំនួន ៥៧២នាក់ សិស្ស-និស្សិតចំនួន ២៣៨នាក់ និងក្មេងវត្តចំនួន ២៩៤នាក់

- សាលាពុទ្ធិកៈបឋមសិក្សាមានចំនួន ៦៥សាលា មានសមណសិស្សកំពុងសិក្សាចំនួន ១១០០ អង្គ/នាក់ មានគ្រូ ១១០អង្គ/នាក់។ សាលាធម្មវិន័យសរុបចំនួន ៣២សាលា សមណៈសិស្ស

ចំនួន ៤២៣អង្គ/នាក់។ សាលាពុទ្ធិកៈអនុវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្រុងច្បារមន មានចំនួន ១សាលា ព្រមទាំងសមណសិស្សកំពុងសិក្សាចំនួន ១៤៥អង្គ/នាក់

– បានចូលរួមចែកអំណោយដល់គ្រួសារក្រីក្រចំនួន ៥៣គ្រួសារ ចូលរួមសម្ពោធសមិទ្ធិផលនានាទូទាំងខេត្តចំនួន ៩លើក និងបានចូលរួមបុណ្យបញ្ចុះខណ្ឌសីមាចំនួន ៧ ទូទាំងខេត្តកំពង់ស្ពឺ។

❖ **ការងារមុខងារសាធារណៈ**

– គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ ការប្រើប្រាស់មន្ត្រីរាជការស៊ីវិលសរុបក្នុងខេត្តកំពង់ស្ពឺមានចំនួន ៧,៦៥១នាក់ ស្រី ២,៩២២នាក់ មានដូចខាងក្រោម៖

- មន្ត្រីរាជការស៊ីវិលដែលមានក្របខណ្ឌប្រភេទ "**ក**" ចំនួន ១១១២នាក់ ស្រី ២៨៧នាក់
- មន្ត្រីរាជការស៊ីវិលដែលមានក្របខណ្ឌប្រភេទ "**ខ**" ចំនួន ២,៧៨២នាក់ ស្រី ៩៦៣នាក់
- មន្ត្រីរាជការស៊ីវិលដែលមានក្របខណ្ឌប្រភេទ "**គ**" ចំនួន៣,៧៥៧នាក់ស្រី១,៦៧៦នាក់
- មន្ត្រីជាប់កិច្ចសន្យាចំនួន ៤៥៣នាក់ ស្រី ១៧១នាក់

– បានស្រង់របាយការណ៍សរុបស្តីពីប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលតាមមន្ទីរ/អង្គភាពមានចំនួន ២៥មន្ទីរ និងក្រុង/ស្រុក ០៨ ដែលមានចំនួន ៨.៦០៦ករណី ទៅអគ្គនាយកដ្ឋានគ្រប់មុខងារសធារណៈ។

### ២.៤.៣- ការគ្រប់គ្រងដីធ្លី បរិស្ថាន សាធារណការ និងសោភ័ណភាព

❖ **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

– ក្នុងឆ្នាំ២០១៧ បញ្ចូលទិន្នន័យដីធ្លីមានលក្ខណៈជាប្រព័ន្ធបានចំនួន ២៥២៧៩ក្បាល់ដី បិទផ្សាយជាសាធារណៈចំនួន ២៣៩៤៣ក្បាល់ដី និងបានចែកប័ណ្ណបានចំនួន ២៩៤៥៥ប័ណ្ណ

– ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធចំនួន ២៧០.៦៩៨ក្បាលដី និងចេញប័ណ្ណជូនប្រជាពលរដ្ឋចំនួន ២១៤.២៧២ប័ណ្ណ

– បានចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំសរុបចំនួន ១៩៣ក្បាលដី ស្មើនឹង ១៣២៣ហិកតា ២០អា ៩សអ ចែកប័ណ្ណចំនួន ៣១.២៥ប័ណ្ណ

– បានចុះបញ្ជីដីរដ្ឋចំនួន ៣៥ប័ណ្ណ ស្មើនឹង ១១២៧៣ហិកតា ៩៩អា បានចេញប័ណ្ណ ១២៨ប័ណ្ណ ស្មើនឹង ៤៧.១២៤ហិកតា ៤៨អា ២៣សអ

– ការដោះស្រាយវិវាទដីធ្លីសរុបចំនួន ២១៩ករណី ស្មើនឹង ២៨៧គ្រួសារ មានផ្ទៃដីទំហំ ១.៥០២ហិកតា ៣៧អា ៦៤សអ បានច្រានចោលពាក្យបណ្តឹងចំនួន ១១៧ករណី ដោះស្រាយបញ្ចប់ចំនួន ៨៨ករណី និងកំពុងដោះស្រាយចំនួន ១៤ករណី

– បានចេញលិខិតអនុញ្ញាតសាងសង់ចំនួន ៨៩៩គម្រោង ដែលមានក្រឡាផ្ទៃសំណង់សរុបចំនួន ២.១២១.១១៤.៥៣$^{២}$ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគសរុបចំនួន ២២១.៣២៨.៤៥០,៣ដុល្លា បើធៀបនឹងឆ្នាំ២០១៦ គឺគម្រោងវិនិយោគកើនឡើងចំនួន ៥គម្រោង ផ្ទៃក្រឡាសំណង់ថយចុះសរុប ២៧.២១៦,៧៩ម$^{២}$ ដែលមានតម្លៃប៉ាន់ស្មានទុកវិនិយោគសរុប ៦.៣៣៣.០៨២ ដុល្លាអាមេរិក ថយចុះ ៣១%។

❖ **ការងារបរិស្ថាន និងអនាម័យ**

– បានចុះត្រួតពិនិត្យតាមបណ្តារោងចក្រ សហគ្រាស ទូទាំងក្រុង ស្រុក ពីការទុកសំណល់រឹងរាវ និងសំណល់ប្រកបដោយគ្រោះថ្នាក់ឱ្យមានការទុកដាក់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស

– បានចុះត្រួតពិនិត្យតាមដ្ឋានកិច្ចសន្យាការពារបរិស្ថានរបស់ រោងចក្រ សហគ្រាស អាជីវកម្មផ្សេងៗបានចំនួន ២៧កន្លែង ស្មើនឹង ១២លើក

– បានចុះត្រួតពិនិត្យ និងណែនាំដល់ម្ចាស់ស្ថានីយ៍ទឹកស្អាតទូទាំងក្រុង ស្រុកបានចំនួន ១៥លើក

– ចំណូលដែលបានមកពីការធ្វើកិច្ចសន្យាការពារបរិស្ថាន និងទាយជ្ជទានបរិស្ថានចំនួន ៥១៧.៧១៧.០០០ លានរៀល(ប្រាំរយដប់ប្រាំពីលានប្រាំពីររយដប់ប្រាំពីរពាន់រៀលគត់)

❖ **ការងារសាធារណការ និងកែលម្អសោភ័ណភាព**

**– បានថែទាំផ្លូវថ្នល់ប្រចាំកំណាត់ផ្លូវជាតិ និងផ្លូវខេត្ត (ផ្លូវក្រាលកៅស៊ូ) បានចំនួន ០៩ខ្សែ រួមមាន៖** ផ្លូវជាតិលេខ៣ ស្រោចកៅស៊ូកំទេចថ្មលើផ្ទៃដីថ្មលប្រេះ១ជាន់បាន ១២,៣២០ម$^{២}$ លប់សំបុកមាន់គ្រឹះ DBST បាន ៨៣០ម$^{២}$ កៀរចិញ្ចឹមផ្លូវបាន ១៩,៥០០ម៉ែត្រ ថែមដីគ្រួសក្រហម បាន៦៨០ម៉ែត្រ លុបសំបុកមាន់គ្រឹះចំរុះកៅស៊ូ ស៊ីម៉ង DBST បាន១០០០ម$^{២}$។ ផ្លូវជាតិ៤ លប់សំបុកមាន់ដោយកៅស៊ូអ៊ិតត្រជាក់បានចំនួន ៣,៨៨០ម$^{២}$ ស្រោចកៅស៊ូកំទេចថ្មលើផ្ទៃដីថ្មល់ប្រេះ ១ជាន់បាន ៣,៧៧០ម$^{២}$ ចាក់កៅស៊ូតម្រង់ចិញ្ចើមបាន ២,១០០ម$^{២}$ កៀរចិញ្ចើមសងខាងបានផ្លូវ ៨៧,៥០០ម៉ែត្រ ថែមគ្រួសក្រហម ៩,០៨០ម$^{២}$ សំអាតស្ពាន និងជួសជុលបន្ទាប់បន្សំ ១៩៥ម៉ែត្រ និងសំអាតរុក្ខជាតិបាន ៦៧,០០ម៉ែត្រ សំអាតប្រឡាយ ២៣,០០០ម៉ែត្រ

**– ការងារថែទាំកំណាត់ផ្លូវជាតិ និងផ្លូវខេត្ត (ក្រាលគ្រួសក្រហម) រួមមាន៖** ផ្លូវជាតិលេខ ៨៣ កៀរគ្រួសក្រហមបាន ១៨៥គ.ម ថែមគ្រួសបាន ១,២២០ម$^{៣}$ និងសំអាតរុក្ខជាតិបាន ២២,២០០ម៉ែត្រ ផ្លូវខេត្តទេសចរណ៍ភ្នំព្រះ កៀរគ្រួសក្រហមបាន ១៧៥គ.ម ថែមគ្រួស ១,៨៨០ម$^{៣}$ និងសំអាតរុក្ខជាតិបាន ១៩,៤០០ម៉ែត្រ។ ផ្លូវខេត្តសម្តេចនាយករដ្ឋមន្ត្រី កៀរគ្រួសក្រហមបានចំនួន ៨១៥គ.ម ថែមគ្រួសក្រហម បាន ២,០៧០ម$^{៣}$ និងសំអាតរុក្ខជាតិបាន ២៩,០០០ម៉ែត្រ។

– **ការងារចុះបញ្ជីយានយន្ត រួមមាន៖** បានចុះបញ្ជីយានយន្តបានចំនួន ១១,៨៣០គ្រឿង ត្រួតពិនិត្យលក្ខណៈបច្ចេកទេសបានចំនួន ៧,៧៧៧គ្រឿង ផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មដឹកជញ្ជូន ២,២៦៣គ្រឿង ផ្តល់ប័ណ្ណបើកបរ បានចំនួន ២,២៨៧ប័ណ្ណ ប្តូរប័ណ្ណបើកបរបានចំនួន ៣២៧ប័ណ្ណ ផ្ទេរកម្មសិទ្ធិ ១៨៣។

### ២.៤.៤- រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

#### ២.៤.៤.១- ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

បានចុះផ្សព្វផ្សាយការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ច្បាប់ពាក់ព័ន្ធ និងវេទិការសាធារណៈចំនួន ២.៩៣៦លើក លើ៨៧ឃុំ/សង្កាត់ និង៨ក្រុង/ស្រុក មានប្រជាជនចូលរួមចំនួន ៨៨៧០២៩.នាក់ ស្រី ២១៧៥០៩.នាក់ ដោយបានទទួលនូវបញ្ហានឹងសំណូមពរពាក់ព័ន្ធ និងសុវត្ថិភាពរបស់ភូមិ/ឃុំ យកមកធ្វើការដោះស្រាយបានទាន់ពេលវេលា។

#### ២.៤.៤.២- ការងារសន្តិសុខ

❖ **សភាពការណ៍បទល្មើសព្រហ្មទណ្ឌ៖** កើតមាន ៣៧/៥៩លើក ថយចុះចំនួន ២២លើក ក្នុងនោះ៖

– **បទឧក្រិដ្ឋ៖** កើតមាន ២០៣១/លើក ថយចុះ ១១លើក បណ្តាលឱ្យស្លាប់មនុស្ស ១០នាក់ ស្រី៣នាក់ របួស ៣នាក់ អស់ម៉ូតូ ៥គ្រឿង កាបូបដៃ ១ លោហធាតុព័ណ៌ខ្មៅ ២ដុំ និងមាស ៣០តម្លឹង។

– **បទមជ្ឈឹម៖** កើតមាន ១៧/២៨លើក ថយចុះ ១១លើក បណ្តាលឱ្យរបួសមនុស្ស ១១នាក់ ធ្ងន់ ៨នាក់ អស់ម៉ូតូ ៧គ្រឿង។

❖ **ការងារបង្ក្រាបបទលើសព្រហ្មទណ្ឌ៖** បង្ក្រាបបាន ៣២ករណី ឃាត់ខ្លួនជនល្មើស ៥៥នាក់ ស្រី ៣នាក់ បើធៀបនឹងសភាពការណ៍ស្មើនឹង ៨៦,៨៨% រួមមាន៖

– **បង្ក្រាបជាក់ស្តែង៖** បានចំនួន ២២ករណី ឃាត់ខ្លួនជនល្មើស ៣៨នាក់ ស្រី ១នាក់

– **បង្ក្រាបដោយស៊ើបអង្កេត៖** បានចំនួន ១០ករណី ឃាត់ខ្លួនជនល្មើស ១៧នាក់ ស្រី ២នាក់

– **បង្ក្រាបតាមដីកា៖** បានចំនួន ១៤ករណី ឃាត់ខ្លួនជនសង្ស័យ ១៤នាក់ បទឧក្រិដ្ឋ ១ករណី ឃាត់ខ្លួន ១នាក់ និងបទមជ្ឈឹម ១៣ករណី ឃាត់ខ្លួន ១៣នាក់។

– បង្ក្រាបករណីលែងល្បែងស៊ីសង ១៨ករណី ឃាត់ខ្លួនមុខសញ្ញាចំនួន ៦៧នាក់ ស្រី ១៣នាក់ ក្នុងនោះ៖ អប់រំធ្វើកិច្ចសន្យាចំនួន ១៤ករណី មនុស្ស ៥៤នាក់ ស្រី ១១នាក់ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ៤ករណី មនុស្ស ១៣នាក់ ស្រី ២នាក់។

❖ **ការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**

– បានផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ និងច្បាប់ឯកព័ន្ធភាពបានចំនួន ១.២៨១លើក មានប្រជាពលរដ្ឋចូលរួមចំនួន ១៦១.០២៧នាក់ ស្រី ៧៨.៨៧៨នាក់។

– ទទួលពាក្យបណ្តឹង ៩ការណី (ករណីជួញដូរឆ្លងដែន ១ករណី ទៅប្រទេសចិន បាត់កូន ៨ករណី (បាត់ក្មេងស្រី) បានស្រាវជ្រាវរកឃើញចំនួន ៥ករណី បានធ្វើការអប់រំណែនាំរួចប្រគល់ជូនអាណាព្យាបាលគ្រប់គ្រងបន្ត និង ៣ករណី ទៀតកំពុងស្រាវជ្រាវ។

– បានចុះត្រួតពិនិត្យទីតាំងហាងខារ៉ាអូខេ ក្នុងភូមិសាស្ត្រក្នុងក្រុងច្បារមនចំនួន ៨២លើក និងបានធ្វើការអប់រំ និងធ្វើកិច្ចសន្យាជាមួយម្ចាស់ហាងហាមមិនឱ្យទទួលយកក្មេងក្រោមអាយុ ១៨ឆ្នាំមកបម្រើការងារ។

❖ **ការងារប្រឆាំងបទល្មើសគ្រឿងញៀន**

– **បង្ក្រាបជាក់ស្តែង៖** បានចំនួន ១៧១លើក ឃាត់ខ្លួនមុខសញ្ញាចំនួន ៤៤៣នាក់ ស្រី ៣៤នាក់ ក្នុងនោះ ករណីជួញដូរ និងចែកចាយចំនួន ១៤៧ករណី មុខសញ្ញា ៣២២នាក់ ស្រី ២៩នាក់ និងបទប្រើប្រាស់ចំនួន ២៤ករណី មុខសញ្ញា ១២១នាក់ ស្រី ៥នាក់ ដកហូតគ្រឿងញៀន ១១៥៤កញ្ចប់ ទម្ងន់ ៦៦០,០៦ក្រាម ជញ្ជីងថ្លឹង២២ ម៉ូត ១១៦គ្រឿង រថយន្ត ៧គ្រឿង ទូរស័ព្ទ ២៧៥គ្រឿង ប្រាក់ចំនួន ៥៩០.០០០រៀល និង ១៣៧ដុល្លារ អាវុធខ្លី ២ដើម និងឧបករណ៍ប្រើប្រាស់មួយចំនួនទៀត។

– **បង្រាប់តាមដីកា៖** បានចំនួន ២៦ករណី ឃាត់ខ្លួនជនល្មើស ២៦នាក់ ស្រី ២នាក់ និងបញ្ជូនមុខសញ្ញាប្រើប្រាស់គ្រឿងញៀន ៤១១នាក់ ស្រី ១៦នាក់ ទៅមណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន។

**២.៤.៤.៣- ការងារសណ្តាប់ធ្នាប់សាធារណៈ និងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក**

❖ **ការងារចរាចរណ៍**

– បានចុះផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកថ្មីចំនួន ២២៧លើក មានអ្នកចំនួន ៧២.០៧៨នាក់ ស្រី ៣៧.៧១៦នាក់

– បានចាត់តាំងកម្លាំងចុះអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកក្នុងក្រុង/ស្រុក ទាំង ៨ ដោយបានត្រួតពិនិត្យរថយន្តឆ្លងកាត់ចំនួន ១១០.១៤០គ្រឿង ផាកពិន័យរថយន្ត ១០៥គ្រឿង ម៉ូតូឆ្លងកាត់

ចំនួន ៩៥.៦៩២គ្រឿង ផាកពិន័យ ៥.១៨០គ្រឿង។ ទឹកប្រាក់បានពីការផាកពិន័យសរុបចំនួន ១៣០.៩៦៩.០០០លានរៀល។

❖ **សភាពការណ៍គ្រោះថ្នាក់សង្គមៈ**

– **គ្រោះថ្នាក់ចរាចរណ៍ៈ** កើតមានចំនួន ១៧៧/១៧៤លើក កើនឡើង ៣លើក បណ្ដាលឱ្យស្លាប់មនុស្ស ១១៣/១២៥នាក់ ស្រី ១៩/៣២នាក់ របួស ៩៣/៣៧៩នាក់ ស្រី ១៥៧/២១២នាក់ ខូចខាតរថយន្ត ១៩៣គ្រឿង និងម៉ូតូ ១៧២គ្រឿង និងយានផ្សេងៗ ៩គ្រឿង។

– **គ្រោះថ្នាក់សង្គមផ្សេងៗៈ** កើតមាន ១៥០/១៧២លើក ថយចុះ ២២លើក បណ្ដាលឱ្យស្លាប់មនុស្ស ១៩៥នាក់ ស្រី ៧៩នាក់ របួស ៨៩នាក់ រងគ្រោះ ៨៧នាក់ ស្រី ៦៩នាក់ រួមមានៈ ករណីខ្យល់ព្យុះ ១លើក របួស ១នាក់ របើកដំបូល ១ខ្នង ករណីទឹកជំនន់ ១ករណី លិចផ្ទះ ៣០ខ្នង ដាច់ផ្លូវ ១កន្លែង ករណីរន្ទះបាញ់ ១ករណី ងាប់គោ ៥ក្បាល។

## ២.៥- ចំណុចខ្សោយក្នុងការអនុវត្តការងារ

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបានគួរជាមោទនៈភាពខាងលើ ក៏មានបញ្ហាប្រឈមមួយចំនួនផងដែរដែលត្រូវយកចិត្តទុកដាក់ និងដោះស្រាយឱ្យបានល្អនាពេលខាងមុខជាអាទិ៍ៈ

– ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋក៏មិនទាន់បានឆ្លើយតប និងមានប្រសិទ្ធិភាពតាមសំណូមពរ

– គម្រោងដែលដាក់ឱ្យអនុវត្តមិនសម្រេចតាមផែនការ ដោយសារតែបណ្ដាលមកពីការសិក្សាគម្រោងយឺតពេក

– បញ្ហាសន្តិសុខ សុវត្ថិភាពសណ្ដាប់ធ្នាប់សង្គម ក៏នៅមិនទាន់ធានាបានល្អតាមសំណូមពររបស់ប្រជាពលរដ្ឋ ជាពិសេសលក្ខណៈទាំងប្រាំរបស់គោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពនៅពុំទាន់ឆ្លើយតបតាមស្តង់ដារនៅឡើយ

– សមត្ថភាពមន្ត្រីនៅមានកម្រិត ដែលទាមទារឱ្យរៀនបណ្ដើរ ធ្វើបណ្ដើរដែលជាហេតុធ្វើឱ្យកិច្ចការមួយចំនួនមានភាពយឺតយ៉ាវ និងប្រសិទ្ធិភាពទាប

– ហេដ្ឋារចនាសម្ព័ន្ធ រូបវន្តមួយចំនួននៅតាមស្រុក ដែលរងគ្រោះនូវទឹកជំនន់ក្នុងរដូវវស្សាកន្លងមកបានទទួលរងនូវការខូចខាតដែលតម្រូវឱ្យមានការជួសជុលជាបន្ទាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ជារៀងរាល់ថ្ងៃរបស់ប្រជាពលរដ្ឋ

– វារីអគ្គីសនីខ្នាតតូចភ្ជាប់ជាមួយគម្រោងស្រោចស្រពចំនួន ២កន្លែង សាងសង់ និងគ្រប់គ្រងគម្រោងដោយក្រសួងធនធានទឹកមិនទាន់មានគោលការណ៍ឯកភាពពីក្រសួងរ៉ែ និងថាមពល អំពីភាពអនុឡោមផ្នែកស្តង់ដារ និងបច្ចេកទេសនៅឡើយ

– សាលាក្រុង ស្រុក និងមន្ទីរ អង្គភាពជុំវិញខេត្ត ឆ្លើយតបនឹងលិខិតរបស់សាលាខេត្តមិនទាន់ពេលវេលា ឬត្រូវបានបំភ្លេចចោលតែម្តង

– បញ្ហាកង្វះច្បាប់ក្នុងការអនុវត្ត ដូចជាច្បាប់ស្តីពីហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និងនីតិវិធីក្នុងការអនុវត្តការងារពុំមានលក្ខណៈស្តង់ដា

– ទម្រង់នៃការធ្វើដីកា និងនីតិវិធីទាក់ទងនឹងកិច្ចប្រជុំ ព្រមទាំងរបៀបធ្វើរបាយការណ៍ពុំទាន់មានលក្ខណៈត្រឹមត្រូវ

– ការយល់ដឹងប្រជាពលរដ្ឋនៅមានកម្រិតទាប ព្រមទាំងទំលាប់ចាស់របស់ប្រជាពលរដ្ឋជាឧបសគ្គដល់ការលើកស្ទួយជីវភាព ដូចជាប្រជាពលរដ្ឋភាគច្រើននៅតែបង្កបង្កើនផលស្រូវតាមរបៀបបុរាណ ទន្ទឹមនឹងការខ្វះខាតប្រព័ន្ធធារាសាស្រ្ត ប្រជាកសិករនៅពឹងផ្អែកទឹកភ្លៀងក្នុងការស្រោចស្រពលើដំណាំកសិកម្ម។

# ជំពូកទី ៣
# គោលនយោបាយ និងសកម្មភាព
# អាទិភាពសម្រាប់ឆ្នាំ២០១៨-២០១៩

# ជំពូកទី ៣

# គោលនយោបាយ និងសកម្មភាពអាទិភាពសម្រាប់ឆ្នាំ ២០១៨-២០១៩

## ៣.១- យុទ្ធសាស្ត្រអភិវឌ្ឍន៍

ឆ្នាំ២០១៨ គឺជាឆ្នាំទី៥ នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់ការទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាឱ្យបានទទួលបានជោគជ័យក្នុងនោះ៖ គឺការអនុវត្តកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ហើយក៏ជាឆ្នាំ ដែលត្រូវខិតខំយ៉ាងណាធានាឱ្យបាននូវស្ថេរភាពនយោបាយ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម។ ក្នុងន័យដើម្បីសម្រេចបានគោលដៅខាងលើ រដ្ឋបាលខេត្តកំពង់ស្ពឺ បានដាក់ចេញនូវទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២១០១៨ ដូចជា៖ ការងាររដ្ឋបាលដែនដី ការងារគ្រប់គ្រងសេដ្ឋកិច្ច ការងារគ្រប់គ្រងសង្គមកិច្ច ការងារគ្រប់គ្រងដីធ្លី សាធារណការ និងកែលម្អសោភ័ណភាព និងការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

### ៣.១.១- ការងាររដ្ឋបាលដែនដី

ជាលទ្ធផលខេត្តកំពង់ស្ពឺ បានសម្រេចលទ្ធផលពីការងាររបស់ខ្លួន លើការងាររដ្ឋបាលដែនដីមួយចំនួន៖ ការងារគ្រប់គ្រងប្រជាពលរដ្ឋ ការងារទីចាត់ការផែនការ និងវិនិយោគ ការងារគ្រប់គ្រងមន្ត្រីរាជការ(ទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត)

❖ **ការងារគ្រប់គ្រងប្រជាពលរដ្ឋ**

– ការបន្តចរាចរណ៍លិខិតរដ្ឋបាលនានាឱ្យបានទាន់ពលវេលា

– ការបន្តជំរុញ និងពង្រឹងការអនុវត្តការងារអត្រានុកូលដ្ឋាននៅតាមមូលដ្ឋានឃុំ សង្កាត់ទូទាំងខេត្ត និងបានបន្តដោះស្រាយនូវបញ្ហានានាដែលកើតមានពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន និងជំរុញធ្វើអត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរជូនប្រជាពលរដ្ឋ ដើម្បីបម្រើដល់ការបោះឆ្នោតសភានាពេលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខ

– ការបន្តការគ្រប់គ្រងឱ្យបាននូវការចេញចូលរបស់ប្រជាពលរដ្ឋ នៅគ្រប់មូលដ្ឋានពិសេសការស្នាក់នៅបណ្តោះអាសន្ន។

❖ **ការងារទីចាត់ការផែនការ និងវិនិយោគ**

– ខិតខំរៀបចំរបាយការណ៍ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រីមាសទី១ ឆ្នាំ២០១៨ ឱ្យបានទាន់ពេលដើម្បីផ្ញើទៅលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

– បន្តតាមដានការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧ និងឆ្នាំ២០១៨

– រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី

– ការបន្តផ្តល់សេវាគ្រប់វិស័យជូនប្រជាពលរដ្ឋ និងអតិថិជនតាមប្រតិភូកម្មពីរាជរដ្ឋាភិបាល ឱ្យបានទាន់ពេលវេលា មានតម្លាភាព និងគុណភាពខ្ពស់

– ពង្រឹងការងារគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

– អនុវត្តឱ្យបានសម្រេចនូវផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩។

❖ **ការងារគ្រប់គ្រងមន្ត្រីរាជការ (ទីចាត់ការការគ្រប់គ្រងធនធានមនុស្ស)**

– ពិនិត្យបច្ចុប្បន្នភាពរបស់មន្ត្រីរាជការក្នុងតារាងព័ត៌មានវិទ្យា

– ត្រៀមរៀបចំឯកសារសំណើសុំតែងតាំងបំពេញបន្ថែមក្នុងរចនាសម្ព័ន្ធរបស់សាលាខេត្ត ក្រុង ស្រុក និងមន្ទីរជុំវិញខេត្ត

– ត្រៀមបើកវគ្គបណ្តុះបណ្តាលការងាររដ្ឋបាលដល់មន្ត្រីសាលាខេត្ត ក្រុង ស្រុក

– ស្រាវជ្រាវបន្ថែមទៅលើឯកសារដែលពាក់ព័ន្ធ និងការបើកវគ្គបណ្តុះបណ្តាល។

### ៣.១.២- ការងារគ្រប់គ្រងសេដ្ឋកិច្ច

❖ **ការងារកសិកម្ម**

– ការបន្តបង្កើនផ្ទៃដីដាំដុះរដូវប្រាំង រដូវវស្សា និងផ្ទៃដីស្រូវបង្កើនរដូវ ជំរុញផ្សព្វផ្សាយពូជស្រូវ និងបច្ចេកទេសកសិកម្មដល់កសិករដើម្បីបង្កើនទិន្នផលសម្រាប់ការនាំចេញអង្កររបស់រាជរដ្ឋាភិបាល

– បន្តត្រួតពិនិត្យអនាម័យសត្វ និងសាច់នៅតាមទីសត្តឃាតដ្ឋាន និងទីផ្សារ

– ការបន្តរៀបចំវគ្គបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វតាមភូមិ និងបន្តជំរុញការងារចាក់ថ្នាំការពារជម្ងឺឆ្លងដល់សត្វ

– ការបន្តអនុវត្តបទដ្ឋានបច្ចេកទេស និងច្បាប់ពាក់ព័ន្ធទៅនឹងការងារកសិកម្មបសុព្យាបាល និងនីតិកម្មកសិកម្ម

– ការបន្តចុះពិនិត្យមូលដ្ឋានការធ្វើអាជីវកម្ម សម្ភារៈកសិកម្ម និងមានវិធានការផ្លូវច្បាប់ចំពោះជនប្រព្រឹត្តបទល្មើស។

❖ **ការងាររដ្ឋបាលជលផល**

– ការបន្តបង្ក្រាបទល្មើសនេសាទដែលកើតមានឡើង និងជំរុញចុះផ្សាយបច្ចេកទេសចិញ្ចឹមត្រីដល់ប្រជាពលរដ្ឋ ក្នុងការចិញ្ចឹមត្រីក្នុងស្រះបែបក្នុងស្រះខ្នាតតូច ក្រោលថង់ប្លាស្ទិក ឬថង់កៅស៊ូ និងការចិញ្ចឹមជន្លេនសម្រាប់ជាចំណីត្រី

– បន្តចុះពិនិត្យស្ថានភាពស្រះជម្រកត្រីសហគមន៍ និងចុះស្រង់ស្ថិតិកូនត្រីពូជ។

❖ **ការងាររដ្ឋបាលព្រៃឈើ**

– ការបន្តជំរុញការដាំដុះ ចែកចាយកូនឈើ ថែទាំ និងការពារកូនឈើដែលដាំរួចហើយ

– បន្តការស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបអ្នកដែលបានកាប់រានដុតឈូសឆាយដីព្រៃឈើ ដើម្បីរាតយកធ្វើកម្មសិទ្ធិ និងរៀបចំបំពេញបែបបទស្នើសុំប័ណ្ណកម្មសិទ្ធិចំពោះដីដែលអង្គភាពក្រោមឱវាទកំពុងគ្រប់គ្រង និងប្រើប្រាស់នាពេលបច្ចុប្បន្ន

– បន្តពង្រឹងការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃគ្រប់ប្រភេទ។

❖ **ការងារធនធានទឹក និងឧតុនិយម**

– បន្តជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រសម្រាប់ផែនការឆ្នាំ២០១៨

– បន្តសហការជាមួយក្រុមការងារបច្ចេកទេសរបស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការត្រួតពិនិត្យកិច្ចដំណើរការ និងអភិវឌ្ឍប្រព័ន្ធក្រាំងពន្លៃ ស្ទឹងព្រែកត្នោត ស្ទឹងស្លាគូ

– បន្តចែកចាយទឹកតាមប្រឡាយមេរលាំងជ្រៃខាងជើង និងប្រឡាយមេរលាំងជ្រៃខាងត្បូង ស្រុកសំរោងទង ស្រុកគងពិសី និងក្រុងច្បារមន ដើម្បីផលិតស្រូវរដូវប្រាំង ដើមរដូវ និងរដូវវស្សា

– ត្រៀមម៉ាស៊ីនអន្តរាគមន៍បូមទឹកសម្រាប់បូមសង្គ្រោះស្រូវរដូវវស្សា ដែលជួបប្រទះគ្រោះរាំងស្ងួតនៅចុងរដូវវស្សា

❖ **ការងារអភិវឌ្ឍជនបទ**

– ការបន្តអនុវត្ត និងគាំទ្រកម្មវិធីផ្គត់ផ្គង់ទឹកស្អាតអនាម័យ និងថែទាំសុខភាពជូនប្រជាពលរដ្ឋនៅជនបទ

– បន្តការអនុវត្តន៍ការងារផ្លូវថែទាំលក្ខណៈខួបចំនួន ១៤ខ្សែប្រវែង៦.៦៣គ.ម លក្ខណៈប្រចាំចំនួន ៨ខ្សែ ប្រវែង ៥.៧៨៥គ.ម និងការងារជួសជុលក្រួសក្រហម(គម្រោងបន្ទាន់)ចំនួន ៤ខ្សែ ប្រវែង ២០គ.ម

– បន្តធ្វើបច្ចុប្បន្នភាពបញ្ជីសោពើភ័ណ្ឌផ្លូវជនបទចំនួន ៩៦ខ្សែ ប្រវែង ៥២.៥៨គ.ម។

❖ **ការងារឧស្សាហកម្ម និងសិប្បកម្ម**

– បន្តជំរុញដល់អាជីវករ ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម ដែលប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ឱ្យដាក់ពាក្យស្នើចុះបញ្ជីមាត្រាសាស្ត្រនៅច្រកចេញចូលតែមួយរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

– បន្តយកសំណាកផលិតផលតាមបណ្តារោងចក្រ សហគ្រាស សិប្បកម្ម ទៅពិនិត្យផ្នែកមីក្រូជីវសាស្ត្រចំណីអាហារ និងផ្នែកគីមីសាស្ត្រ

– បន្តធ្វើបច្ចុប្បន្នភាពសិប្បកម្ម កត់ត្រាស្ថិតិ (សិប្បកម្មលើកលែងការចុះបញ្ជី)។

❖ **ការងារពាណិជ្ជកម្ម**

– បន្តកិច្ចសហប្រតិបត្តិការជាមួយសាខាកាំកុលត្រួលដើម្បីត្រួតពិនិត្យគុណភាព និងសុវត្ថិភាពទំនិញលើទីផ្សារ

– បន្តកិច្ចសហការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធ ដោយស្វ័យប្រវត្តិដល់បណ្តាក្រុមហ៊ុនសហគ្រាស

– បន្តការផ្សព្វផ្សាយ និងអនុវត្តផ្តល់សេវាសាធារណៈលើការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មដល់មូលដ្ឋាន។

❖ **ការងារសាខាធនាគារជាតិខេត្ត**

– បន្តអនុវត្តមុខងារជាអាជ្ញាធររូបិយវត្ថុ សាខាចាំបាច់គឺដើរតួនាទីជាអ្នកសម្របសម្រួលចរាចរណ៍រូបិយវត្ថុជាតិ និងផ្គត់ផ្គង់សាច់ប្រាក់ឱ្យធានាពាណិជ្ជប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ព្រមទាំងអង្គការ ក្រុមហ៊ុន និងសាធារណៈជនដើម្បីសំដៅស្ថិរភាពថ្លៃ និងបង្កើនជំនឿទុកចិត្តមកលើប្រាក់រៀល

– ជំរុញការងារប្តូរប្រាក់រហែក រិចរឹល ដែលបាននឹងកំពុងចរាចរណ៍នៅលើទីផ្សារ។

❖ **ការងារពន្ធដារ**

– ខិតខំប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទឆ្នាំ២០១៨

– ប្រមូលពន្ធអចលនទ្រព្យសម្រាប់ឆ្នាំ២០១៨

– បន្តធ្វើជំរឿនសហគ្រាសតម្រឹមផលរបរ និងបញ្ជូនសហគ្រាសកើតថ្មីក្នុងពន្ធដារ

– បន្តធ្វើសវនកម្មមានកម្រិតលើសហគ្រាស ដែលមានហានិភ័យ និងការដាក់អនុវត្តប្រព័ន្ធសវនកម្ម (ព័ត៌មានវិទ្យា) របស់អគ្គនាយកដ្ឋានពន្ធដារ។

❖ **ការងារទេសចរណ៍**

– ត្រៀមបើកវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសទេសចរណ៍ថ្នាក់សហគមន៍ នៅលើភ្នំគិរីរម្យ ដោយសហការជាមួយក្រសួងទេសចរណ៍ពេលឆាប់ៗខាងមុខនេះ

– ចុះត្រួតពិនិត្យអនាម័យនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន និងជំរុញការផ្សព្វផ្សាយកម្ពុជាព្រះរាជាណាចក្រកម្ពុជាអច្ឆរិយៈ និងជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីដ្ឋានស្អាត សេវាល្អ និងស្ប៉ាតអប់រំស្តីពីភោជនីដ្ឋានស្អាត អាហារដ្ឋានស្អាត សេវាល្អ។

### ៣.១.៣ ការងារគ្រប់គ្រងសង្គមកិច្ច

❖ **ការងារអប់រំ យុវជន និងកីឡា**

– ជំរុញក្មេងដែលដល់អាយុចូលរៀនឱ្យបានគ្រប់គ្នាៗ និងការយកចិត្តទុកដាក់ក្នុងការផ្តល់អាហារូបការណ៍សិស្សក្រីក្រមធ្យមសិក្សា

– ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបន្ថែម និងការអប់រំក្រៅប្រព័ន្ធ កាត់បន្ថយអត្រាអក្ខរភាព

– ជំរុញសិស្សបោះបង់ការសិក្សាដែលបំប៉នរួចឱ្យបានចូលរៀនក្នុងប្រព័ន្ធវិញឱ្យបាន ៩៧%

– ជំរុញការពិគ្រោះយោបល់ជួយកុមារ និងកុមារងាយរងគ្រោះ

– ជំរុញសកម្មភាពបណ្ណាល័យឱ្យដំណើរការ។

❖ **ការងារសុខាភិបាល**

– គ្រប់មន្ទីរពេទ្យ មណ្ឌលសុខភាព ការិយាល័យក្រោមឱវ៉ាត និងកម្មវិធីទាំងអស់នឹងអនុវត្តបន្តនូវសកម្មភាពទៅតាមផែនការប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីសម្រេចឱ្យបានគោលដៅដែលបានដាក់ចេញ

– ធានាឱ្យបានសេវាសុខភាពសាធារណៈ មានប្រសិទ្ធភាព ស័ក្តសិទ្ធិ កាត់បន្ថយការចំណាយប្រាក់ហោប៉ៅប្រជាជន និងឆ្លើយតបតម្រូវការឆាប់រហ័ស ដោយអនុវត្តផែនការសកម្មភាព ការងារផែនការ ការពង្រឹងមូលដ្ឋានសុខាភិបាលបុគ្គលិក(ក្រមសីលធម៌ និងបច្ចេកទេសផ្តល់សេវា) និងហេដ្ឋារចនាសម្ព័ន្ធ។

❖ **ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

– បន្តផ្សព្វផ្សាយដល់ជនពិការឱ្យមកទទួលសេវា និងស្វែងរកដៃគូដើម្បីជួយបណ្តុះបណ្តាលវិជ្ជាជីវៈដល់មុខសញ្ញាពិការ និងផលិតជូសជុលអវយវៈសិប្បនិម្មិត

– បន្តស្រាវជ្រាវកុមារកំព្រារងគ្រោះគ្រប់ប្រភេទនៅតាមសហគមន៍ ដើម្បីស្វែងរកសេវាជួយដល់ពួកគេ និងស្វែងរកកុមារីរងគ្រោះពីការជួញដូរ និងរំលោភបំពាន

– បន្តអប់រំដល់ក្មេងអំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ជម្ងឺអេដស៍ ជម្ងឺផ្សេងៗ និងផលប្រយោជន៍ការនៃការប្រើស្រោមអនាម័យ

– បន្តបញ្ជូនជនពិការឱ្យទៅស្តារលទ្ធភាពពលកម្ម(រោងជាង)

❖ **ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ**

– ជំរុញការធ្វើសៀវភៅការងារជនកម្ពុជា និងបរទេសដើម្បីប្រមូលអាករបង់ចូលថវិកាជាតិ

– បន្តរៀបចំកម្មវិធីចុះអធិការកិច្ចតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន និងតាមដានសកម្មធ្វើកូដកម្មរបស់កម្មករ សហជីព តាមបណ្តារោងចក្រ សហគ្រាស

– សហការជាមួយរោងចក្រ សហគ្រាស គ្រឹះស្ថាន ដើម្បីជំរុញកាតព្វកិច្ច ហ្វឹកហ្វឺនកូនជាង

– បន្តសិក្សាស្រាវជ្រាវមុខរបរជាអទិភាពតាមតម្រូវការទីផ្សារការងារក្នុងមូលដ្ឋាន

– បន្តជំរុញការគ្រប់គ្រងរបបធានារ៉ាប់រងហានិភ័យការងារ។

❖ **ការងារព័ត៌មាន**

– ជំរុញការចុះយកព័ត៌មានតាមមូលដ្ឋាន និងនិពន្ធអត្ថបទដើម្បីបញ្ជូនទៅផ្សព្វផ្សាយតាមបណ្តាព័ត៌មានឱ្យបានលឿន និងទាន់ហេតុការណ៍

– បន្តបញ្ជូនមន្ត្រីចូលរួមវគ្គសិក្សាអំពីគន្លឹះ និងបទពិសោធន៍ដែលពាក់ព័ន្ធទៅនឹងវិស័យព័ត៌មាន

❖ **ការងារកិច្ចការនារី**

– បន្តការពិនិត្យ និងពង្រឹងសមត្ថភាពអ្នកទទួលបន្ទុកកិច្ចការនានារបស់ឃុំ សង្កាត់ ពង្រឹងសមត្ថភាពការងារបញ្ជ្រាបបញ្ហាយេឌ័រដល់មន្ត្រីកិច្ចការនារីខេត្ត

– បន្តរៀបចំវេទិការសហគមន៍លើកកម្ពស់សីលធម៌សង្គម តម្លៃស្រី និងគ្រួសារខ្មែរ

– បន្តរៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីបណ្តាញក្រុមការងារ អ្នកផ្តល់សេវាកម្មជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្ត និងពង្រឹងក្រុមបណ្តាញពីតួនាទីភារកិច្ច

– បន្តសហការ និងស្វែងរកស្ថាប័នពាក់ព័ន្ធ អង្គការនានាក្នុងការផ្តល់សេវាជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

❖ **ការងារធម្មការ និងសាសនា**

– បន្តពង្រឹងវិស័យព្រះពុទ្ធសាសនានាប្រតិបត្តិវិន័យឱ្យបានម៉ត់ចត់តាមពុទ្ធបញ្ញត្តិ ជំរុញការរៀបចំរចនាសម្ព័ន្ធមន្ត្រីសង្ឃតាមបញ្ញត្តិវត្តដែលមិនទាន់បានរៀបចំតែងតាំង

– បន្តខិតខំសហការដោះស្រាយអធិការណ៍ដែលនៅសេសសល់

– បន្តការរៀបចំបុណ្យប្រពៃណីជាតិនានាឱ្យបានល្អប្រសើរ និងអធិកអធម

– បន្តជំរុញលោកអាចារ្យឱ្យមកដាក់ពាក្យចូលរៀន និងដាក់ពាក្យចូលសមាគមន៍អាចារ្យខ្មែរ។

## ៣.២- ការងារគ្រប់គ្រងដីធ្លី សាធារណការ និងកែលម្អសោភ័ណភាព

❖ **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

– បន្តការអនុវត្តការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នៅតាមបណ្តាស្រុកគោលដៅ និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ និងបន្តធ្វើការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ

– ចុះត្រួតពិនិត្យ និងស្រង់ទិន្នន័យសំណង់ខុសច្បាប់ និងគ្មានច្បាប់អនុញ្ញាតសាងសង់

– បន្តការអនុវត្តការងាររៀបចំសម្រាប់សម្បទានដីគោលដៅសង្គមកិច្ច សេដ្ឋកិច្ច និងបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារប្រជាពលរដ្ឋក្រីក្រគ្មានដីពិតប្រាកដ។

❖ **ការងារសាធារណការ និងកែលម្អសោភ័ណភាពខេត្ត**

– បន្តស្តាបនាជួសជុល និងថែទាំផ្លូវ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធនានាដែលបានបម្រើដល់វិស័យសាធារណការ និងដឹងជញ្ជូនក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ ព្រមទាំងបន្តយកចិត្តទុកដាក់ត្រួតពិនិត្យលើយានយន្តដឹកលើទម្ងន់កម្រិតកំណត់អតិបរមា ដើម្បីការពារស្ពាន ថ្នល់ និងលូឱ្យគង់វង្សយូរអង្វែង

– បន្តជំរុញដល់ម្ចាស់យានយន្ត ឱ្យបំពេញកាតព្វកិច្ចគ្រប់ៗគ្នាធ្វើការត្រួតពិនិត្យលក្ខណ:បច្ចេកទេសយានយន្ត និងការចេញប័ណ្ណបើកបរទោចក្រយានយន្តជូនប្រជាពលរដ្ឋប្រើប្រាស់។

## ៣.៣- ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

❖ **ការងារអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព**

– បន្តការពង្រឹងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ-សង្កាត់ និង ពង្រឹងកម្លាំងប្រជាការពារ

– ការបន្តយកចិត្តទុកដាក់ស្រាវជ្រាវ ដើម្បីទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសឧក្រិដ្ឋ និងមជ្ឈឹម ដើម្បីលើកកម្ពស់សន្តិសុខ សុវត្ថិភាពភូមិ-ឃុំ

– ការបន្តជំរុញការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យសកម្ម ដោយត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយអប់រំទូលាយអំពីច្បាប់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀនដល់ប្រជាពលរដ្ឋ។

❖ **ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណ: និងចរាចរណ៍**

– បង្កើនការយកចិត្តទុកដាក់ក្តាប់សភាពការណ៍កូដកម្ម និងបាតុកម្មរបស់កម្មករនៅតាមបណ្តាលរោងចក្រ និងការតវ៉ាពីសំណាក់ប្រជាពលរដ្ឋ ឬសំណូមពរបញ្ហាផ្សេងៗតាមបណ្តាស្រុកក្រុង ក្នុងខេត្ត

– ការបន្តសកម្មភាពរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក តាមរយ:បង្កើនការផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីច្បាប់ចរាចរណ៍ផ្លូវគោកសំដៅទៅរកការកែប្រែឥរិយាបថ និងទម្លាប់មកជាការគោរពច្បាប់

– ការបន្តចាត់វិធានការរឹតបន្តឹងចំពោះការបើកបរដោយមានជាតិស្រវឹង បើកបរលើសល្បឿនកំណត់ និងលុបបំបាត់ឱ្យបានសកម្មភាពដឹងសំពីងសំពោងផ្ទុកលើសទម្ងន់ប្រើប្រាស់យាន-យន្តខុសបទដ្ឋានបច្ចេកទេសព្រមជាមួយនោះត្រូវណែនាំអប់រំមឹងម៉ាត់ ចំពោះមន្ត្រីនគរបាលចរាចរណ៍ឱ្យអនុវត្តត្រឹមត្រូវតាមតួនាទី ភារកិច្ចរបស់ខ្លួន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ តាំងពីដើមរហូតដល់ចប់ គឺធ្វើក្រុមយើងខ្ញុំយល់ដឹងយ៉ាងច្បាស់អំពីរចនាសម្ព័នរបស់ខេត្តកំពង់ស្ពឺ ព្រមទាំងតួនាទី និងភារកិច្ច របស់អាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់តាំងពីក្រុមប្រឹក្សាខេត្ត អភិបាលនៃគណៈអភិបាលខេត្ត រហូតដល់ថ្នាក់ក្រោម និងយល់ដឹងរឹតតែច្បាស់អំពីរបៀបរបបធ្វើការងាររបស់មន្ត្រីរាជការ និងទំនាក់ទំនងការងាររវាងក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងមន្ទីរអង្គភាពនានាទាំងអស់ជុំវិញខេត្ត។

ក្នុងឆ្នាំ២០១៨នេះ យើងឃើញថាមន្ត្រីរាជការ អាជ្ញាធរគ្រប់ជាន់ថ្នាក់របស់ខេត្តកំពង់ស្ពឺបាន ខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការជំរុញការងារអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋ ដោយបានសហការយ៉ាងកក់ក្តៅជាមួយមន្ទីររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈព្រមទាំងបានពង្រឹងកិច្ចការពារសន្តិសុខសុវត្ថិភាព។ ជាពិសេស អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងខេត្តមានការមមាញឹកយ៉ាងខ្លាំងក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់មូលដ្ឋាន និងការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលតាមរយៈការណែនាំរបស់ក្រសួងមហាផ្ទៃ។

លើសពីនេះទៅទៀត សាលាខេត្តកំពង់ស្ពឺបានសម្រេចការងាររបស់ខ្លួនជាទីមោទនៈទៅលើការងារមួយចំនួនដូចជា៖ ការងារគ្រប់គ្រងរដ្ឋបាលដែនដី គឺខេត្តកំពង់ស្ពឺបានយកចិត្តទុកដាក់ក្នុងការចុះបញ្ជីស្នាក់នៅ ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ និងផ្តល់អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋសម្រេចបានយ៉ាងល្អប្រសើរ និងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលបានធ្វើឱ្យកំណែទម្រង់ អភិបាលកិច្ចនៅថ្នាក់មូលដ្ឋានក្រុង ស្រុក ឃុំ សង្កាត់ កាន់តែចម្រើនថ្មីជាបន្តបន្ទាប់ ហើយទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗស្របតាមការណែនាំពីថ្នាក់ជាតិ។ ទន្ទឹមនឹងនេះដែរការធ្វើសមាហរណកម្ម រចនាសម្ព័ន្ធ និងមន្ត្រីរាជការបច្ចុប្បន្នចូលទៅក្នុងរចនាសម្ព័នថ្មីស្របទៅតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ម៉្យាងវិញទៀតការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក បានរួមចំណែកធ្វើឱ្យគ្រោះថ្នាក់ត្រូវបានកាត់បន្ថយ។ ចំណែកឯការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន រូបវន្តផ្លូវ ស្ពាន ថ្នល់មានការតភ្ជាប់ពីភូមិមួយទៅភូមិមួយ ដែលជាសរសៃឈាមនៃសេដ្ឋកិច្ចសម្រាប់ប្រជាពលរដ្ឋធ្វើដំណើរ និងដឹកផលិតផលនានាបានយ៉ាងឆាប់រហ័សចំណាយតិច ព្រមទាំងចូលរួមចំណែកក្នុងកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជាផងដែរ។

ទន្ទឹមនឹងសមិទ្ធិផលដែលសម្រេចបានខាងលើនេះ វាក៏មាននូវចំណុចខ្វះខាតមួយចំនួនផង ដែរដែលតម្រូវឱ្យសាលាខេត្តកំពង់ស្ពឺ ខិតខំអនុវត្តឱ្យកាន់តែល្អប្រសើរឡើងថែមទៀតមានដូចជាៈ ការដោះស្រាយជម្លោះដីធ្លីដែលនៅសេសសល់ ការងារចោរកម្មគ្រប់ប្រភេទ ក្រុមក្មេងទំនើង មុខ សញ្ញាប្រើប្រាស់គ្រឿងញៀន អំពើហឹង្សាក្នុងគ្រួសារ បញ្ហារស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋទាម-ទារឱ្យមានការយកចិត្តទុកដាក់លើកស្ទួយកម្រិតជីវភាព។

តាមនាមឱ្យប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ ដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិនិតីសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែករដ្ឋបាលសាធារណៈ ដែលបានចុះធ្វើការសិក្សាស្រាវជ្រាវនៅសាលា ខេត្តកំពង់ស្ពឺ សូមសំណូមពរដល់អាជ្ញាធរ មន្ទីរ អង្គភាពពាក់ព័ន្ធ និងកងកម្លាំងប្រដាប់អាវុធគ្រប់ ជាន់ថ្នាក់មេត្តាទប់ស្កាត់លំហូរចូល និងការប្រើប្រាស់គ្រឿងញៀន ជាពិសេសអប់រំអ្នកប្រើប្រាស់ឱ្យ យល់ដឹងបញ្ហាគ្រោះថ្នាក់នៃថ្នាំញៀន និងធានាឱ្យបាននូវស្ថេរភាពសង្គម សន្តិសុខ សុវត្ថិភាព ព្រមទាំងអនុវត្តច្បាប់ប្រកបដោយភាពត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

សរុបសេចក្តីមក ការងារគ្រប់គ្រងរដ្ឋបាលរបស់សាលាខេត្តកំពង់ស្ពឺ គឺមានសារៈសំខាន់ ណាស់សម្រាប់ប្រទេសដែលគោរពច្បាប់ ព្រោះថារដ្ឋបាលមូលដ្ឋានជារដ្ឋបាលដែលស្ថិតនៅជិត ប្រជាពលរដ្ឋបម្រើផលប្រយោជន៍ ស្គាល់សុខទុក្ខរបស់ប្រជាពលរដ្ឋ និងសេចក្តីត្រូវការរបស់ប្រជា-ពលរដ្ឋ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវកន្លងមកនេះ ភស្តុតាង ទន្និករណ៍នានាក៏បានលើកបង្ហាញ និងធ្វើសេចក្តីសន្និដ្ឋានខាងលើក្រុមយើងខ្ញុំក៏សូមចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ក្នុងព្រះរាជណាចក្រកម្ពុជា ដើម្បីចូលរួមចំណែកការពង្រឹងរដ្ឋបាលដែនដី និងកែលម្អរដ្ឋបាលសាធារណៈ នូវអនុសាសន៍ដូចខាងក្រោមៈ

– សូមរាជរដ្ឋាភិបាលធ្វើការសិក្សា និងរៀបចំបង្កើតវិទ្យាស្ថានរដ្ឋបាលសាធារណៈ ដើម្បីផ្តល់ការស្រាវជ្រាវផ្នែកគោលនយោបាយសាធារណៈ និងការបណ្តុះបណ្តាលពាក់ព័ន្ធនឹងមុខងាររដ្ឋបាលសធារណៈ។

– សូមរាជរដ្ឋាភិបាលធ្វើការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវតែបន្តអនុវត្តឱ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅថែមទៀត ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍដែលអាចជឿទុកចិត្តបានសំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។

– សូមរាជរដ្ឋាភិបាល និងរដ្ឋបាលខេត្ត ត្រូវធ្វើការរៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសធារណៈលើគ្រប់វិស័យជូនដល់ប្រជាពលរដ្ឋ។

– សូមរាជរដ្ឋាភិបាល និងរដ្ឋបាលខេត្ត ជំរុញឱ្យមានការផ្លាស់ប្តូរទស្សនាទានក្នុងក្របខណ្ឌនៃការផ្តល់សេវាសាធារណៈរបស់មន្រ្តីរាជការពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវា ព្រមទាំងផ្តល់តម្លៃដល់អ្នកប្រើប្រាស់សេវា។

– ជំរុញការកែទម្រង់របៀបរបបការងារ ពីរចនាសម្ព័ន្ធការងារទៅជារចនាសម្ព័ន្ធប្រតិបត្តិការដោយលើកកម្ពស់គុណភាពសេវាផ្នែកជួរមុខ ព្រមទាំងបង្កើនសមត្ថភាពផ្នែកទ្រទ្រង់។

– រដ្ឋបាលខេត្តត្រូវរៀបចំឱ្យមានការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពការបណ្តុះបណ្តាលទៅដល់មន្រ្តីក្នុងការកសាងសមត្ថភាពមន្រ្តីរាជការ និងអភិវឌ្ឍធនធានមនុស្ស ឱ្យមានប្រសិទ្ធភាព និងមានប្រព័ន្ធវាយតម្លៃច្បាស់លាស់។

– កែលម្អនីតិវិធី និងយន្តការផ្តល់សេវាសាធារណៈដែលអនុវត្តដោយស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នទទួលសមត្ថកិច្ច តាមរយៈយន្តការផ្សេងៗដូចជាគ្រឹះស្ថានសាធារណៈ ទីភ្នាក់ងារប្រតិបត្តការពិសេស និងការិយាល័យច្រកចេញចូលតែមួយជាដើម។

– រដ្ឋបាលខេត្តត្រូវរៀបចំដាក់ឱ្យមានដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈនៅតាមយន្តការផ្តល់សេវាសាធារណៈ។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររវាងក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុម-ប្រឹក្សា គណៈអភិបាលស្រុក។
- អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ប្រកាសអន្តក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ប្រកាសលេខ ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។
- ប្រកាសលេខ ៧២០៧ ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាជិកក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ។
- សេចក្តីណែនាំលេខ ០៣៤ សណន ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- សេចក្តីសម្រេចលេខ ០២ ស.ស.រ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ស្តីពីការទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ។
- សេចក្តីសម្រេចលេខ ០០២ ស.ស.រ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ ស្តីពីការទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការលទ្ធកម្ម របស់រដ្ឋបាលខេត្តកំពង់ស្ពឺ។

- សេចក្តីសម្រេចលេខ ០២/០៨ សសរ.ក្រប្រខ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ ស្តីពីការបង្កើតសមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រីនិងកុមារ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ។

**របាយការណ៍**

- របាយការណ៍ប្រចាំឆ្នាំ២០១៧ លេខ ០៣១/១៨ រ.ប.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកំពង់ស្ពឺ
- របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ លេខ ១៦៣/១៨ រ.ប.ក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកំពង់ស្ពឺ

**សៀវភៅតែងនិពន្ធ**

- សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលខេត្ត បោះពុម្ពខែកក្កដា ឆ្នាំ២០១១
- សៀវភៅនីតិមុខងារសាធារណៈ និពន្ធ និងរៀបរៀងដោយសាស្ត្រាចារ្យបណ្ឌិត ស៊ិន សុយន បោះពុម្ពឆ្នាំ២០១៧

**គេហទំព័រ**

- http:// www.kapongspeu.cambodia.gov.kh (ថ្ងៃចូលមើល ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨)

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- និមិត្តសញ្ញាសម្គាល់រដ្ឋបាលខេត្តកំពង់ស្ពឺ
- ផែនទីខេត្តកំពង់ស្ពឺ
- អង្គការលេខរដ្ឋបាលខេត្តកំពង់ស្ពឺ
- រចនាសម្ព័ន្ធរដ្ឋបាលខេត្តកំពង់ស្ពឺ
- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សេចក្ដីសម្រេចលេខ ០០២ ស.ស.រ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការលទ្ធកម្ម របស់រដ្ឋបាលខេត្តកំពង់ស្ពឺ
- សេចក្ដីសម្រេចលេខ ០២/០៨ សសរ.ក្រប្រខ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ ស្ដីពីការបង្កើតសមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

# ឧបសម្ព័ន្ធទី ១

## និមិត្តសញ្ញាសម្គាល់រដ្ឋបាលខេត្តកំពង់ស្ពឺ

ខេត្ត កំពង់ធំ

# ឧបសម្ព័ន្ធទី ២

## ផែនទីខេត្តកំពង់ស្ពឺ



ផែនទីខេត្តកំពង់ស្ពឺ
ជើង
ពោធិ៍សាត់
កំពង់ឆ្នាំង
កោះកុង
កណ្ដាល
តាកែវ
កំពត
20 0 20 Kilometers

# ឧបសម្ព័ន្ធទី ៣

## អង្គការលេខរដ្ឋបាលខេត្តកំពង់ស្ពឺ


អង្គការលេខរដ្ឋបាលខេត្តកំពង់ស្ពឺ
ក្រុមប្រឹក្សា
គណៈកម្មាធិការសម្រេចសម្រួលបច្ចេកទេស
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
គណៈកម្មាធិការផ្សេងៗទៀត
មន្ទីរ អង្គភាពជំនួយ
គណៈអភិបាល
នាយករដ្ឋបាល
ទីចាត់ការរដ្ឋបាល
ទីចាត់ការផែនការនិងវិនិយោគ
ទីចាត់ការហិរញ្ញវត្ថុ
ទីចាត់ការធនធានមនុស្ស
ទីចាត់ការអន្តរវិស័យ
អង្គភាពលទ្ធកម្ម
អង្គភាពច្រកចេញចូលតែមួយ
- ការិ.របៀប និងឯកសារ
- ការិ.ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការិ.សរុប និងព័ត៌មាន
- ការិ.ស្ថិតិ និងអត្រានុកូលដ្ឋាន
- ការិ.លេខាធិការក្រុមប្រឹក្សា
- ការិ.ផែនការ
- ការិ.គាំទ្រមូលដ្ឋាន
- ការិ.វិនិយោគ
- ការិ.ហិរញ្ញកិច្ច
- ការិ.គណនេយ្យ
- ការិ.គ្រប់គ្រងទ្រព្យសម្បត្តិ
- ការិ.គ្រប់គ្រងបុគ្គលិក
- ការិ.កសាងសមត្ថភាព
- ការិ.កិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច
- ការិ.គ្រប់គ្រងការអភិវឌ្ឍន៍ និងសំណង់
- ការិ.កិច្ចការច្បាប់និងសុវត្ថិភាពសាធារណៈ

# ឧបសម្ព័ន្ធទី ៤

## រចនាសម្ព័ន្ធរដ្ឋបាលខេត្តកំពង់ស្ពឺ

## រចនាសម្ព័ន្ធរដ្ឋបាលខេត្តកំពង់ស្ពឺ

### ឯកឧត្តម វ៉ី សំណាង អភិបាលខេត្ត

**១.ដឹកនាំការងាររួម**
**២.ដឹកនាំផ្ទាល់:**
- រដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាអាណាប័ក ក្នុងនាមក្រុមប្រឹក្សា

### ឯកឧត្តម គុច សេង អភិបាលរងខេត្ត

ទទួលបន្ទុកដឹកនាំលើការងារ៖
- នគរូបនីយកម្ម សំណង់ និងសុរិយោដី
- កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល
- ធនធានទឹក ឧតុនិយម និងធារាសាស្ត្រ ទឹកស្អាត
- សាធារណការ និងដឹកជញ្ជូន
- អង្គភាពអគ្គិសនី
- កាកបាទក្រហម និងការងារផ្សេងៗទៀត តាមការប្រគល់ ជូនពី **ឯកឧត្តមអភិបាលខេត្ត**

### លោកជំទាវ ឡុង បូណារេត អភិបាលរងខេត្ត

ទទួលបន្ទុកដឹកនាំលើការងារ៖
- មន្ទីរកិច្ចការនារី ស្ត្រីនិងកុមារ
- ការងារព័ត៌មាន
- សុខាភិបាល
- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការបង្ក្រាបការជួញដូរមនុស្ស
- ការងារគ្រប់គ្រងគ្រោះមហន្តរាយ និងការងារផ្សេងៗទៀត តាមការប្រគល់ជូនពី **ឯកឧត្តមអភិបាលខេត្ត**

### ឯកឧត្តម ចាន់ តារា អភិបាលរងខេត្ត

ទទួលបន្ទុកដឹកនាំលើការងារ៖
- សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធានាគារ រតនាគារ ពន្ធដារ គយ និងរដ្ឋាករ
- សាខាកាំកុងត្រូល
- លទ្ធកម្មសាធារណៈ
- អនុគណៈកម្មការវិនិយោគខេត្ត និងការងារផ្សេងៗទៀត តាមការប្រគល់ជូនពី **ឯកឧត្តមអភិបាលខេត្ត**

### ឯកឧត្ត សរ សុព្យត្រា អភិបាលរងខេត្ត

ទទួលបន្ទុកដឹកនាំលើការងារ៖
- គ្រប់គ្រងធនធានមនុស្ស
- ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- កិច្ចការសាធារណៈ ធម្មការ និងសាសនា
- អប់រំ យុវជន និងកីឡា កិច្ចការរដ្ឋបាលខេត្ត
- រៀបចំបុណ្យជាតិ អន្តរជាតិ កងកម្លាំងទាំង៣
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារប្រយុទ្ធប្រឆាំង និងគ្រឿងញៀននិងការងារផ្សេងៗទៀត តាមការប្រគល់ជូនពី **ឯកឧត្តមអភិបាលខេត្ត**

### ឯកឧត្តម ព្រុំ វណ្ណៈ អភិបាលរងខេត្ត

ទទួលបន្ទុកដឹកនាំលើការងារ៖
- កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ សិទ្ធមនុស្ស
- ស្ថិតិ និងអគ្រានុកូលដ្ឋាន តុលាការ និងពន្ធនាគារ
- គណបក្សនយោបាយ និងសមាគម ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល វេទិការសាធារណៈ
- ឧស្សាហកម្ម សិប្បកម្មរ៉ែ និងថាមពល
- ទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច
- សម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ និងការងារផ្សេងៗទៀត តាមការប្រគល់ជូនពី **ឯកឧត្តមអភិបាលខេត្ត**

### ឯកឧត្តម សុខ តា អភិបាលរងខេត្ត

ទទួលបន្ទុកដឹកនាំលើការងារ៖
- អភិវឌ្ឍន៍ជនបទ បរិស្ថាន និងអភិរក្សឧទ្យានជាតិ
- កិច្ចការគ្រប់គ្រងកាកសំណល់រឹង-រាវ
- កិច្ចការផែនការ និងវិនិយោគ
- ការងារលទ្ធកម្ម ផអ៣
- កិច្ចការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- កិច្ចការងារទេសចរណ៍ និងការងារផ្សេងៗទៀតតាមការប្រគល់ជូនពី **ឯកឧត្តមអភិបាលខេត្ត**

# ឧបសម្ព័ន្ធទី ៥

## ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល

## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

## ជំពូកទី ១

## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ពង្រឹង និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.-**

ការបង្កើតរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ គឺសំដៅលើការពង្រឹងអង្គភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

**មាត្រា ៩.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលដែនដីសាធារណៈ ។

**មាត្រា ១០.-**

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**មាត្រា ១១.-**

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១២.-**

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ រួមមាន :

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.-**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម :

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២០.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២១.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត

- មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

- មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ២២.-**

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

- សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

- សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

- សាមីខ្លួនទទួលមរណភាព

- សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬ បទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

**មាត្រា ២៣.–**

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួស ក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៤.–**

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំលាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៥.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម ៖

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំលាយតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០) ថ្ងៃ ។

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**មាត្រា ២៦.–**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

**មាត្រា ២៧.–**

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

**មាត្រា ២៨.–**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**មាត្រា ២៩.–**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

**មាត្រា ៣០.–**

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ។

**មាត្រា ៣១.-**

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។

**មាត្រា ៣២.-**

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៣៣.-**

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

**មាត្រា ៣៤.-**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

**មាត្រា ៣៥.-**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋ-ធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

**មាត្រា ៣៦.-**

រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬ ដីកាតាមការចាំបាច់ ត្រូវតែមិន[illegible]នឹង :

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.–**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ (១២) ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣) ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៤០.-**

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

**មាត្រា ៤១.-**

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

**មាត្រា ៤២.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញផលការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

-តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារ ភារកិច្ច និងធនធានថ្មីៗ

-សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់

-ការកាត់បន្ថយភាពក្រីក្រ

-តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូលទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

**មាត្រា ៤៣.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ៤៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី ។

សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង ។

ក្រុមប្រឹក្សាត្រូវអនុម័តលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីនិងប្រតិទិននៃការកសាងថវិការដ្ឋជារៀងរាល់ឆ្នាំ ។

ក្រុមប្រឹក្សាត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងនិងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានតុល្យភាពរវាងចំណូល និងចំណាយ ។

**មាត្រា ៤៥.–**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធី ដែលបានកំណត់ទាក់ទិនទៅនឹង :

-ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា

-គណនេយ្យ និងរបាយការណ៍

-ទ្រព្យសកម្ម និងទ្រព្យអកម្ម

-តម្លាភាព និងគណនេយ្យភាព

-ការគ្រប់គ្រង :

+ ចំណូលផ្ទាល់

+ ចំណូលដែលចែករំលែក មូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

+ ចំណូលពីប្រភពផ្សេងៗទៀត ។

-លទ្ធកម្មសាធារណៈ

-ការធ្វើសវនកម្មផ្ទៃក្នុង

-ការធ្វើសវនកម្មផ្ទៃក្រៅ

-តម្រូវការផ្នែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត ។

បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.–**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យ

សម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យខ្លួន ឬ ដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួនផ្សេងទៀតឱ្យមានប្រសិទ្ធភាព ។

នីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៧.-**

ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬ អ្នកដែលបានទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រដ្ឋ ឬ ក្នុងក្រុមប្រឹក្សាណាមួយ ឬ ជនណាម្នាក់ ដែលបានប្រព្រឹត្តអំពើដោយចេតនា ហើយដែលមិនអាចធ្វើយុត្តិកម្មបាន ដូចជា :

-ការប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈណាមួយ

-ការមិនបានប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬ ការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈ ។

**មាត្រា ៤៩.-**

ការរំលោភអំណាច រួមមានសកម្មភាពណាមួយ ដូចខាងក្រោម :

-ការរំលោភសិទ្ធិស្របច្បាប់ ឬ សិទ្ធិមនុស្សរបស់ជនណាម្នាក់

-ការកាន់កាប់ ឬ ការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬ ទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់

-ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ

-ការដកយកថវិកា ឬ ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ

-ការស្នើសុំ ឬ ការទទួលប្រាក់ ឬ រង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬ មិនធ្វើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬ រង្វាន់ នោះមិនបានកំណត់នៅក្នុងច្បាប់

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬប្រកាស

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា

-ការធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ផលប្រយោជន៍គ្រួសាររបស់ខ្លួន ។

មាត្រា ៥០.-

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធ :

-ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ

-សកម្មភាពនានាដែលបានអនុវត្ត

-របាយការណ៍ហិរញ្ញវត្ថុ

-ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា

-លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ

-វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំ ។

មាត្រា ៥១.-

ក្រុមប្រឹក្សា ត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការជូនព័ត៌មានជា

សាធារណៈអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារផ្សេងទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ៥២.-**

ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬ មធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

## ផ្នែកទី ៣
## ដីការបស់ក្រុមប្រឹក្សា

**មាត្រា ៥៣.-**

ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា ។

យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួន តាមការធ្វើសេចក្តីសម្រេចដើម្បីដាក់ចេញនូវដីកាតាមការចាំបាច់ ។

**មាត្រា ៥៤.-**

ដីការបស់ក្រុមប្រឹក្សា មានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬ ដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬ លើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សារួមមាន :

-តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលប្រគល់ឱ្យក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះ មិនបានដកចេញនូវសិទ្ធិអំណាចខ្លះ ឬ ទាំងអស់ដើម្បីដាក់ចេញដីកា ឬកិច្ចការណាមួយដែលច្បាប់នេះ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសផ្សេងទៀត តម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា ។

## មាត្រា ៥៥.–

ដីកាដែលដាក់ចេញដោយក្រុមប្រឹក្សា ត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលរបស់ខ្លួន លើកលែងតែដីកាចែងផ្សេងពីនេះ ឬ លើកលែងតែច្បាប់ណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់ ។

## មាត្រា ៥៦.–

ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលក្រុមប្រឹក្សាប្រកាសផ្សាយដីកានោះ ។

ដីកា អាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគត សម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬ ផ្នែកខ្លះនៃដីកា ។

ដីកា មិនអាចមានប្រតិសកម្ម និងមិនអាចចូលជាធរមានមុនពេលដែលដីកាត្រូវបានអនុម័ត និងប្រកាសផ្សាយនោះឡើយ ។

## មាត្រា ៥៧.–

ដីកា ដែលចែងផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ដីកានោះនឹងមិនមានសុពលភាពបានឡើយ ។

## មាត្រា ៥៨.–

ដីកាណាមួយដែលធ្វើឡើងដោយមានការរើសអើងក្នុងន័យជាអវិជ្ជមាន ឬ អនុវត្តចំពោះតែបុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬ ជាតិកំណើត ឬ អសមត្ថភាពខាងស្មារតី ឬ ខាងកាយសម្បទា ដីកានោះមិនមានសុពលភាពបានឡើយ ។

## មាត្រា ៥៩.–

ដីកាអាចបង្កើតបទប្បញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ចំពោះការប្រព្រឹត្តល្មើស ឬ ការមិនគោរពតាមបទប្បញ្ញត្តិមួយ ឬ ច្រើននៃដីកានោះបាន ។

បែបបទ នីតិវិធីនៃការរៀបចំបទប្បញ្ញត្តិ សម្រាប់ការពិន័យជាប្រាក់ដោយដីការបស់

ក្រុមប្រឹក្សា និងកម្រិតនៃប្រាក់ពិន័យនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦០.-**

ក្រុមប្រឹក្សានីមួយៗត្រូវអនុវត្តទៅតាមនីតិវិធីក្នុងការរៀបចំតាក់តែង ការកែប្រែ ឬ ការលុបចោលដីការបស់ខ្លួន ។

ការកែប្រែដីកា ឬ ការលុបចោលដីការបស់ក្រុមប្រឹក្សា ត្រូវសម្រេចដោយដីការបស់ក្រុមប្រឹក្សា ។

នីតិវិធីនៃការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សា ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦១.-**

ក្រុមប្រឹក្សា ត្រូវអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ខ្លួន ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចពង្រឹងការអនុវត្តដីការបស់ខ្លួនតាមរយៈ ឬ ដោយមានកិច្ចសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវជួយក្រុមប្រឹក្សា ដើម្បីពង្រឹងការអនុវត្តដីការបស់ក្រុមប្រឹក្សា នៅពេលដែលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា ។

## ផ្នែកទី ៤
## អង្គប្រជុំ និង បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សា

**មាត្រា ៦២.-**

អង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ត្រូវប្រារព្ធធ្វើឡើងនៅក្នុងរយៈពេលមិនឱ្យលើសពីដប់បួន(១៤)ថ្ងៃ បន្ទាប់ពីថ្ងៃដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

ក្រសួងមហាផ្ទៃ ត្រូវចាត់តាំងមន្ត្រីមួយរូបឱ្យធ្វើជាអធិបតីក្នុងអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ។

មាត្រា ៦៣._

ប្រធានក្រុមប្រឹក្សា គឺជាប្រធានអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ។

មាត្រា ៦៤._

ប្រធានអង្គប្រជុំរបស់ក្រុមប្រឹក្សា មានភារកិច្ច :

-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា ដោយមិនលំអៀង

-គោរព អនុវត្តច្បាប់ និងបទបញ្ជាផ្ទៃក្នុងសម្រាប់អង្គប្រជុំរបស់ក្រុមប្រឹក្សា ។

មាត្រា ៦៥._

ក្នុងករណីប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាធ្វើជាអធិបតីនៃអង្គប្រជុំ ។

ក្នុងករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតក្នុងលំដាប់លេខរៀងបន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលជាប់ឆ្នោតលំដាប់ទី ២ ក្នុងក្រុមប្រឹក្សា ដើម្បីធ្វើជាអធិបតីនៃអង្គប្រជុំ ។

ករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលជាប់ឆ្នោតលំដាប់ទី ២ ក្នុងក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតក្នុងលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយនោះឱ្យធ្វើជាអធិបតីនៃអង្គប្រជុំ ។

មាត្រា ៦៦._

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សានឹងមានសុពលភាពទៅបាន លុះត្រាតែមានវត្តមានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល ។

សមាជិកក្រុមប្រឹក្សាគ្រប់ៗរូបដែលមានវត្តមាននៅក្នុងអង្គប្រជុំ មានសិទ្ធិបោះឆ្នោតមួយសំឡេងដើម្បីអនុម័តរាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ។

ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬ សេចក្ដីសម្រេច ដោយសំឡេងលើសពីពាក់កណ្ដាល

ធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១១.-**

ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង ។

**មាត្រា ១១២.-**

ក្រុមប្រឹក្សាក្រុងត្រូវធ្វើប្រតិភូកម្មមុខងារ ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១៣.-**

តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## អំពីគណៈកម្មាធិការក្រុមប្រឹក្សា និងគណៈអភិបាល
### ផ្នែកទី ១
### គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

**មាត្រា ១១៤.-**

ក្រុមប្រឹក្សា មានកាតព្វកិច្ចរៀបចំឱ្យមានគណៈកម្មាធិការដូចខាងក្រោម :

-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-គណៈកម្មាធិការលទ្ធកម្ម ។

**មាត្រា ១១៥.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងទៀត ដើម្បីជួយការងាររបស់ក្រុមប្រឹក្សាតាមការចាំបាច់ ។

ក្រុមប្រឹក្សាអាចតែងតាំងសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង បុគ្គលិកក្រុមប្រឹក្សាជាសមាជិកគណៈកម្មាធិការ បាន ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីរបស់ក្រុមប្រឹក្សា ឬ តួនាទី ភារកិច្ចរបស់គណៈអភិបាលឡើយ ។

**មាត្រា ១១៦.-**

ក្រុមប្រឹក្សា ត្រូវសម្រេចអំពីចំនួនសមាជិកគណៈកម្មាធិការនីមួយៗ អំពីការតែងតាំងប្រធាន អនុប្រធាន និងអំពីការកំណត់តួនាទី ភារកិច្ច សកម្មភាពរបស់គណៈកម្មាធិការនីមួយៗដែលខ្លួនបានបង្កើតឡើង ។

**មាត្រា ១១៧.-**

ក្រុមប្រឹក្សា អាចអនុញ្ញាតឱ្យគណៈកម្មាធិការនីមួយៗជ្រើសរើសបុគ្គល ដែលមិនមែនជាសមាជិកក្រុមប្រឹក្សា ធ្វើជាទីប្រឹក្សាតាមការចាំបាច់ ។

**មាត្រា ១១៨.-**

ក្រុមប្រឹក្សា ត្រូវធានាឱ្យមានតំណាងស្ត្រីនៅក្នុងគណៈកម្មាធិការរបស់ខ្លួនរួមទាំងប្រធាន ឬ អនុប្រធានគណៈកម្មាធិការផង ។

**មាត្រា ១១៩.-**

គណៈកម្មាធិការនីមួយៗនៃក្រុមប្រឹក្សា ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនឱ្យបានទៀងទាត់ឱ្យក្រុមប្រឹក្សា និងគណៈអភិបាល ។

**មាត្រា ១២០.-**

ក្រុមប្រឹក្សា អាចបញ្ឈប់សមាជិកណាមួយពីគណៈកម្មាធិការដែលខ្លួនបានបង្កើតឡើង ។

ក្នុងករណីដែលសមាជិកគណៈកម្មាធិការនោះ ជាសមាជិកក្រុមប្រឹក្សា សមាជិកនោះនៅតែជាសមាជិកក្រុមប្រឹក្សាដដែល ។

**មាត្រា ១២១.-**

ក្រុមប្រឹក្សា ត្រូវទទួលខុសត្រូវរាល់សេចក្តីសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា ដែលខ្លួនបានបង្កើតឡើង និងទទួលខុសត្រូវចំពោះផលវិបាកពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ ។

**មាត្រា ១២២.-**

ក្រុមប្រឹក្សា ត្រូវផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន និងការគាំទ្រដទៃទៀត ដល់គណៈកម្មាធិការនានាដែលខ្លួនបានបង្កើតឡើង ។

## ផ្នែកទី ២
## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

**មាត្រា ១២៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានសមាសភាព :

- អភិបាល ជាប្រធាន
- ប្រធានអង្គភាពទាំងអស់របស់ក្រុមប្រឹក្សា
- ប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា
- ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាលដែលផ្តល់សេវាសម្ភារៈ ឬ ហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។
- តំណាងផ្សេងៗទៀតតាមការចាំបាច់ ។

**មាត្រា ១២៤.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវខិតខំធានាឱ្យបានថា ផែនការអភិវឌ្ឍ និងថវិការបស់ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រដ្ឋាភិបាលដែលផ្តល់សេវាសម្ភារៈ ឬ ហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបានគិតបញ្ចូលយ៉ាងត្រឹមត្រូវទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកា

ប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១២៥.-**

ក្រសួងមហាផ្ទៃ អាចកំណត់ឱ្យក្រុមប្រឹក្សាពីរ ឬ ច្រើនប្រើប្រាស់រួមគ្នានូវគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។

**មាត្រា ១២៦.-**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៣

## គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

**មាត្រា ១២៧.-**

សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាស្ត្រីនៅក្នុងក្រុមប្រឹក្សានោះ ឬ ស្ត្រី និងបុរស នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១២៨.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សា លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១២៩.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សា គណៈកម្មាធិការនានា និងគណៈអភិបាល ។

**មាត្រា ១៣០.–**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំខាងលើនេះ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ មានសិទ្ធិទទួលបាននូវរបៀបវារៈប្រជុំ និងឯកសារសម្រាប់កិច្ចប្រជុំដូចសមាជិកអង្គប្រជុំដទៃទៀតដែរ ។

**មាត្រា ១៣១.–**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចចាត់តាំងសមាជិករបស់ខ្លួនយ៉ាងច្រើនពីរ(០២)រូប ដើម្បីចូលរួមក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈអភិបាល និងកិច្ចប្រជុំនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ។

សមាជិកដែលបានចាត់តាំងទាំងនេះ មានសិទ្ធិបញ្ចេញយោបល់ក្នុងកិច្ចប្រជុំនានាដូចគ្នានឹងសមាជិកដទៃទៀតនៃអង្គប្រជុំដែរ ។

**មាត្រា ១៣២.–**

ក្នុងករណីសមាជិកដែលត្រូវបានចាត់តាំងឱ្យចូលរួមក្នុងកិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា ១៣១ ជាសមាជិកក្រុមប្រឹក្សា សមាជិកនោះមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់គណៈអភិបាលបានឡើយ ។

**មាត្រា ១៣៣.–**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៣៤.–**

របាយការណ៍ប្រចាំឆ្នាំខាងលើនេះ ត្រូវរួមបញ្ចូលនូវ ៖

-ស្ថានភាពរួមនៃការចូលរួមរបស់ស្ត្រី ក្នុងការលើកកម្ពស់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ និងស្ថានភាពរបស់កុមារ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

-សមិទ្ធផល និងបញ្ហាប្រឈមរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ

ស្ត្រី និងកុមារ និងអនុសាសន៍ ដើម្បីពង្រឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១៣៥.–**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញប្រកាសណែនាំអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារតាមការចាំបាច់ ដោយផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ផ្នែកទី ៤

## គណៈកម្មាធិការលទ្ធកម្ម

**មាត្រា ១៣៦.–**

គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពកិច្ចលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហតម្លាភាព មិនលំអៀង ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ១៣៧.–**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៥

## គណៈអភិបាល

**មាត្រា ១៣៨.–**

ត្រូវរៀបចំឱ្យមានគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ១៣៩.–**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.–**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្ដែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.–**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.–**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្ដិឧត្ដមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧) ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៣.-**

អភិបាលរងរាជធានី អភិបាលរងខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិ ចាប់ពីវរមន្ត្រីឡើងទៅ

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៤.-**

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង

-មានអាយុ ចាប់ពីសាមសិប(៣០)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៥.-**

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុង

ចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង

-មានអាយុចាប់ពីម្ភៃប្រាំ(២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចបំផុតបី(០៣)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៦.–**

ក្នុងករណីចាំបាច់ អភិបាល អភិបាលរង អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅពីក្របខ័ណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវមានលក្ខណសម្បត្តិ សមស្របតាមមាត្រា ១៤២ មាត្រា ១៤៣ មាត្រា ១៤៤ និងមាត្រា ១៤៥ នៃច្បាប់នេះ ។

**មាត្រា ១៤៧.–**

អភិបាល អភិបាលរង មានអាណត្តិការងារមិនលើសពីបួន(០៤)ឆ្នាំ ។

អភិបាល អភិបាលរងអាចត្រូវបានតែងតាំងបានបួន(០៤)ឆ្នាំទៀត សម្រាប់អាណត្តិទី ២ របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល ។

**មាត្រា ១៤៨.–**

អភិបាល អភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ ។

**មាត្រា ១៤៩.–**

អភិបាល អភិបាលរងអាចចូលរួមគ្រប់អង្គប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោតបានឡើយ ។

**មាត្រា ១៥០.-**

អភិបាល អភិបាលរង ត្រូវបញ្ឈប់ពីមុខតំណែងនៅមុនពេលបញ្ចប់អាណត្តិការងារ ប្រសិនបើសាមីខ្លួន :

-ដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ

-ត្រូវបានដកហូតពីមុខតំណែង ។

**មាត្រា ១៥១.-**

អភិបាល អភិបាលរងណាមួយ ត្រូវដកហូតពីមុខតំណែងមុនពេលបញ្ចប់អាណត្តិការងារ ក្នុងករណីណាមួយដូចខាងក្រោម :

-បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬ អភិបាលរង

-*អសមត្ថភាព*

-បំពេញការងារមិនបានល្អ

-មានបញ្ហាសុខភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច

-បោះបង់ចោលការងារ

-ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ ។

**មាត្រា ១៥២.-**

ក្រុមប្រឹក្សា អាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខតំណែង ដោយផ្អែកតាមករណីណាមួយក្នុងចំណោមករណីដូចមានចែងក្នុងមាត្រា ១៥១ នៃច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់នូវសំណើខាងលើនេះ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេចចំពោះអភិបាលរាជធានី អភិបាលខេត្ត អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ។

ចំពោះអភិបាលរងក្រុង ស្រុក ខណ្ឌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេត និងដោះស្រាយជាបន្ទាន់ ។

**មាត្រា ១៥៣.–**

អភិបាល អភិបាលរង ត្រូវទទួលប្រាក់បៀវត្ស និងអាចទទួលកម្រៃផ្សេងៗទៀតដែលសមស្របនឹងមុខតំណែងនេះ ។

ប្រាក់បៀវត្ស និងកម្រៃផ្សេងៗទៀតរបស់អភិបាល អភិបាលរងត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋ-មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៥៤.–**

អភិបាល មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

អភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារ សន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិ-បាល ត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចស្នើរាជរដ្ឋាភិបាលចេញអនុក្រឹត្យដើម្បីកំណត់តួនាទី សិទ្ធិអំណាចរបស់អភិបាលក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា តាមការចាំបាច់ ។

**មាត្រា ១៥៥.–**

គណៈអភិបាល ត្រូវផ្ដល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ។

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្ត

មុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៥៦.-**

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធាន ទាំងអស់ ដែលបានបែងចែក ឬ បានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ រួចហើយត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរបៀបបំពេញ មុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ ។

**មាត្រា ១៥៧.-**

ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិបាល និងអភិ-បាល ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬ អភិបាល និង បុគ្គលដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៥៨.-**

គណៈអភិបាល ឬ អភិបាលដែលបានសម្រេច ឬ បានអនុវត្តកិច្ចការណាមួយដែល ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការ សម្រេច ឬ សកម្មភាពនោះ ពុំមានសុពលភាពបានឡើយ ។

**មាត្រា ១៥៩.-**

គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការ នានារបស់ក្រុមប្រឹក្សា ក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយទៅអង្គប្រជុំសាមញ្ញមួយទៀត របស់ក្រុមប្រឹក្សា ។

**មាត្រា ១៦០.-**

គណៈអភិបាលត្រូវផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធ-សាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយក

មាត្រា ២៧៣.–

បែបបទ និងនីតិវិធីនៃការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## ជំពូកទី ៦
## អំពីទោសប្បញ្ញត្តិ

មាត្រា ២៧៤.–

សមាជិកក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលវិន័យដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

មាត្រា ២៧៥.–

វិន័យដែលត្រូវអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាដែលបានប្រព្រឹត្តនូវកំហុស ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៤ ចំណុចទី ៥ មាត្រា ២២ នៃច្បាប់នេះ ។

មាត្រា ២៧៦.–

វិន័យដែលត្រូវអនុវត្ត ចំពោះគណៈអភិបាល នាយករដ្ឋបាល បុគ្គលិកក្រុមប្រឹក្សា ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៣ និងចំណុចទី ៦ មាត្រា ១៥១ នៃច្បាប់នេះ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលក្ខន្តិកៈដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៧

# អំពីអន្តរប្បញ្ញត្តិ

## ផ្នែកទី ១

## ការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវ

**មាត្រា ២៧៧.-**

រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌដែលត្រូវបានបង្កើតឡើងដោយច្បាប់នេះនឹងជំនួសរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលបច្ចុប្បន្ននេះ ។

**មាត្រា ២៧៨.-**

អភិបាលរាជធានី អភិបាលខេត្ត អភិបាលក្រុង អភិបាលខណ្ឌ អភិបាលស្រុកដែលបានតែងតាំងឡើងនៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តស្ថិតក្នុងមុខតំណែងនិងបំពេញការងាររហូតដល់មានក្រុមប្រឹក្សា និងគណៈអភិបាលដែលបានរៀបចំឡើងស្របតាមច្បាប់នេះមកជំនួស ។

**មាត្រា ២៧៩.-**

ការតែងតាំងគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី ១ នេះ ត្រូវធ្វើឡើងយ៉ាងយូរដប់បួន(១៤)ថ្ងៃ បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប." ប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗនោះ ។

**មាត្រា ២៨០.-**

ដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ទាំងអស់ដែលអនុវត្ត ឬ ដែលបានកាន់កាប់ដោយ ឬ ក្នុងនាមរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ទាំងអស់នោះត្រូវអនុវត្ត និងចាត់ចែងបន្តដោយរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ។

**មាត្រា ២៨១.-**

អង្គភាព និងមន្ត្រីបុគ្គលិកដែលបំពេញការងារក្នុងអង្គភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តជាអង្គភាព និងជាមន្ត្រីបុគ្គលិកនៃអង្គភាពទាំងនោះរបស់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រហូតដល់មានការរៀបចំជាថ្មី ។

**មាត្រា ២៨២.-**

ក្រសួងមហាផ្ទៃ ត្រូវធ្វើការកំណត់ និងកត់ត្រានូវការផ្ទេរ និងការទទួលយកនូវសិទ្ធិ កាតព្វកិច្ចទាំងអស់ កម្មសិទ្ធិ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ ព្រមទាំងអង្គភាព បុគ្គលិក ពីរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នជូនទៅរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ឱ្យបានសមស្រប និងមានតម្លាភាព ។

## ផ្នែកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ២៨៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបន្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា លើកលែងតែគោលការណ៍ដូចមានចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍នៃជំពូកទី ៥ នៃច្បាប់នេះ ។

**មាត្រា ២៨៤.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវរៀបចំលិខិតបទដ្ឋានសម្រាប់គាំទ្រឃុំ សង្កាត់ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍នៃជំពូកទី ៥ នៃច្បាប់នេះ ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៩០៥.៥៥៥

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ឧបសម្ព័ន្ធទី ៦

## សេចក្តីសម្រេចលេខ ០០២ ស.ស.រ ចុះថ្ងៃ ទី២៥ ខែមីនា ឆ្នាំ២០១៦ ស្តីពីការទទួលស្គាល់ សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការលទ្ធកម្ម របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ស្ពឺ**
លេខ៖ ០០២.... ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការលទ្ធកម្ម របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

## ប្រធានក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦៤២ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ អាណត្តិទី ២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣១៦ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងស្មារតីនៃកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត នាថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦

# សម្រេច

**ប្រការ១ .–**

ត្រូវបានទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្ត ដូចខាងក្រោម៖

| | | |
|---|---|---|
| ១). **ឯកឧត្តម ទ៉ី សំណាង** | អភិបាលខេត្ត | ជាប្រធាន |
| ២). **លោក ចាន់ តារា** | អភិបាលរងខេត្ត | ជាអនុប្រធាន |
| ៣). **លោក ថន ម៉ុនថា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាអនុប្រធាន |
| ៤). **លោកជំទាវ កែវ សុខុម** | សមាជិកាក្រុមប្រឹក្សាខេត្ត | ជាសមាជិក |
| ៥). **ឯកឧត្តម ហួត ថន** | សមាជិកក្រុមប្រឹក្សាខេត្ត | ជាសមាជិក |
| ៦). **ឯកឧត្តម ញឹម សុខ** | សមាជិកក្រុមប្រឹក្សាខេត្ត | ជាសមាជិក |
| ៧). **លោក កង វណ្ណារ៉ូ** | នាយករដ្ឋបាលសាលាខេត្ត | ជាសមាជិក |
| ៨). **លោក សួស ឌុល** | នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | ជាសមាជិក |
| ៩). **លោក ម៉ែន ចន្ទី** | ប្រធានអង្គភាពលទ្ធកម្ម | ជាលេខាធិការ |

**ប្រការ២.–**

ក្នុងដំណើរការលទ្ធកម្មនីមួយៗ ប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តត្រូវតែងតាំងសមាជិកចំពោះកិច្ចមួយចំនួនដែលជាមន្ត្រីមានសមត្ថភាពគាំទ្របច្ចេកទេសមកពីអង្គភាព ស្ថាប័នរដ្ឋ ឬជួលពីខាងក្រៅដោយប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្ត និងអាចអញ្ជើញមន្ត្រីជំនាញក្នុងរដ្ឋបាលរបស់ខ្លួន ឬពីអង្គភាព ស្ថាប័នរដ្ឋផ្សេងៗទៀតដើម្បីជួយផ្តល់យោបល់។ សមាជិកចំពោះកិច្ចនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវរំសាយដោយស្វ័យប្រវត្តិនៅពេលកិច្ចលទ្ធកម្មនោះត្រូវបានបញ្ចប់ជាស្ថាពរ។

**ប្រការ៣.–**

សមាជិកគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ។

**ប្រការ៤.–**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ ត្រូវធ្វើសេចក្តីសម្រេចដោយសម្លេងភាគច្រើន។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានគណៈកម្មាធិការលទ្ធកម្មមានឧត្តមានុភាព។

**ប្រការ៥.–**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- គោរពឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលរៀបចំដោយអង្គភាពលទ្ធកម្មដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័ត
- ណែនាំឱ្យអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃកំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រូវពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់ថវិកាលទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការកិច្ចលទ្ធកម្ម
- ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន
- ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័ត
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬបចារថ្លៃ

- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញលើលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ មុនសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅអោយអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅអ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមសង្កេតការណ៍ដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម លើកលែងតែដំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ៦._**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧._**

គណៈអភិបាលខេត្ត នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការទាំង ០៥ និងប្រធានអង្គភាពចំនួន ០១ របស់សាលាខេត្ត អភិបាលក្រុង ស្រុក ទាំង ០៨ មន្ទីរ អង្គភាពជុំវិញខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

កំពង់ស្ពឺ ថ្ងៃទី២៩ ខែ មិនា ឆ្នាំ ២០១៦

**ជ. ក្រុមប្រឹក្សា**

**ប្រធាន**

**យឹម សុខុម**

**<u>កន្លែងទទួល៖</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
"ដើម្បីគោរពជូនជ្រាប"
-ដូចក្នុងប្រការ ១, ៧
"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៧

## សេចក្តីសម្រេចលេខ ០២/០៨ សសរ.ក្រប្រខ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលសមាសភាពសមាជិក គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ស្ពឺ**
**ក្រុមប្រឹក្សាខេត្ត**
លេខ៖ ..០២./១៨ សសរ.ក្រប្រខ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតសមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

## ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦៤២ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ អាណត្តិទី ២
- យោងតាមអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- យោងប្រកាសលេខ ៤២៧៥ ប្រក ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាក្រុង គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាស្រុក
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១._** ត្រូវបានបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោកជំទាវ **កែវ សុខុម** | សមាជិកក្រុមប្រឹក្សាខេត្ត | ប្រធាន |
| ២- ឯកឧត្តម **សុខ យ៉ាន** | សមាជិកក្រុមប្រឹក្សាខេត្ត | អនុប្រធាន |
| ៣-លោកស្រី **ឡុង មុណារេត** | អភិបាលរងខេត្ត | អនុប្រធាន |
| ៤-លោកស្រី **ស្រី លីនណា** | អនុប្រធានមន្ទីរ ស.អ.យ ខេត្ត | អនុប្រធាន |
| ៥-លោកស្រី **កែវ សុខន** | អនុប្រធានមន្ទីរកិច្ចការនារីខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៦-លោក **ហាន តក្កី** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៧-លោក **ខិន កែវសុវណ្ណា** | អនុប្រធានមន្ទីរសុខាភិបាលខេត្ត | សមាជិក |
| ៨-លោកស្រី **អ៊ុក សូម៉ាអ៊ី** | អនុប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ៩-លោក **ប៉ាស្គួខ សៅគន្ធ** | អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០-លោកស្រី **ស៊ិន សុខា** | អនុប្រធានមន្ទីរ អ.យ.ក ខេត្ត | សមាជិក |
| ១១-លោកស្រី **លឿង សោភា** | អនុប្រធានមន្ទីរ ក.ប ខេត្ត | សមាជិក |
| ១២-លោកស្រី **ណុច សុគន្ធ** | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣-លោកស្រី **ខិន សុគន្ធា** | ស្នងការរងនគរបាលខេត្ត | សមាជិក |
| ១៤-លោក **លុយ ច័ន្ទតារា** | នាយករងទីចាត់ការអន្តរវិស័យ | សមាជិក |
| ១៥-លោក **ជុំ ទ្រួក** | ប្រធានសមាគមក្រុមប្រឹក្សាក្រុងស្រុក ឃុំ សង្កាត់ | សមាជិក |
| ១៦-លោក **រ័ត្ន ថាវី** | តំណាងអង្គការអាដហុកប្រចាំខេត្ត | សមាជិក |
| ១៧-កញ្ញា **តា ម៉ាឡែន** | តំណាងអង្គការ L.W.D ប្រចាំខេត្ត | សមាជិក |

**ប្រការ២._** គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ចូលរួមក្នុងការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល ០៥ ឆ្នាំ និងកម្មវិធីវិនិយោគ ០៣ ឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា
- ចូលរួមក្នុងការតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដែលទាក់ទងទៅនឹងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ស្វែងរកការគាំទ្រពីក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការផ្សេងៗទៀតនៃក្រុមប្រឹក្សាដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

- សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាស្រុក ក្រុង ក្នុងការដោះស្រាយបញ្ហា និងសំណូមពរ ឬសំណើនានា ដែលគណៈកម្មាធិការនៃក្រុមប្រឹក្សាស្រុក ក្រុង មិនអាចដោះស្រាយបានក្នុងការអនុវត្ត មុខងាររបស់ខ្លួន
- លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សា ឬគណៈអភិបាលអំពីវិធានការសមស្រប នានាដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ
- ស្វែងរក និងការទទួលបានរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការងាររបស់គណៈកម្មាធិការ
- ជំរុញលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាដែលទាក់ទងនឹង សមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ ដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ច របស់ក្រុមប្រឹក្សា
- ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍អំពីអ្វីដែលបានកើតមានជាប្រចាំពាក់ព័ន្ធ នឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ និងមានវិធានការដើម្បីឆ្លើយតប
- ស្វែងរកការគាំទ្រដើម្បីជំរុញឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការងារ អភិវឌ្ឍន៍នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនងកិច្ចសហការ និងការសម្រប សម្រួលរវាងក្រុមប្រឹក្សាស្រុក ក្រុង មន្ទីរអង្គភាពពាក់ព័ន្ធនានា អ្នកផ្តល់សេវា អង្គការ មិនមែនរដ្ឋាភិបាល ក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍ដើម្បីធានាថាសកម្មភាពទាំងឡាយ ត្រូវបានគាំទ្រដល់ស្ត្រី យុវវ័យ និងកុមារ
- ពិនិត្យមើលការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ពិសេសដើម្បីកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវានានា និង ដើម្បីលើកអនុសាសន៍ក្នុងការដោះស្រាយបញ្ហាទាំងនោះ
- រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាព ដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ
- គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែងដើម្បីកៀរគរមូលនិធិសំរាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សា។

**ប្រការ៣._** គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានរបៀបរបបការងារដូចខាងក្រោម៖

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិចូលរួមក្នុងរាល់កិច្ចប្រជុំ របស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា និងគណៈអភិបាល លើកលែងតែកិច្ចប្រជុំសម្ងាត់។ គណៈកម្មាធិការអាចចាត់តាំងសមាជិករបស់ខ្លួនយ៉ាងតិច (០២) រូប ដើម្បីចូលរួមក្នុង កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈអភិបាល និងកិច្ចប្រជុំនៃគណៈកម្មាធិការនានារបស់ ក្រុមប្រឹក្សា។ សមាជិកដែលចាត់តាំងនេះមានសិទ្ធិបញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំនានា ដូចគ្នានឹងសមាជិកដទៃផ្សេងទៀតនៃអង្គប្រជុំដែរ
- ក្នុងករណីសមាជិកដែលត្រូវបានចាត់ឱ្យចូលរួមក្នុងកិច្ចប្រជុំជាសមាជិកក្រុមប្រឹក្សា សមាជិក នេះមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោត អនុម័តក្នុងកិច្ចប្រជុំរបស់គណៈអភិបាលបានឡើយ

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវរៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រុមប្រឹក្សា
- តួនាទី និងភារកិច្ចរបស់ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវអនុវត្តតាមប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រង់ផ្នែកទី ៣ ប្រការទី ១៣,១៤,១៥,១៦,១៧,១៨ និងប្រការទី ១៩ ក្នុងប្រកាសទាំងស្រុង។

**ប្រការ៤._** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥._** គណៈអភិបាលខេត្ត នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការ និងអង្គភាពរបស់សាលាខេត្តទាំង ៦ អភិបាលក្រុង ស្រុកទាំង ៨ មន្ទីរជំនាញពាក់ព័ន្ធទាំងអស់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ...៤...រោច... ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

កំពង់ស្ពឺ ថ្ងៃទី០៥ ខែ មីនា ឆ្នាំ ២០១៨

**ជ.ក្រុមប្រឹក្សាខេត្ត**

**ប្រធាន**

**យឹម សុខុម**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ១,៥
  "ដើម្បីសហការ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ